

IJM

# ការវិភាគអំពីពលកម្មដោយបង្ខំឆ្លងដែននៅកម្ពុជា

## របាយការណ៍ស្តីពីការសិក្សាអំពីប្រេវ៉ាឡង់

# ខែធ្នូ ឆ្នាំ២០២២

ឯកសារបោះពុម្ពផ្សាយនេះ ផលិតដោយមូលនិធិ Walmart Foundation សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។ ឯកសារនេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) នៅសាកលវិទ្យាល័យឈីកាហ្គោ (Chicago University)។

NORC
នៅសាកលវិទ្យាល័យឈីកាហ្គោ
១១៥៥ វិថី East ៦០ ជាន់ទី ២
ឈីកាហ្គោ
IL ៦០៦៣៧

ដាក់ជូន

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**

ដាក់ជូនដោយ៖

Rachael Jackson
Xiran Liu
Paige Pepitone
Kyle Vincent
Kareem Kysia

**គោរពជូន៖** Kareem Kysia

Kysia-Kareem@norc,org
៣០១-៦៣៤-៩៤៧០

## សេចក្តីប្រកាសពុំទទួលខុសត្រូវ

ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ ពុំឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មូលនិធិ Walmart Foundation និង អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ឡើយ។

# មាតិកា


**សេចក្តីសង្ខេប** ........ 1
សារតារនៃការស្រាវជ្រាវ និងវិធីសាស្ត្រ ........ 1
វិធីសាស្ត្រជ្រើសសំណាកគំរូ ........ 1
ការវាស់ស្ទង់ពលកម្មដោយបង្ខំ ........ 1
របកគំហើញសំខាន់ៗ ........ 2
របកគំហើញជាក់លាក់អំពីសូចនាកររបស់អង្គការពលកម្មអន្តរជាតិ ........ 3
របកគំហើញជាក់លាក់អំពីកម្រិតវិសាលភាពនៃគ្រោះថ្នាក់ ៤ ប្រភេទ និងចំណុចចាប់ផ្តើមពីរជំហានរបស់មជ្ឈមណ្ឌលស្រាវជ្រាវ ណាក ........ 3
អនុសាសន៍ ........ 6
**១. សេចក្តីផ្តើម** ........ 8
សារតារ និងបរិបទ ........ 8
គោលបំណង និងវត្ថុបំណងនៃការសិក្សា ........ 8
**២. វិធីសាស្ត្រស្រាវជ្រាវ** ........ 11
វិធីសាស្ត្រប៉ាន់ប្រមាណប្រេវ៉ាឡង់ ........ 11
ការវាស់វែងការស្ទង់មតិ ........ 11
ការវាស់ស្ទង់ពលកម្មដោយបង្ខំ ........ 12
ការជ្រើសសំណាកគំរូ ........ 13
ការរៀបចំប្រមូលទិន្នន័យ ........ 15
ការបណ្តុះបណ្តាល និងការចុះកម្មសិក្សា ........ 18
ការបណ្តុះបណ្តាលអ្នកសម្ភាសន៍ និងការអនុវត្តសាកល្បង ........ 18
ការធានាគុណភាពទិន្នន័យ ........ 19
ក្រមសីលធម៌នៃការស្រាវជ្រាវ និងការអនុញ្ញាតដល់ការសិក្សា ........ 19
ដែនកំណត់នៃការសិក្សា ........ 20
**៣. របកគំហើញ** ........ 23
លក្ខណៈសម្បត្តិប្រជាសាស្ត្រ ........ 23
លក្ខណៈសម្បត្តិការងារ ........ 27
ការប្រព្រឹត្តជាក់ស្តែងឬការគម្រាមថានឹងប្រព្រឹត្តអំពើហិង្សាផ្លូវកាយឬផ្លូវភេទ ........ 31
ការរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរឬការប្រាស្រ័យទាក់ទង ........ 32
ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ ........ 33
បរិយាកាសការងារដែលឆបោកឬអយុត្តិធម៌ឬអសុវត្ថិភាព ........ 30
សោហ៊ុយច្រើនហួសហេតុក្នុងការចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន ........ 31
សេចក្តីសង្ខេបអំពីការរំលោភបំពានលើការជួញដូរមនុស្ស ........ 33
អន្តរកម្មជាមួយនឹងប្រព័ន្ធយុត្តិធម៌ ........ 40
ការចូលរួមដោយប្រើសម្មតិកម្មជាមួយនឹងប្រព័ន្ធយុត្តិធម៌ ........ 40
បទពិសោធន៍ពីអតីតកាលជាមួយនឹងប្រព័ន្ធយុត្តិធម៌ ........ 45
**៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 45
សេចក្តីសន្និដ្ឋាន ........ 45
អនុសាសន៍ ........ 48

# ពាក្យសរសេរកាត់

| | |
|---|---|
| CI | ចន្លោះជឿជាក់ |
| CITI | គំនិតផ្តួចផ្តើមបណ្តុះបណ្តាលស្ថាប័ន និងការសហការ |
| DQA | ការធានាគុណភាពទិន្នន័យ |
| DQR | ការត្រួតពិនិត្យគុណភាពទិន្នន័យ |
| FGD | កិច្ចពិភាក្សាក្រុមគោលដៅ |
| TIP Office | ការិយាល័យតាមដានត្រួតពិនិត្យ និងប្រឆាំងការជួញដូរមនុស្សនៃក្រសួងការបរទេសសហរដ្ឋអាមេរិក |
| KHR | ប្រាក់រៀលខ្មែរ |
| IJM | អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IRB | ក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIH | វិទ្យាស្ថានជាតិសុខាភិបាល |
| NORC | មជ្ឈមណ្ឌលស្រាវជ្រាវ ណរក នៃសាកលវិទ្យាល័យឈីកាហ្គោ |
| ODK | ឧបករណ៍ប្រមូលទិន្នន័យបើកចំហ |
| RDS | ការជ្រើសរើសសំណាកគំរូជំរុញដោយអ្នកឆ្លើយតប |
| TIP | អំពើជួញដូរមនុស្ស |
| TVPA | ច្បាប់ស្តីអំពីការការពារជនរងគ្រោះពីការជួញដូរមនុស្ស |



# សេចក្តីសង្ខេប

## សារតានៃការស្រាវជ្រាវ និងវិធីសាស្ត្រ

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** (IJM) បំពេញការងារលើការធានាឱ្យបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើទាសភាព ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើគាបសង្កត់ដោយហិង្សាក្នុងទម្រង់ផ្សេងៗ។

អង្គការ IJM បានចុះកិច្ចសន្យាជាមួយ មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) នៅសាកលវិទ្យាល័យឈីកាហ្គោ ស្តីពីការសិក្សាស្រាវជ្រាវឯករាជ្យ ដែលជាផ្នែកមួយនៃផែនការរបស់អង្គការក្នុងការវាយតម្លៃឥទ្ធិពលនៃកម្មវិធីរបស់អង្គការ ដោយមានការផ្តល់មូលនិធិពីមូលនិធិ Walmart Foundation ដើម្បីទទួលបានការប៉ាន់ប្រមាណអំពីប្រេវ៉ាឡង់បន្ទាត់គោលនៃពលកម្មដោយបង្ខំឆ្លងដែនក្នុងខេត្តចំនួន ៤ នៅប្រទេសកម្ពុជា រួមមាន ខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងសៀមរាប។

### វិធីសាស្ត្រជ្រើសសំណាកគំរូ

សំណាកគំរូគោលដៅសរុបសម្រាប់ការសិក្សាអំពីពលកម្មដោយបង្ខំឆ្លងដែន គឺមានចំនួន ១.២០០ នាក់ ដែលជាពលករចំណាកស្រុកដែលទើបត្រឡប់មកវិញនាពេលថ្មីៗនេះ។ ពលករចំណាកស្រុក (៣០០ នាក់ក្នុងមួយខេត្ត) បានរាយការណ៍ថាបានត្រលប់មកចូលប្រទេសវិញកាលពីរយៈពេល ១៨ ខែ ចុងក្រោយ ពីការទៅធ្វើការងារចំណាកស្រុកនៅប្រទេសមួយទៀត។ ដើម្បីអាចចូលរួមក្នុងការសិក្សានេះបាន អ្នកឆ្លើយតបសម្ភាសន៍ទាំងអស់ គឺតម្រូវឱ្យបំពេញតាមលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិដូចខាងក្រោម៖ (១) ត្រូវមានអាយុ ១៨ ឆ្នាំឡើងទៅ តាមពេលកំណត់កាលវិភាគសម្រាប់សម្ភាសន៍ និង (២) ធ្លាប់បានរស់នៅ និងបម្រើការងារនៅក្រៅប្រទេសកម្ពុជាកាលក្នុងអំឡុងពេល ១៨ ខែចុងក្រោយ។

ជំហានពាក់ព័ន្ធនានាក្នុងការប្រមូលទិន្នន័យរួមមាន៖

១. ការចុះតាមភូមិដែលបានជ្រើសរើសដោយចៃដន្យ
២. សម្ភាសន៍មេភូមិ ដើម្បីបង្កើតគ្រោងសំណាកគំរូដំបូងនៃពលរដ្ឋក្នុងសហគមន៍ស្របតាមលក្ខណៈសម្បត្តិដែលបានកំណត់
៣. ការចុះជួបប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីបញ្ជាក់អំពីលក្ខណៈសម្បត្តិ វាយតម្លៃឆន្ទៈក្នុងការចូលរួម និងកំណត់កាលវិភាគសម្រាប់សម្ភាសន៍
៤. ការចុះស្ទង់មតិអំពីប្រេវ៉ាឡង់ពលកម្មដោយបង្ខំឆ្លងដែន ៣ ដំបូងក្នុងភូមិ
៥. ស្នើសុំឱ្យអ្នកឆ្លើយតបផ្តល់ឈ្មោះ និងព័ត៌មានទំនាក់ទំនងសម្រាប់ប្រជាពលរដ្ឋក្នុងសហគមន៍ណាមួយផ្សេងទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលពួកគេស្គាល់ និងបន្ថែមឈ្មោះទាំងនេះទៅក្នុងគ្រោងសំណាកគំរូដើម (ប្រសិនបើពុំបានបន្ថែម)
៦. ជ្រើសរើសមនុស្សរហូតដល់ ៤ នាក់ ដោយចៃដន្យ ដើម្បីចាត់តាំង កំណត់អាទិភាពមនុស្សដែលអ្នកឆ្លើយតបទើបតែកំណត់អត្តសញ្ញាណហើយថ្មីៗ
៧. ការចុះស្ទង់មតិអំពីប្រេវ៉ាឡង់ពលកម្មដោយបង្ខំឆ្លងដែនចំនួន ៤ ចុងក្រោយក្នុងភូមិ

### ការវាស់ស្ទង់ពលកម្មដោយបង្ខំ

ឧបករណ៍ស្ទង់មតិសម្រាប់ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រផ្អែកលើសូចនាករ។ ការសិក្សានាពេលកន្លងមករបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងឯកសារនានាដែលមានស្រាប់ស្តីពីការរៀបចំការស្ទង់មតិ គឺផ្អែកលើការស្រាវជ្រាវអំពីការ

ជួញដូរមនុស្ស។ ការវាស់ស្ទង់សំខាន់ៗអំពីពលកម្មដោយបង្ខំ គឺបានសិក្សាស្របតាមក្របខណ្ឌច្បាប់ ដែលបានបង្កើតឡើងដោយអង្គការពលកម្មអន្តរជាតិ (ILO ឆ្នាំ២០១២) ហើយការវាស់ស្ទង់ទាំងនេះ តំណាងឱ្យសូចនាករដែលមានការឯកភាពគ្នាភាគច្រើនបំផុតអំពីពលកម្មដោយបង្ខំ ដែលបច្ចុប្បន្នកំពុងប្រើប្រាស់ដោយសហគមន៍ស្រាវជ្រាវនានា។ ក្រុមការងារស្រាវជ្រាវបានផ្ទៀងផ្ទាត់ទិន្នន័យគ្រប់ជ្រុងជ្រោយ (crosswalk exercise) ដើម្បីធានាថាឧបករណ៍នៃការស្ទង់មតិគាំទ្រដល់ក្របខណ្ឌច្បាប់ទាំងពីរ។

ដើម្បីសម្របសម្រួលដល់ការវិភាគ និងការបកស្រាយរបកគំហើញនៃការសិក្សា ជាដំបូងយើងបានចាត់ថ្នាក់សូចនាករពលកម្មដោយបង្ខំទៅជាប្រភេទនៃការរំលោភបំពានដែលបានកំណត់ ដោយផ្អែកលើការយល់ឃើញពីកម្រិតធ្ងន់ធ្ងរនៃការរំលោភសិទ្ធិមនុស្សពីសំណាក់និយោជក។ វិធីសាស្ត្រនេះ ជួយឱ្យអ្នកស្រាវជ្រាវបង្កើត "កម្រិតវិសាលភាពនៃគ្រោះថ្នាក់" ជាជាងការចាត់ថ្នាក់ការរំលោភបំពាននីមួយៗថាអាចមានឥទ្ធិពលអវិជ្ជមានស្មើៗគ្នា។ កម្រិតទាំងនេះរាប់ចាប់ពីកម្រិតធ្ងន់ធ្ងរបំផុត៖

១ បានបំពាន ឬគំរាមថានឹងបំពានលើសុចរិតភាពផ្លូវកាយ

២ បានរិតត្បិត ឬគំរាមថានឹងរិតត្បិតលើសេរីភាពផ្ទាល់ខ្លួន ឬការប្រាស្រ័យទាក់ទង

៣ ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំពលករចំណាកស្រុកការអនុវត្តការងារដែលមានការរំលោភបំពាន និងបង្ខិតបង្ខំ ពលករចំណាកស្រុក ធ្វើអ្វីដែលពួកគេពុំចង់ធ្វើ និង

៤ កិច្ចសន្យាឆបោក ការចាត់ចែងការងារដោយអយុត្តិធម៌ ឬអសុវត្ថិភាព ឬកង្វះខាតស្បៀងអាហារ និងជម្រក។

ទី២ យើងបានអនុវត្តគម្រោងចំណុចចាប់ផ្ដើម ២ ជំហាន ដើម្បីបង្កើតដែនកំណត់នៃការប្រឈមភាពងាយរងគ្រោះនឹងការជួញដូរមនុស្ស ដែលក្នុងនោះយើងវាស់ស្ទង់ ចំណាយលើការចាកចេញ "ច្រើនហួសហេតុ" ដែលនិយោជកប្រើប្រាស់ដើម្បីបង្អាក់ ឬរារាំងពលករចំណាកស្រុកពុំឱ្យចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន។ នៅក្រោមវិធីសាស្ត្របែបវិភាគនេះ ពលករចំណាកស្រុក (១) ធ្លាប់ទទួលរងការរំលោភបំពានក្នុងទម្រង់ខ្លះពីសំណាក់និយោជក ឬការអនុវត្តការងារពុំស្មើភាពគ្នា និង (២) ពុំធ្លាប់ឈប់ពីការងារ ដោយសារភ័យខ្លាចផលវិបាកធ្ងន់ធ្ងរ។ ស្របពេលដែល "កម្រិតវិសាលភាពនៃគ្រោះថ្នាក់" វាស់ស្ទង់អំពីកម្រិតវិសាលភាពនៃគ្រោះថ្នាក់ ឬការបង្កបួសស្នាមដែលបានប្រព្រឹត្តមកលើពលករចំណាកស្រុកម្នាក់ៗ គម្រោងចំណុចចាប់ផ្ដើម ២ជំហាន របស់យើងមានគោលបំណងកំណត់នូវអំពីពិសោធន៍ដែលបានជួបប្រទះផ្សេងៗដែលអាចរាប់បញ្ចូលជាការប្រឈមនឹងភាពងាយរងគ្រោះនៃការជួញដូរមនុស្ស។

## ៤ របកគំហើញសំខាន់ៗ

សូចនាកររបស់អង្គការពលកម្មអន្តរជាតិ (ILO) កម្រិតវិសាលភាពនៃគ្រោះថ្នាក់របស់ណាក និងចំណុចចាប់ផ្ដើម ២ជំហាន របស់មជ្ឈមណ្ឌលស្រាវជ្រាវ ណាក (NORC)

តាមរយៈការប្រើប្រាស់សូចនាករស្ដីពីពលកម្មដោយបង្ខំ

បានបង្ហាញអំពីលំនាំប្រែប្រួលនៃការរំលោភបំពានពលកម្មដោយបង្ខំ ក្នុងចំណោមពលករចំណាកស្រុកក្នុងប្រទេសកម្ពុជាដែលទើបតែត្រឡប់មកវិញនាពេលថ្មីៗនេះ។ វិសាលភាពនៃការរំលោភបំពានពលកម្មដោយបង្ខំក្នុងចំណោមអ្នកឆ្លើយតបមានភាពខុសគ្នាបន្តិចរវាងការវាស់ស្ទង់នីមួយៗ។ តាមរយៈការប្រើប្រាស់សូចនាករស្តីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ (ILO) (ការរួមបញ្ចូលគ្នានៃការគំរាមដាក់ទណ្ឌកម្ម និងការរំលោភបំពានដោយបង្ខំ) យើងបានប៉ាន់ប្រមាណថា ពលករចំណាកស្រុក ៨នាក់ ក្នុងចំណោម ១០ នាក់ដែលមកពីកម្ពុជា គឺទំនងជាទទួលរងនូវការរំលោភបំពានទាំងពីរប្រភេទនេះយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលធ្វើការងារក្នុងប្រទេសគោលដៅរបស់ពួកគេ។ តាមរយៈការប្រើប្រាស់ការវាស់ស្ទង់របស់មជ្ឈមណ្ឌលស្រាវជ្រាវ ណាក អត្រារងគ្រោះប៉ាន់ប្រមាណក្នុងការរំលោភបំពានណាមួយក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់នៅលើកម្រិតវិសាលភាពនៃគ្រោះថ្នាក់ គឺមានចន្លោះពី ១៣,៦១% ក្នុងប្រភេទធ្ងន់ធ្ងរបំផុត (ការរំលោភបំពានលើសុច្ចរិតភាពផ្លូវកាយ) រហូតដល់ ៥៧,៣១% ក្នុងប្រភេទមធ្យមនៃការរំលោភបំពាន (ការបំពេញការងារដែលមានការរំលោភបំពាន/ដោយបង្ខំ)។ ចំពោះចំណាយលើការចាកចេញច្រើនហួសហេតុវិញ យើងបានប៉ាន់ប្រមាណថា ពលករចំណាកស្រុកកម្ពុជា ៥៣,៧១% បានជួបប្រទះនឹងការរំលោភបំពានមួយក្នុងចំណោមការរំលោភបំពានដែលបានវាស់ស្ទង់ និងពុំអាចឈប់ពីការងារបាននោះទេ ដោយសារតែភ័យខ្លាចទទួលរងផលវិបាកធ្ងន់ធ្ងរ។ ផលវិបាករួមមាន ការរឹបអូសប្រាក់ចំណូលដែលរកបានទ្រព្យសម្បត្តិមានតម្លៃ ឯកសារអត្តសញ្ញាណ ការបង្ខូចកេរ្តិ៍ឈ្មោះរបស់ពលករដោយចេតនា ឬការគំរាមវាយការណ៍ទៅអាជ្ញាធរ។ លទ្ធផលនេះ ក៏បានបង្ហាញអំពីការប្រែប្រួលខ្លះពាក់ព័ន្ធនឹងយេនឌ័រនៃពលករចំណាកស្រុក ឧស្សាហកម្មដែលពួកគេបម្រើការងារ និងខេត្តដែលពួកគេរស់នៅ។

**របស់អង្គការពលកម្មអន្តរជាតិ (ILO) យើងបានប៉ាន់ប្រមាណថា ពលករចំណាកស្រុក ៨ នាក់ ក្នុងចំណោម ១០ នាក់ដែលមកពីកម្ពុជា គឺទំនងជាទទួលរងនូវការរំលោភបំពានយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលធ្វើការងារក្នុងប្រទេសគោលដៅរបស់ពួកគេ។**

## ◢ របកគំហើញជាក់លាក់អំពីសូចនាកររបស់អង្គការពលកម្មអន្តរជាតិ

ចំពោះ **ការគំរាមដាក់ទណ្ឌកម្ម វិញ** យើងប៉ាន់ប្រមាណថា ក្រុមប្រជាជនកម្ពុជាមួយចំណែកតូចដែលជាពលករចំណាកស្រុកដែលធ្លាប់បានជួបការរំលោភបំពានយ៉ាងហោចណាស់មួយក្នុងចំណោមការរំលោភបំពានដែលបានលើកឡើង គឺមានចំណែកស្មើនឹង ៤៦,៥១%។

ចំពោះការវាស់ស្ទង់អំពីភាពមិនស្ម័គ្រចិត្ត យើងប៉ាន់ប្រមាណថា អត្រារងគ្រោះរបស់អ្នកឆ្លើយតប គឺស្មើនឹង ៦០,៥៥%។

## ◢ របកគំហើញជាក់លាក់អំពីកម្រិតវិសាលភាពនៃគ្រោះថ្នាក់ ៤ ប្រភេទ និងចំណុចចាប់ផ្តើមពីរជំហានរបស់មជ្ឈមណ្ឌលស្រាវជ្រាវ ណាក

### កម្រិតវិសាលភាពនៃគ្រោះថ្នាក់ ៤ ប្រភេទ

១ **អំពើហិង្សាផ្លូវកាយឬផ្លូវភេទ** យើងប៉ាន់ប្រមាណថា ១៣,៦១% នៃពលករចំណាកស្រុកកម្ពុជា គឺមានបទពិសោធន៍យ៉ាងហោចណាស់មួយចេញពីការរស់ស្នង់។

២ **ការរឹតត្បិតសេរីភាព** យើងប៉ាន់ប្រមាណថា អត្រារងគ្រោះក្នុងចំណោមពលករចំណាកស្រុកកម្ពុជា គឺស្មើនឹង ៣៩,៦៧%។

៣ **ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ** យើងប៉ាន់ប្រមាណថា ពលករ ៥៧,៣១% នៃពលករចំណាកស្រុកកម្ពុជាប្រមាណ ធ្លាប់បានទទួលរងការរំលោភបំពានឬល្បិចកលពីសំណាក់និយោជកអំឡុងពេលបំពេញការងារ ដែលបង្ខំពលករចំណាកស្រុកឱ្យធ្វើអ្វីដែលពួកគេពុំចង់ធ្វើ។

៤ ចំពោះ **បរិយាកាសការងារដែលឆបោកឬអយុត្តិធម៌ឬអសុវត្ថិភាព** យើងប៉ាន់ប្រមាណថា ពលករប្រមាណ ២៨,២២% នៃពលករចំណាកស្រុកកម្ពុជា គឺមានបទពិសោធន៍យ៉ាងហោចណាស់មួយចេញពីការរស់ស្នង់។

## ចំណុចចាប់ផ្តើមពីរជំហានសម្រាប់កំណត់លក្ខណៈសម្បត្តិនៃការជួញដូរមនុស្ស

ចំពោះ **ចំណាយលើការចាកចេញច្រើនហួសហេតុ** យើងប៉ាន់ប្រមាណថា ៥៣,២១% នៃពលករចំណាកស្រុកកម្ពុជា ធ្លាប់បានជួបប្រទះនឹងការរំលោភបំពានមួយក្នុងចំណោមការរំលោភបំពានដែលបានរស់ស្នង់ និងពុំអាចឈប់ពីការងារបាននោះទេ ដោយសារភ័យខ្លាចទទួលរងផលវិបាកធ្ងន់ធ្ងរ។

*រូបភាព ១៖ សេចក្តីសង្ខេបអំពីសូចនាករស្តីពីពលកម្មដោយបង្ខំ*

**សូចនាកររបស់អង្គការពលកម្មអន្តរជាតិ**

ការគំរាមដាក់ទណ្ឌកម្ម

ភាពមិនស្ម័គ្រចិត្ត

ពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ (ការគំរាម ១ + ភាពមិនស្ម័គ្រចិត្ត ១)

**កម្រិតវិសាលភាពនៃគ្រោះថ្នាក់របស់ NORC**

ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ

ការរឹតត្បិតសេរីភាព

ការបំពេញការងារដែលមានការរំលោភបំពាន ឬដោយបង្ខំ

បរិយាកាសការងារដែលឆបោកឬអយុត្តិធម៌ឬអសុវត្ថិភាព

ទាំងអស់ខាងលើ (ការរងគ្រោះនៅកម្រិតអតិបរិមា)

**ចំណុចចាប់ផ្តើមពីរជំហាន**

សោហ៊ុយច្រើនហួសហេតុក្នុងការចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន




**បណ្តាញសង្គម-គ្រួសារ គឺជាបណ្តាញជ្រើសរើសពលករញឹកញាប់បំផុតក្នុងចំណោមពលករចំណាកស្រុកកម្ពុជា** ដោយអ្នកឆ្លើយតបចំនួន ២/៣ នៃអ្នកឆ្លើយតបសរុប ទទួលបានការងារតាមរយៈគ្រួសារ ឬមិត្តភក្តិក្នុងប្រទេសគោលដៅស្រាប់។ អ្នកឆ្លើយតប ១១,២១% ទៀត បានទទួលការងារតាមរយៈទីភ្នាក់ងារជ្រើសរើសពលករដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាល។ កម្រប់បំផុត អ្នកឆ្លើយតប ២,៨២% បានទទួលការងារតាមរយៈទីភ្នាក់ងារជ្រើសរើសពលករឯកជន ដែលពុំបានចុះបញ្ជីជាមួយរដ្ឋាភិបាល។

**ពលករចំណាកស្រុកកម្ពុជា ក៏ទទួលរ៉ាប់រងបន្ទុកហិរញ្ញវត្ថុក្នុងការបង់ថ្លៃសេវាចំណាកស្រុក និងការងារនៅក្រៅប្រទេសផងដែរ។** អ្នកឆ្លើយតបលើសពាក់កណ្តាល ចាំបាច់ត្រូវយកកម្ចី ដើម្បីបង់កម្រៃជ្រើសរើសការងារ និងចំណាយផ្សេងៗដើម្បីរក្សាការងារនៅក្រៅប្រទេស។ ចំនួនទឹកប្រាក់កម្ចីដែលបានខ្ចីជាមធ្យម គឺមានចំនួន ៣.៦៦៦.៨២៧ រៀល (ប្រហែល ៨៩០ ដុល្លារអាមេរិក)។ ចំនួនទឹកប្រាក់នេះ មានចន្លោះពីទាបបំផុតចំនួន ៣០០.០០០ រៀល (ប្រហែល ៧០ ដុល្លារអាមេរិក) ទៅខ្ពស់បំផុតចំនួន ១២០.០០០.០០០ រៀល (ប្រហែល ២៩.២៦៨ ដុល្លារអាមេរិក) ដែលបង្ហាញអំពីការខុសគ្នាជាខ្លាំងលើស្ថានភាពផ្ទាល់ខ្លួន។ ចំពោះប្រភពនៃប្រាក់កម្ចីវិញ មិត្តភក្តិ និងសមាជិកគ្រួសារ គឺជាប្រភពផ្តល់កម្ចីធំបំផុត (៤០,៩៥%) បន្ទាប់មកគឺធនាគារ (៣០,៧៦%) និងនិយោជក (១៨,០៩%)។ សម្ពាធហិរញ្ញវត្ថុពីប្រាក់កម្ចី ក៏ដូចជាលទ្ធភាពនៃការខ្ចីត្រួតគ្នាពីអ្នកជ្រើសរើសពលករ និយោជក និងអ្នកឱ្យខ្ចីប្រាក់ អាចធ្វើឱ្យពលករចំណាកស្រុកកម្ពុជាកាន់តែងាយរងគ្រោះកាន់តែខ្លាំងឡើង។

**ពលករចំណាកស្រុកបង្ហាញអំពីទំនុកចិត្តកម្រិតខ្ពស់លើប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសគោលដៅ និងប្រទេសកំណើតរបស់ពួកគេ។** អ្នកឆ្លើយតបស្ទើរតែជិត ៩៥% បាននិយាយថា ពួកគេនឹងរាយការណ៍អំពីការរំលោភបំពានពលកម្មដោយបង្ខំដែលអាចកើតឡើងទៅកាន់អាជ្ញាធរ។ ទោះបីជាតួលេខនេះ បង្ហាញអំពីឆន្ទៈខ្ពស់ក្នុងការរាយការណ៍ក៏ដោយ ក៏ការអះអាងបែបនេះពុំមែនមានន័យថា ពលករចំណាកស្រុកស្ទើរតែទាំងអស់នឹងធ្វើការរាយការណ៍ប្រកបដោយប្រសិទ្ធភាព (ឬព្យាយាមរាយការណ៍) អំពីការរំលោភបំពានដែលពួកគេជួបប្រទះនោះដែរ។ ទី១ ក្នុងការសាកសួរបន្តបន្ទាប់ អ្នកឆ្លើយតបតិចជាងពាក់កណ្តាលដែលមានឆន្ទៈរាយការណ៍ (៤៩,១៣%) បានកំណត់អត្តសញ្ញាណអាជ្ញាធរពាក់ព័ន្ធដែលពួកគេត្រូវរាយការណ៍បានយ៉ាងត្រឹមត្រូវ។ លើសពីនេះទៅទៀត អ្នកឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងឥរិយាបថនៃការរាយការណ៍ អាចនឹងមានការលំអៀងគ្នាខ្លះៗដែរ។ សំណាកគំរូនៃពលករចំណាកស្រុកដែលទើបត្រលប់មកស្រុកកំណើតវិញកាលពីពេលថ្មីៗនេះ អាចនឹងប៉ាន់ប្រមាណហួសកម្រិតអំពីឆន្ទៈរបស់ពួកគេក្នុងការរាយការណ៍អំពីការរំលោភបំពានដោយសារពួកគេគឺត្រូវបានលុបចេញពីកិច្ចសន្យាពីមុន មិនថា ផ្លូវកាយ និងស្មារតី ដែលយើងអាចនិយាយបានម្យ៉ាងទៀតថា ពួកគេប្រហែលជា "ងាយស្រួលក្នុងការនិយាយ" ថាពួកគេនឹងរាយការណ៍អំពីការរំលោភបំពាន។ ទី២ អ្នកឆ្លើយតបអាចអះអាងថា ពួកគេនឹងរាយការណ៍អំពីការរំលោភបំពាន ប្រសិនបើពួកគេជឿជាក់ថា មន្ត្រីអង្កេតការសម្ភាសន៍ នឹងឯកភាពលើចម្លើយនោះ (ភាពលម្អៀងតាមសង្គម)។ បើយើងសង្កេតទៅលើសេណារីយ៉ូប៉ាន់ប្រមាណវិញ ១០,០២% នៃអ្នកឆ្លើយតប បានរាយការណ៍ថាពិតជាធ្លាប់បានទទួលរង ឬបានសង្កេតឃើញការប្រព្រឹត្តចំពោះដោយមិនស្មើភាពឬខុសច្បាប់ពីសំណាក់និយោជកដែល ៩៨,៣៥% នៃពលករចំណាកស្រុកបាននិយាយថា ពួកគេបានរាយការណ៍អំពីការរំលោភបំពានទាំងនេះទៅកាន់អាជ្ញាធរ។ ភាពមិនស៊ីគ្នារវាងអត្រារងគ្រោះដែលរាយការណ៍ដោយខ្លួនឯង (១០,០២%) និង អត្រារងគ្រោះដែលបានប៉ាន់ប្រមាណដោយប្រើប្រាស់សូចនាកររបស់អង្គការពលកម្មអន្តរជាតិ (ILO) (៣៩,៥៩%) បង្ហាញថា ការរំលោភបំពានពលកម្មដោយបង្ខំកម្រិតមធ្យមមួយចំនួនអាចនឹងពុំទទួលស្គាល់ និងពុំមិនបានរាយការណ៍។ យើងអាចនិយាយបានម្យ៉ាងទៀតថា អ្នកដែលទទួលស្គាល់ថាពួកគេបានជួបប្រទះ ឬបានឃើញការប្រព្រឹត្តរំលោភបំពាន គឺទំនងជាស្ថិតនៅក្រោមប្រភេទនៃការរំលោភបំពានកាន់តែធ្ងន់ធ្ងរ និងអាចនឹងមានការលើកទឹកចិត្តឱ្យធ្វើការរាយការណ៍អំពីបទល្មើសនេះឡើយ។

## អនុសាសន៍

**ការអន្តរាគមន៍ដែលផ្តោតលើភាពងាយរងគ្រោះដែលត្រូវបានលាក់បាំងក្នុងខ្សែសង្វាក់ជ្រើសរើសដោយអ្នកស្គាល់គ្នា។** ចំពោះពលករចំណាកស្រុកកម្ពុជា បណ្តាញជ្រើសរើសពលករសាយភាយបំផុត គឺតាមរយៈគ្រួសារ ឬមិត្តភក្តិក្នុងប្រទេសគោលដៅ។ បណ្តាញក្រៅផ្លូវការនេះ អាចជាអាវុធមុខពីរ។ ទី១ បណ្តាញនេះផ្តល់ភាពងាយស្រួល និងប្រភពដែលអាចទុកចិត្តបានសម្រាប់អ្នកស្វែងរកការងារជាច្រើនដែលកំពុងស្វែងរកការងារធ្វើនៅក្រៅប្រទេស។ ចំណុចមួយទៀត គឺថា បណ្តាញបែបនេះ អាចនាំឱ្យពលករចំណាកស្រុកមានការពិនិត្យពិច័យ និងមានការប្រុងប្រយ័ត្នតិចជាងមុន នៅពេលដែលស្វែងរកជម្រើសការងារ និងសម្រេចចិត្តក្នុងការទទួលយកការងារ។ ស្របពេលមានកម្មវិធីជាច្រើនដែលប្រឆាំងនឹងការជួញដូរកម្លាំងពលកម្មផ្តោតលើអាជ្ញាប័ណ្ណ និងសមត្ថភាពរបស់ទីភ្នាក់ងារ និងមេខ្យល់ជ្រើសរើសពលករ ទិន្នន័យបង្ហាញឱ្យឃើញអំពីភាពងាយរងគ្រោះលាក់កំបាំងដែលអាចពាក់ព័ន្ធនឹងបណ្តាញអ្នកស្គាល់គ្នា។ លើសពីនេះ គ្រួសារ និងមិត្តភក្តិក៏ដើរតួនាទីជាអ្នកផ្តល់កម្ចីចម្បងដល់ពលករចំណាកស្រុកក្នុងការរ៉ាប់រងទៅលើថ្លៃចំណាយនៃការធ្វើចំណាក

ស្រុករបស់ពួកគេផងដែរ។ អ្នកជ្រើសរើសពលករ និងអ្នកផ្តល់កម្ចី ដែលជាមនុស្សតែម្នាក់ គឺធ្វើឱ្យពលករចំណាកស្រុកកាន់តែងាយរងគ្រោះ និងកាន់តែស្មុគស្មាញថែមទៀត។

**ការលើកកម្ពស់ការយល់ដឹងក្នុងចំណោមសហគមន៍ពលករចំណាកស្រុកពាក់ព័ន្ធនឹងសិទ្ធិ ឬច្បាប់។** ទិន្នន័យបង្ហាញឱ្យឃើញអំពីកង្វះការយល់ដឹងក្នុងសហគមន៍ពលករចំណាកស្រុកពាក់ព័ន្ធនឹងសិទ្ធិរស់នៅ សិទ្ធិការងារ និងការការពារផ្លូវច្បាប់ដែលពួកគេមានសិទ្ធិទទួលបាន។ កង្វះខាតព័ត៌មាន ធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការធ្វើចំណាកស្រុកមិនមានសុវត្ថិភាព និងបរិយាកាសការងារដែលមានការរំលោភបំពាន។ ដូច្នេះ ការបង្កើនការយល់ដឹងរបស់ពលករចំណាកស្រុកមុនពេលដែលពួកគេចេញដំណើរទៅបម្រើការងារនៅក្រៅប្រទេស គឺមានសារៈសំខាន់ណាស់។ ឧទាហរណ៍ ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមកិច្ច អាចដាក់ចេញនូវយុទ្ធនាការផ្សព្វផ្សាយអប់រំ និងការចុះផ្តល់ព័ត៌មានតាមមូលដ្ឋានដល់ពលករចំណាកស្រុកទាំងនេះអំពីការងារ កិច្ចសន្យា ហានិភ័យដែលអាចកើតមាន ប្រភេទនៃការកេងប្រវ័ញ្ច ការរំលោភបំពានទូទៅ និងចំណេះដឹង ឬការអនុវត្តជាក់ស្តែងអំពីការការពារសិទ្ធិរបស់ពួកគេ និងការស្វែងរកជំនួយនៅកម្ពុជា ក៏ដូចជានៅប្រទេសគោលដៅផងដែរ។ ខ្លឹមសារនៃយុទ្ធនាការឬការបណ្តុះបណ្តាលនេះ អាចសម្របសម្រួលបន្ថែមទៀតឱ្យសមស្របតាមប្រទេសគោលដៅ យេនឌ័រ ឬវិស័យការងារជាក់លាក់។ នៅពេលដែលពលករចំណាកស្រុកកាន់តែច្រើនមានការយល់ដឹងអំពីសិទ្ធិ និងអត្ថប្រយោជន៍ការងារដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិទាំងនេះ ការយល់ដឹងរួមក៏អាចនាំឱ្យមានការចាត់វិធានការរួម ដើម្បីលើកកម្ពស់ស្ថានភាពចំណាកស្រុកជាទូទៅឱ្យល្អប្រសើរឡើងផងដែរ។

**ការណែនាំច្បាស់លាស់អំពីធនធាន សេវាផ្លូវច្បាប់ និងយន្តការរាយការណ៍។** អ្នកឆ្លើយតបបង្ហាញអំពីការទុកចិត្តកម្រិតខ្ពស់លើប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធនឹងការរាយការណ៍អំពីការអនុវត្ត ឬបរិយាកាសការងារដែលគ្រោះថ្នាក់។ ទោះបីជាមានឆន្ទៈរឹងមាំក្នុងការស្វែងរកជំនួយពីអាជ្ញាធរទាំងនេះក៏ដោយ ក៏ពលករចំណាកស្រុកទាំងនេះនៅពុំទាន់មានការយល់ដឹងច្បាស់លាស់នៅឡើយថាតើមធ្យោបាយ ទីភ្នាក់ងារ ឬនីតិវិធីមួយណាដែលសមស្របបំផុតក្នុងការរាយការណ៍អំពីការរំលោភបំពានដែលអាចកើតមាន និងស្វែងរកការគាំទ្រផ្នែកច្បាប់នោះទេ។ ជាការចាំបាច់ណាស់ ដែលត្រូវផ្តល់សេចក្តីណែនាំផ្នែកគោលនយោបាយ និងយន្តការរាយការណ៍ច្បាស់លាស់ ដើម្បីអាចឱ្យពលករចំណាកស្រុកដឹងអំពីស្ថាប័នជាក់លាក់ (មួយ ឬច្រើន) ណាដែលមានដែនយុត្តាធិការនៅក្នុងកាលៈទេសៈជាក់លាក់។ លើសពីនេះទៅទៀត ទីភ្នាក់ងារ និងស្ថាប័នពាក់ព័ន្ធអាចរៀបចំធនធានគាំទ្រ និងសេវាផ្លូវច្បាប់ដែលមាន ក៏ដូចជាព័ត៌មានអំពីទីតាំងជួយសង្គ្រោះក្នុងករណីមានគ្រោះអាសន្ន និងផ្តល់ព័ត៌មាននេះជូនដល់ពលករចំណាកស្រុក ជាផ្នែកមួយនៃកញ្ចប់ឯកសារតម្រង់ទិសមុនពេលចាកចេញទៅបម្រើការងារនៅក្រៅប្រទេស។

**ការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើភ្នាក់ងារជ្រើសរើសពលករ និងការពង្រីកលទ្ធភាពទទួលបានកម្ចីដែលសមរម្យ។** អ្នកឆ្លើយតបលើសពីពាក់កណ្តាល ចាំបាច់ត្រូវយកកម្ចី ដើម្បីដោះស្រាយលើការធ្វើដំណើររបស់ពួកគេ។ ថ្លៃចំណាយខ្ពស់នៃការធ្វើចំណាកស្រុក មិនថាទាំងក្នុងទម្រង់ជាថ្លៃសេវាជ្រើសរើសការងារ ឬចំណាយផ្សេងៗ ជាផ្នែកមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជិតដល់ និងការអន្តរាគមន៍កាន់តែច្រើនពីសំណាក់រដ្ឋាភិបាល។ មួយវិញទៀត រដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវធ្វើអធិការកិច្ចឱ្យបានជិតដល់លើសេវារបស់ភ្នាក់ងារជ្រើសរើសពលករជាច្រើន និងអនុវត្តច្បាប់ ឬបទប្បញ្ញត្តិឱ្យបានតឹងរ៉ឹង ដើម្បីរារាំងដល់ឥរិយាបថស្វែងរកការការងារខុសប្រក្រតី និងថ្លៃសេវាច្រើនហួសហេតុ។ ម្យ៉ាងវិញទៀត ស្ថាប័នរដ្ឋាភិបាល និងសហគមន៍អាចធ្វើការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីផ្តល់កម្ចីដែលសមរម្យ និងកាល

វិភាគសងប្រាក់សមរម្យដល់ពលករចំណាកស្រុក ដែលមានប្រវត្តិអាចទុកចិត្តបាន។ ការផ្តល់កម្ចីដែលមានការប្រាក់ទាប និងផែនការទូទាត់សងដែលមាននិរន្តរភាព នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារពលករចំណាកស្រុកពីថ្លៃសេវាច្រើនហួសហេតុពីអ្នកផ្តល់កម្ចីឯកជន ឬអន្ទាក់បំណុល ដែលបង្កើនភាពងាយរងគ្រោះរបស់ពួកគេទៅនឹងពលកម្មដោយបង្ខំ។



# ១. សេចក្តីផ្តើម

## សាវតារ និងបរិបទ

ការជួញដូរមនុស្ស ជាប់ពាក់ព័ន្ធនឹងហានិភ័យជាច្រើនស្រទាប់នៅមុនពេល ក្នុងអំឡុងពេល និងភ្លាមៗបន្ទាប់ពីធ្វើចំណាកស្រុក។ ពលករចំណាកស្រុកដែលប្រឈមហានិភ័យអាចនឹងទទួលរងការកេងប្រវ័ញ្ចក្នុងទម្រង់ខុសៗគ្នាក្នុងអំឡុពេលជ្រើសរើស និងចំណាកស្រុក បើធៀបទៅនឹងការកេងប្រវ័ញ្ចនៅប្រទេសគោលដៅរបស់ពួកគេ និងទទួលរងគ្រោះពីហានិភ័យជាច្រើន ដូចជា ការការពារផ្លូវច្បាប់ ការងារ និងសេវាសង្គមកិច្ចពុំគ្រប់គ្រាន់ ដែលបង្កើនភាពងាយរងគ្រោះរបស់ពួកគេទៅនឹងលក្ខខណ្ឌពលកម្មដោយបង្ខំ។ ដំណើរការជ្រើសរើស ចាប់ផ្តើមបង្កហានិភ័យដល់ពលករចំណាកស្រុក ដោយសារតែការអនុវត្តការជ្រើសរើសការងារមិនមានសីលធម៌ ដែលនាំឱ្យធ្លាក់ចូលក្នុងលក្ខខណ្ឌនៃពលកម្មដោយបង្ខំ (Verité. ២០១៩; Bryant & Landman. ២០២០)។ បើទោះបីជាមានការស្រាវជ្រាវអំពីការជួញដូរមនុស្សភាគច្រើនផ្តោតលើហានិភ័យ និងបទពិសោធន៍ទទួលរងការកេងប្រវ័ញ្ចរបស់ពលករចំណាកស្រុកក្នុងប្រទេសគោលដៅរបស់ពួកគេក្តី ក៏មានការយល់ដឹងតិចតួចអំពីហានិភ័យ និងបទពិសោធន៍ទទួលរងការកេងប្រវ័ញ្ចនៅមុនពេល និងក្នុងអំឡុងពេលចំណាកស្រុកផងដែរ។ ឯកសារទ្រឹស្តីលើកឡើងថា ការអន្តរាគមន៍ដែលទទួលស្គាល់ភាពស្មុគស្មាញនៃការជួញដូរកម្លាំងពលកម្មតាមរយៈការដោះស្រាយកត្តាហានិភ័យ ឬការពារឬការផ្តោតលើការផ្លាស់ប្តូរនៅកម្រិតប្រព័ន្ធ (ធៀបនឹងកម្រិតបុគ្គល) គឺទំនងហាក់បីដូចជាមានប្រសិទ្ធភាពជាងគេ (Zimmerman & Kiss. ២០១៧; Bryant & Landman. ២០២០; Fabbri. et al,. ២០២១; Zimmerman. et al,. ២០២១)។ ដូច្នេះ ជាការសំខាន់ណាស់ដែលកម្មវិធីប្រឆាំងការជួញដូរមនុស្សឆ្លងដែនត្រូវស្វែងយល់ទាំងហានិភ័យនិងលំនាំជួញដូរមនុស្សពីប្រទេសដើម និងប្រទេសគោលដៅក្នុងចំណោមពលករចំណាកស្រុក។

> ជាការសំខាន់ណាស់ដែលកម្មវិធីប្រឆាំងការជួញដូរមនុស្សឆ្លងដែនត្រូវមានការស្វែងយល់អំពីទាំងហានិភ័យ និងលំនាំជួញដូរមនុស្សពីប្រទេសដើម និងប្រទេសគោលដៅក្នុងចំណោមពលករចំណាកស្រុក។

## គោលបំណង និងវត្ថុបំណងនៃការសិក្សា

**មជ្ឈមណ្ឌលស្រាវជ្រាវ ណាក** (NORC) បានសហការជាមួយ **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** (IJM) ក្នុងការអនុវត្តការសិក្សាមួយ ដើម្បីធ្វើការប៉ាន់ប្រមាណដាច់ដោយឡែកអំពីកម្រិតវិសាលភាពរងគ្រោះ និងភាពងាយរងគ្រោះនៅប្រទេសកំណើត ដែលជំរុញឱ្យមានការជួញដូរកម្លាំងពលកម្មនៅកម្ពុជា។ ការស្រាវជ្រាវ និងការប៉ាន់ប្រមាណអំពីប្រេវ៉ាឡង់ផ្តោតលើខេត្តចំនួនបួន រួមមានខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងសៀមរាប។ សំណួរស្រាវជ្រាវចម្បង និងសំណួរបន្ទាប់បន្សំជាក់លាក់ គឺមានរៀបរាប់នៅខាងក្រោម។

## សំណួរស្រាវជ្រាវចម្បង

១ តើការប៉ាន់ស្មានកម្រិតទាំងមូលនៃប្រជាជនកម្ពុជាដែលត្រូវបានជួញដូរកម្លាំងពលកម្មឆ្លងដែនប្រចាំឆ្នាំមានកម្រិតប៉ុន្មាន?

២ តើពលករចំណាកស្រុកដែលទើបត្រលប់មកវិញកាលពីថ្មីៗនេះមានចំនួនប៉ុន្មាននាក់ ដែលពួកគេបានពឹងផ្អែកលើ និងមានឆន្ទៈក្នុងការទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ បើពួកគេជួបប្រទះនឹងចំណាកស្រុកការងារដែលមានគ្រោះថ្នាក់?

## សំណួរស្រាវជ្រាវបន្ទាប់បន្សំ

១ តើមានកត្តាហានិភ័យសំខាន់ៗអ្វីខ្លះ ដែលបង្កើនភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជាទៅនឹងការជួញដូរមនុស្សឆ្លងដែន?

២ តើមានមជ្ឈមណ្ឌលសំខាន់ៗ និងបណ្តាញចម្បងអ្វីខ្លះនៃការជួញដូរកម្លាំងពលកម្មចេញពីប្រទេសកម្ពុជា?



វិធីសាស្ត្រពណ៌នាខាងក្រោម ជួយឱ្យអ្នកប្រមូលទិន្នន័យកំណត់អត្តសញ្ញាណ និងស្ទង់មតិសំណាកគំរូតំណាងនៃពលករចំណាកស្រុកដែលទើបត្រលប់មកវិញកាលពីពេលថ្មីៗនៅតាមបណ្តាខេត្តដែលមានអត្រាពលករចំណាកស្រុកកម្រិតខ្ពស់ ស្របពេលដែលកំណត់លំនាំជួញដូរ និងកត្តាហានិភ័យឬការពារសម្រាប់ការរងគ្រោះឆ្លងដែននៅទូទាំងវិស័យជាច្រើន។ លទ្ធផលដែលបានរកឃើញ នឹងរួមបញ្ចូលទិន្នន័យ និងការវិភាគ ដើម្បីផ្តល់ជាព័ត៌មានដល់ការអន្តរាគមន៍ពង្រឹងប្រព័ន្ធយុត្តិធម៌នាពេលអនាគតក្នុងគោលបំណងប្រឆាំងនឹងការជួញដូរកម្លាំងពលកម្មឆ្លងដែន។

# ២. វិធីសាស្ត្រស្រាវជ្រាវ

## វិធីសាស្ត្រប៉ាន់ប្រមាណប្រេវ៉ាឡង់

### ការវាស់វែងការស្ទង់មតិ

ឧបករណ៍ស្ទង់មតិសម្រាប់ការសិក្សានេះ គឺប្រើប្រាស់វិធីសាស្ត្រផ្អែកលើសូចនាករ។ ការសិក្សាកាលពីមុនរបស់មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) ក៏ដូចជាឯកសារស្ទង់មតិដែលមានស្រាប់ក្នុងវិស័យស្រាវជ្រាវអំពីការជួញដូរមនុស្ស បានផ្តល់ជាព័ត៌មានដល់វិធីសាស្ត្រនេះ។ អមជាមួយនឹងកិច្ចការងារស្រដៀងគ្នាដែលសហគមន៍ស្រាវជ្រាវបានអនុវត្តតាមជាទូទៅ ក្រុមការងារបានព្យាយាមអនុវត្តតាមការវាស់ស្ទង់សំខាន់ៗអំពីពលកម្មដោយបង្ខំ ស្របតាមក្របខណ្ឌច្បាប់ដែលបង្កើតឡើងដោយ **អង្គការពលកម្មអន្តរជាតិ** (ILO ឆ្នាំ២០១២)។ ធាតុផ្សំជាក់លាក់នៅក្នុងឧបករណ៍នេះ តំណាងឱ្យធាតុការវាស់ស្ទង់ភាគច្រើន និងប្រហែលជាទាំងអស់ ដែលរកឃើញមានជាទូទៅក្នុងការសិក្សាអំពីប្រេវ៉ាឡង់ដែលបច្ចុប្បន្នមានក្នុងវិស័យនេះ។ ក្រុមការងារអាចនិយាយបានម្យ៉ាងទៀតថា ឧបករណ៍នេះតំណាងឱ្យសូចនាករទូទៅដែលបានឯកភាពភាគច្រើនបំផុតអំពីពលកម្មដោយបង្ខំ ឬសកម្មភាពជួញដូរពលកម្មដែលបច្ចុប្បន្នសហគមន៍ស្រាវជ្រាវប្រើប្រាស់សម្រាប់ប្រធានបទនេះ។

ឧបករណ៍នេះ ត្រូវបានសម្រិតសម្រាំង តាមរយៈការធ្វើតេស្តផ្ទៃក្នុង ការត្រួតពិនិត្យ និងការធ្វើតេស្តការយល់ដឹងរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ជាមួយក្រុមប្រជាជនគោលដៅ ដែលអនុវត្តដោយក្រុមហ៊ុន Chhat Group ជាក្រុមហ៊ុនក្នុងស្រុកដែលទទួលការងារបន្តពីមជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) ដើម្បីគាំទ្រដល់សកម្មភាពប្រមូលទិន្នន័យក្នុងប្រទេសកម្ពុជា។ ក្នុងអំឡុងពេលបណ្តុះបណ្តាល យើងក៏បានស្នើឱ្យមន្ត្រីអង្កេតសម្ភាសន៍ ផ្តល់មតិត្រលប់អំពីរបៀបចាត់ថ្នាក់ឧបករណ៍ ដោយផ្អែកលើបទពិសោធន៍ក្នុងវិស័យរបស់ពួកគេ និងបន្ទាប់ពីការធ្វើតេស្តអនុវត្តសាកល្បង។ ក្រុមការងារបានកែសម្រួលស្ពាន ដោយផ្អែកលើបទពិសោធន៍របស់សិក្ខាកាមនៅក្នុងការអនុវត្តការស្ទង់មតិនៅទីតាំងផ្ទាល់។ ការវាស់ស្ទង់ទាំងនេះ គឺលើកមកពិភាក្សាលម្អិតបន្ថែមនៅក្នុងអនុផ្នែកបន្តបន្ទាប់។ លើសពីនេះ ក្រុមការងារបានអនុវត្តការផ្ទៀងផ្ទាត់ (crosswalk exercise) ដើម្បីធានាថាការវាស់ស្ទង់ក្នុងឧបករណ៍ស្ទង់មតិនេះ និងគាំទ្រដល់ក្របខណ្ឌច្បាប់របស់អង្គការពលកម្មអន្តរជាតិ (ILO)។

ចំពោះការសិក្សានេះ ក្រុមការងារ បានប្រើប្រាស់សូចនាករស្តីពីពលកម្មដោយបង្ខំរបស់ **អង្គការពលកម្មអន្តរជាតិ** ព្រមទាំងបានចាត់ក្រុម និងវិភាគសូចនាករទាំងនេះតាមពីររបៀប។ លើសពីនេះ ក្រុមការងារបានស្នើនូវវិធីសាស្ត្រចម្រោះ "កម្រិតវិសាលភាពគ្រោះថ្នាក់"។

ឧបករណ៍ស្ទង់មតិ រួមបញ្ចូលទិដ្ឋភាពចម្បងៗដូចខាងក្រោម៖ (១) លក្ខណៈសម្បត្តិប្រជាសាស្ត្រ (ឧទាហរណ៍ អាយុ យេនឌ័រ ជនជាតិ និងសមាសភាគគ្រួសារ) (២) ស្ថានភាពបំណុល ដោយសារការសម្រេចចិត្តចំណាកស្រុក (ឧទាហរណ៍ ចំនួនទឹកប្រាក់បំណុល ប្រភពកម្ចី) (៣) ការវាស់ស្ទង់បទពិសោធន៍ការងារនៅកន្លែងធ្វើការ (ឧទាហរណ៍ ប្រភេទការងារ ការងារថែមម៉ោង លក្ខខណ្ឌទូទាត់) និង (៤) ទម្រង់ជា

ច្រើននៃការរំលោភបំពានប្រព្រឹត្តដោយនិយោជក រួមទាំង អំពើហិង្សា ការរឹតត្បិតសេរីភាពផ្លូវកាយឬការប្រាស្រ័យទាក់ទង និងការអនុវត្តដែលមានលក្ខណៈកេងប្រវ័ញ្ច។

## ការវាស់ស្ទង់ពលកម្មដោយបង្ខំ

ចំពោះការសិក្សានេះ ក្រុមការងារបានប្រើប្រាស់សូចនាករស្តីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ ព្រមទាំងបានចាត់ក្រុម និងវិភាគសូចនាការទាំងនេះតាមពីររបៀប។ ទី១ ក្រុមការងារបានបង្ហាញពីសូចនាករទិដ្ឋភាពស្តង់ដារចម្បងរបស់អង្គការពលកម្មអន្តរជាតិ ដែលពិនិត្យទៅលើ "ភាពមិនស្ម័គ្រចិត្ត" និង "ការគំរាមដាក់ទណ្ឌកម្ម" ដើម្បីចាត់ថ្នាក់បុគ្គលណាម្នាក់ក្នុងស្ថានភាពពលកម្មដោយបង្ខំ។ លើសពីនេះ ក្រុមការងារបានស្នើឡើងនូវវិធីសាស្រ្តចម្រុះ "កម្រិតវិសាលភាពនៃគ្រោះថ្នាក់" ដែលក្នុងនោះ ក្រុមការងារបានកំណត់បរិមាណនៃកម្រិតវិសាលភាពនៃគ្រោះថ្នាក់ចំពោះសំណុំសូចនាករនីមួយៗ។ ក្រុមការងារបានរៀបរាប់លម្អិតអំពីលក្ខណៈវិនិច្ឆ័យដូចខាងក្រោម។

### កម្រិតវិសាលភាពនៃគ្រោះថ្នាក់

ដើម្បីសម្របសម្រួលដល់ការវិភាគ និងការបកស្រាយរបកគំហើញនៃការសិក្សានេះ ក្រុមការងារបានចាត់ក្រុមសូចនាករពលកម្មដោយបង្ខំជាច្រើនបន្ថែមទៀតទៅជាប្រភេទនៃការរំលោភបំពានដែលបានកំណត់ ដោយផ្អែកលើការយល់ឃើញអំពីកម្រិតធ្ងន់ធ្ងរនៃការរំលោភសិទ្ធិមនុស្សពីសំណាក់និយោជក។ ការស្រាវជ្រាវពីមុនបានប្រើប្រាស់វិធីសាស្រ្តនេះ ដើម្បីបង្កើតកម្រិតកំណត់នៃការកំណត់ការជួញដូរពលកម្ម ឬ ពលកម្មដោយបង្ខំ ក៏ដូចជាដើម្បីអនុវត្តវិសាលភាពទស្សនាទានដែលយើងអាចគ្រប់គ្រងលើភាពស្មុគស្មាញនៃការជួញដូរមនុស្សបាននៅលើវិសាលភាពនេះ (Zhang. ២០១២; Zhang et al,. ២០១៤)។ ប្រភេទទាំងនេះចាប់ផ្តើមពីកម្រិតធ្ងន់ធ្ងរបំផុត៖

១ បានបំពាន ឬបានគំរាមថានឹងបំពានលើសុចរិតភាពផ្លូវកាយ ឧទាហរណ៍ អំពើហិង្សាផ្លូវកាយ ឬផ្លូវភេទប្រព្រឹត្តទៅលើពលករចំណាកស្រុកឬគ្រួសាររបស់ពួកគេ

២ បានរិតត្បិត ឬបានគំរាមថានឹងរិតត្បិតលើសេរីភាពផ្ទាល់ខ្លួនឬការប្រាស្រ័យទាក់ទង

៣ ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំពលករចំណាកស្រុកការអនុវត្តការងារដែលមានការរំលោភបំពាន និងបង្ខិតបង្ខំ ពលករចំណាកស្រុក ធ្វើអ្វីដែលពួកគេមិនចង់ធ្វើ និង

៤ កិច្ចសន្យាឆបោក ការចាត់ចែងការងារដោយអយុត្តិធម៌ ឬអសុវត្ថិភាព ឬកង្វះខាតស្បៀងអាហារ និងជម្រក។

### គម្រោងពីរជំហាន

បន្ទាប់មក ក្រុមបានអនុវត្តគម្រោងពីរជំហាន ដើម្បីបង្កើតបាននូវដែនកំណត់អំពីការប្រឈមនឹងភាពងាយរងគ្រោះទៅនឹងការជួញដូរមនុស្ស។ នៅត្រង់ចំណុចនេះ យើងវាស់ស្ទង់ចំណាយលើការចាកចេញ "ច្រើនហួសហេតុ" ដែលនិយោជកបានប្រើប្រាស់ ដើម្បីរារាំងឬទប់ស្កាត់ពលករចំណាកស្រុកពីការឈប់ធ្វើការងារ។ មធ្យោបាយនេះរួមមាន ការរឹបអូសប្រាក់ចំណូលដែលរកបាន ទ្រព្យសម្បត្តិមានតម្លៃ ឯកសារអត្តសញ្ញាណ ការបង្ខាំងឬបង្ខូចកេរ្តិ៍ឈ្មោះរបស់ពលករសាមីដោយចេតនាឬការគំរាមរាយការណ៍ទៅអាជ្ញាធរ។ តាមរយៈការប្រើប្រាស់វិធីសាស្រ្តនេះ ពលករចំណាកស្រុកចាំបាច់ត្រូវតែ (១) ធ្លាប់ទទួលរងការរំលោភបំពានក្នុងទម្រង់ណាមួយ ឬការអនុវត្តពុំស្មើភាព និង (២) ពុំអាចឈប់ពីការងារបាន ដោយសារភ័យខ្លាចទទួលរងនូវផលវិបាកធ្ងន់ធ្ងរ។

ស្របពេលដែលការវាស់ស្ទង់របស់ក្រុមការងារបានរួមបញ្ចូលក្នុងការស្ទង់មតិនេះអាចសម្របទៅនឹងការកែសម្រួលក្នុងការកំណត់ក្រុមនៃការរំលោភសិទ្ធិមនុស្ស ក្រុមការងារជឿថាកម្រិតវិសាលភាពនៃគ្រោះថ្នាក់ និងគម្រោងពីរជំហានដូចដែលបានពណ៌នានៅចំណុចនេះផ្តល់ជូននូវភាពងាយស្រួល និងមធ្យោបាយប្រកបដោយសុភវិនិច្ឆ័យ ក្នុងការបង្ហាញអំពីប្រភេទនៃការរំលោភបំពានជាក់លាក់ដែលក្រុមការងារព្យាយាមគាស់កកាយនៅក្រោមក្របខណ្ឌច្បាប់ ដែលមានចែងដោយអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ។ លើសពីនេះ វិសាលភាពដ៏ទូលំទូលាយនៃការវាស់ស្ទង់ទាំងនេះបង្កើនភាពបត់បែនដែលអនុញ្ញាតឱ្យអ្នកស្រាវជ្រាវអាចរៀបចំឡើងវិញនូវសំណួរស្រាវជ្រាវរបស់ខ្លួនក្នុងការវិភាគទិន្នន័យបន្ទាប់បន្សំ។ ដូចបានបង្ហាញពេលក្រោយក្នុងអំឡុងពេលធ្វើបទបង្ហាញអំពីរបកគំហើញ កម្រិតវិសាលភាពនៃគ្រោះថ្នាក់ហាក់បីដូចជាដំណើរការបានយ៉ាងល្អប្រសើរ ស្របតាមសុពលភាពនៃការសិក្សានេះ។ ការយល់ដឹងអំពីភាពធ្ងន់ធ្ងរនៃការរំលោភបំពានកាន់តែច្រើន នាំឱ្យមានជនរងគ្រោះកាន់តែតិច និងច្រាសមកវិញ៖ កម្រិតភាពធ្ងន់ធ្ងរកាន់តែតិច ជនរងគ្រោះមានកាន់តែច្រើន។

# ការជ្រើសសំណាកគំរូ

## វិធីសាស្ត្រជ្រើសសំណាកគំរូ

វិធីសាស្ត្រជ្រើសសំណាកគំរូ ត្រូវបានបង្កើតឡើងដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃផ្តួចផ្តើម ដែលបានប្រមូលធាតុចូលពីពលករចំណាកស្រុកដែលទើបត្រលប់មកវិញកាលពីពេលថ្មីៗ និងបុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដល់ពលករចំណាកស្រុក។ ក្រុមការងារបានប្រើប្រាស់វិធីសាស្ត្រពហុជំហាន ដើម្បីជ្រើសសំណាកគំរូអ្នកឆ្លើយតប។ ទី១ យើងបានជ្រើសរើសខេត្តចំនួន ៤ ដោយមានគោលបំណងច្បាស់លាស់ ដែលក្នុងខេត្តទាំងនោះ ក្រុមការងាររំពឹងថានឹងអាចមានលទ្ធភាពស្វែងរកក្រុមប្រជាជនជាច្រើនដែលជាពលករចំណាកស្រុកទើបតែត្រលប់មកវិញកាលពីពេលថ្មីៗ (ឧទាហរណ៍ ពលករធ្វើការងារនៅក្រៅប្រទេសដែលបានត្រលប់មកកម្ពុជាវិញរយៈពេល ១៨ ខែចុងក្រោយ ឬតិចជាងនេះ គិតចាប់ពីពេលវេលាប្រមូលទិន្នន័យ)។ ខេត្តដែលបានជ្រើសរើសមាន ខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងសៀមរាប។ ខេត្តទាំងនេះ ជាខេត្តស្ថិតក្នុងចំណោមខេត្តដែលមានការលើកឡើងជាញឹកញាប់នៅក្នុងការវាយតម្លៃផ្តួចផ្តើមថាជាទិសដៅសម្រាប់ពលករចំណាកស្រុកដែលទើបត្រលប់មកវិញកាលពីពេលថ្មីៗ។

ទី២ យើងបានប្រើប្រាស់វិធីសាស្ត្រជ្រើសសំណាកគំរូចៃដន្យក្នុងការជ្រើសរើស ៤៨ ភូមិដើម្បីរកអ្នកឆ្លើយតបគំរូ។ បន្ទាប់ពីទទួលបានបញ្ជីស្រុក ឃុំ និងភូមិទាំងអស់នៅក្នុងខេត្តនីមួយៗនៃខេត្តទាំងបួនរួចហើយ យើងបានជ្រើសរើសស្រុកចំនួនប្រាំបីដោយចៃដន្យនៅក្នុងខេត្តនីមួយៗ ឃុំចំនួនបីនៅក្នុងស្រុកនីមួយៗដែលបានជ្រើសរើស និងភូមិចំនួនពីរនៅក្នុងឃុំនីមួយៗដែលបានជ្រើសរើស។ វិធីសាស្ត្រនេះ បានជួយឱ្យយើងទទួលបានសំណាកគំរូតំណាងចៃដន្យពីភូមិនានា ស្របពេលដែលកាត់បន្ថយថ្លៃចំណាយលើការប្រមូលទិន្នន័យ តាមរយៈការកម្រិតលើចំណាយនៃការធ្វើដំណើរដែលត្រូវការជាចាំបាច់។ យើងបានដាក់គោលដៅក្នុងការប្រមូលទិន្នន័យពីអ្នកឆ្លើយតបប្រាំមួយទៅប្រាំពីរនាក់ក្នុងមួយភូមិ ប៉ុន្តែយើងបានកត់សម្គាល់ឃើញថា ភូមិមួយចំនួនដែលបានជ្រើសរើសដោយចៃដន្យ អាចនឹងមិនមានពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះគ្រប់ចំនួនប្រាំមួយនាក់នោះទេ។ ដូច្នេះ យើងបានបង្កើតបញ្ជីភូមិជំនួសចំនួន ៩៥ ភូមិ ដែលអាចជ្រើសសំណាកគំរូបាន ប្រសិនបើចាំបាច់។

ជាចុងក្រោយ នៅពេលដែលអ្នកប្រមូលទិន្នន័យចុះទៅតាមភូមិដែលបានជ្រើសរើស ពួកគេបានដាក់គោលដៅជ្រើសរើសអ្នកឆ្លើយតបចំនួន ៦ ទៅ ៧ នាក់ ក្នុងមួយភូមិឱ្យជួយបម្រើការងារសិក្សានេះ។ នៅក្នុងការវាយតម្លៃផ្តួចផ្តើម យើងបានដឹងថា មេភូមិគឺទទួលបានការទុកចិត្តខ្ពស់ពីសំណាក់ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះ និងត្រូវបានចាត់ទុកថាបានដឹងអំពីប្រជាជននៅក្នុងភូមិរបស់ពួកគាត់។ ដូច្នេះ ពេលអ្នកប្រមូលទិន្នន័យចូលក្នុងភូមិជាលើកដំបូង ពួកគេបានចាប់ផ្តើមតាមរយៈការជជែកជាមួយនឹងមេភូមិ និងសួរនាំពួកគាត់ដើម្បីកំណត់អត្តសញ្ញាណរកពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះនៅក្នុងសហគមន៍។ បញ្ជីនេះបម្រើជាគ្រោងសំណាកគំរូព្រាងសម្រាប់ភូមិ។ មេភូមិបានកំណត់អត្តសញ្ញាណពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះចន្លោះពីសូន្យទៅ ១២ នាក់ក្នុងមួយភូមិ ដោយជាមធ្យមមានប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំនួន ៣នាក់ ក្នុងមួយភូមិ។ ពេលមេភូមិពុំអាចកំណត់អត្តសញ្ញាណពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនាពេលថ្មីៗនេះ អ្នកប្រមូលទិន្នន័យបញ្ជាក់អំពីព័ត៌មាននេះក្រៅផ្លូវការតាមរយៈការជជែកជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ផ្សេងទៀតដែលពួកគេបានជួប និងសួរនាំថាតើពួកគាត់ស្គាល់ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះណាម្នាក់ដែរឬទេ។ ប្រសិនបើបានស្គាល់ អ្នកប្រមូលទិន្នន័យបានបន្ថែមប្រជាពលរដ្ឋក្នុងសហគមន៍ទាំងនេះទៅក្នុងគ្រោងសំណាកគំរូ។ បើពុំស្គាល់ទេ អ្នកប្រមូលទិន្នន័យបានសន្និដ្ឋានថាពុំមានអ្នកចូលរួមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងភូមិ និងបន្តទៅកាន់ភូមិជំនួសដែលបានជ្រើសរើស ដើម្បីជំនួសឱ្យភូមិនេះ។ បើមេភូមិបានកំណត់អត្តសញ្ញាណប្រជាពលរដ្ឋក្នុងសហគមន៍ណាម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកប្រមូលទិន្នន័យបានធ្វើការព្រាងគ្រោងសំណាកគំរូដោយចុះឈ្មោះសមាជិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ។ បន្ទាប់មក ពួកគេបានធ្វើកាជ្រើសរើសដោយចៃដន្យរហូតដល់ ៣នាក់ ក្នុងចំណោមប្រជាពលរដ្ឋក្នុងសហគមន៍ទាំងនេះ ដើម្បីឱ្យជួយបម្រើការងារនៅក្នុងការស្ទង់មតិនេះ។

នៅចុងបញ្ចប់នៃការស្ទង់មតិនីមួយៗ អ្នកឆ្លើយតបនឹងត្រូវបានសួរថាតើពួកគេស្គាល់ និងអាចចែករំលែកព័ត៌មានទំនាក់ទំនងរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ណាម្នាក់ផ្សេងទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងភូមិដែរឬទេ។ ការសួរបែបនេះ គឺមានគោលបំណងត្រួតពិនិត្យទៅលើភាពពេញលេញនៃគ្រោងសំណាកគំរូដែលបានបង្កើតឡើងពីព័ត៌មានដែលបានពីមេភូមិ។ បើអ្នកឆ្លើយតបបានកំណត់អត្តសញ្ញាណប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលពុំមានក្នុងគ្រោងសំណាកគំរូ អ្នកប្រមូលទិន្នន័យបន្ថែមប្រជាជនទាំងនេះទៅក្នុងគ្រោងសំណាកគំរូ និងធ្វើការជ្រើសរើសអ្នកចូលរួមដោយចៃដន្យរហូតដល់ ៣នាក់ ពីសមាជិកដែលបានបន្ថែមថ្មី។ ការធ្វើបែបនេះធានាថា ប្រជាជនដែលមេភូមិពុំស្គាល់ ដែលអាចនឹងមានភាពខុសគ្នាជាប្រព័ន្ធពីប្រជាជនដែលមេភូមិស្គាល់នោះទេ ពោលគឺពុំត្រូវបានផាត់ចេញពីការស្ទង់មតិឡើយ។ នៅទូទាំងភូមិទាំងអស់ អ្នកឆ្លើយតបបានបន្ថែមប្រជាពលរដ្ឋក្នុងសហគមន៍ចន្លោះពី ០ ទៅ៤ នាក់ទៅក្នុងគ្រោងសំណាកគំរូ។ ចំនួនមធ្យមនៃប្រជាពលរដ្ឋក្នុងសហគមន៍ដែលបានបន្ថែមទៅក្នុងគ្រោងសំណាកគំរូ គឺមានតិចជាងមួយ (០,៦) នាក់ក្នុងមួយភូមិ ដែលបង្ហាញថា បញ្ជីរបស់មេភូមិជាទូទៅ គឺពេញលេញ។ ទោះជាយ៉ាងនេះក្តីមាន ៦ភូមិ ដែលក្នុងនោះអ្នកឆ្លើយតបបានកំណត់អត្តសញ្ញាណប្រជាពលរដ្ឋក្នុងសហគមន៍មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងចំនួនស្មើគ្នា ឬច្រើនជាងបញ្ជីរបស់មេភូមិ។ សម្រាប់ព័ត៌មានលម្អិតអំពីចំនួនប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានជ្រើសរើសជាសំណាកគំរូតាមស្រុក ក៏ដូចជាចំនួនឃុំ និងភូមិដែលបានចុះប្រមូលទិន្នន័យ សូមមើលតារាង ១១ នៃឧបសម្ព័ន្ធ I. នីតិវិធីជ្រើសសំណាកគំរូ និងការប៉ាន់ប្រមាណប្រជាជន។

# ការរៀបចំប្រមូលទិន្នន័យ

## ការវិភាគផ្តួចផ្តើម

ការវាយតម្លៃផ្តួចផ្តើម ជាការស្រាវជ្រាវអភិវឌ្ឍន៍ដែលបានធ្វើឡើងនៅក្នុងការរៀបចំសម្រាប់ការសិក្សាមួយដែលអនុវត្តវិធីសាស្ត្រថ្មី និង/ឬពឹងផ្អែកលើការសន្មតមុខងារ និងការវិភាគដែលមិនទាន់បានធ្វើតេស្តសាកល្បង។[១] គោលបំណងនៃការវាយតម្លៃផ្តួចផ្តើមនេះ គឺដើម្បីធ្វើសុពលកម្មលើការរៀបចំការស្រាវជ្រាវដែលបានស្នើឡើង ក៏ដូចជាប្រមូលធាតុចូលសំខាន់ៗ ដែលត្រូវការចាំបាច់សម្រាប់ការស្ទង់មតិ ភស្តុភារកម្ម និងការរៀបចំផែនការ។ ដោយសារតែយុទ្ធសាស្ត្រប៉ាន់ប្រមាណអំពីការតាមដានទំនាក់ទំនងដែលបានស្នើឡើង នៅក្រោមការវិភាគអំពីពលកម្មដោយបង្ខំឆ្លងដែននៅកម្ពុជា នៅពុំទាន់បានអនុវត្តជាមួយក្រុមប្រជាជន និងអ្នកឆ្លើយតបគោលដៅនៅឡើយ ការវាយតម្លៃផ្តួចផ្តើមគឺត្រូវបានអនុវត្តកាលពីខែធ្នូ ឆ្នាំ២០២១ រហូតដល់ខែមីនា ឆ្នាំ២០២២ ដើម្បីធ្វើតេស្តសាកល្បងការសន្មតសំខាន់ៗដែលបានផុសឡើងក្នុងអំឡុងពេលនៃដំណាក់កាលរៀបចំការស្រាវជ្រាវ។

សកម្មភាពវាយតម្លៃផ្តួចផ្តើម គឺទទួលបានព័ត៌មានពីរបាយការណ៍រៀបចំការស្រាវជ្រាវ ការត្រួតពិនិត្យឯកសារ និងកិច្ចប្រជុំឬកិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រុមហ៊ុន Chhat Group។

សកម្មភាពចុះទីតាំងផ្ទាល់ គឺត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងពាក់ព័ន្ធនឹងឯកសារគោលបំណងនៃការវាយតម្លៃផ្តួចផ្តើមដែលគូសបញ្ជាក់អំពីធាតុផ្សំ និងប៉ារ៉ាម៉ែត្រសំខាន់ៗពីឯកសាររៀបចំការស្រាវជ្រាវ ដែលតម្រូវឱ្យមានការអង្កេតតាមដានបន្ថែម។ គោលបំណងទាំងនេះរួមមានការវាយតម្លៃទៅលើ៖

- វិសាលភាពដែលអ្នកឆ្លើយតបគោលដៅអាចមានលទ្ធភាព និងមានឆន្ទៈក្នុងការជជែកជាមួយនឹងក្រុមការងារស្រាវជ្រាវ ផ្តល់ទិន្នន័យសុក្រឹតអំពីខ្លួនពួកគេ និងណែនាំបុគ្គលដែលពួកគេស្គាល់ឱ្យចូលរួមក្នុងការសិក្សានេះ
- សមត្ថភាពនៃខ្សែសង្វាក់បញ្ជូនតាមបណ្តាញ ដើម្បីពង្រីកវិសាលភាពទៅដល់អ្នកឆ្លើយតបលាក់កំបាំង ឬពិបាកទៅដល់ជាពិសេស
- ធាតុចូលគណនាទំហំសំណាកគំរូ រួមទាំងចំនួន និងលក្ខណៈសម្បត្តិនៃចំនួនរាប់ឬអត្រាចូលរួមជាក់ស្តែង និងរំពឹងទុក និង
- ការសន្មតសមហេតុផលពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ រួមទាំង បែបបទ ការជ្រើសសំណាកគំរូ ការជ្រើសសំណាកគំរូចម្បង និងបន្ទាប់បន្សំ ទីតាំង និងធាតុចូលថវិកា។

វិធីសាស្ត្រសម្រាប់ការដោះស្រាយចំណុចខាងលើរួមមាន៖

- សម្ភាសន៍ព័ត៌មានជាមួយភាគីពាក់ព័ន្ធ រួមទាំងជំនាញការក្នុងវិស័យ និងអង្គការមិនមែនរដ្ឋាភិបាល និង
- កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) និងសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ (semi-structured) ជាមួយអ្នកឆ្លើយតបគោលដៅ។

ក្រុមហ៊ុន Chhat Group បានកំណត់អត្តសញ្ញាណ និងបានជ្រើសរើសអ្នកចូលរួមសម្រាប់កិច្ចពិភាក្សាក្រុមគោលដៅដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមមាន៖ បុរស និងស្ត្រីដែលជាពលករចំណាកស្រុកទើបត្រលប់មកវិញ អាយុ ១៨ ឆ្នាំឡើង

ទៅ។ កិច្ចពិភាក្សាក្រុមគោលដៅមួយបានរួមបញ្ចូលបុរសដែលធ្លាប់បានធ្វើការនៅឧស្សាហកម្មនេសាទ មួយទៀតបានរួមបញ្ចូលបុរសដែលធ្លាប់បានធ្វើការនៅក្នុងឧស្សាហកម្មណាមួយ និងមួយទៀតបានរួមបញ្ចូលស្ត្រីដែលធ្លាប់បានធ្វើការងារនៅក្នុងឧស្សាហកម្មណាមួយ។ កិច្ចពិភាក្សាក្រុមគោលដៅ មានរយៈពេលប្រហែល ២២ ម៉ោង។ សម្ភាសន៍ផ្តល់ព័ត៌មានត្រូវបានធ្វើឡើងដោយប្រើប្រាស់វេទិកាអនឡាញ (Zoom) ឬសម្ភាសន៍ផ្ទាល់ជាមួយអ្នកតំណាងមកពីអង្គការអាដហុក អង្គការសង់ត្រាល់ អង្គការសម្ព័ន្ធចាប់ដៃ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) អង្គការ រតនៈ និងអង្គការ Winrock។ របកគំហើញពីការវាយតម្លៃផ្តួចផ្តើម បានផ្តល់ជាព័ត៌មានសម្រាប់វិធីសាស្ត្រស្រាវជ្រាវស្ថាពរ យុទ្ធសាស្ត្រជ្រើសសំណាកគំរូ និងការរៀបចំឧបករណ៍ ក៏ដូចជាសំណាងសម្រាប់អ្នកឆ្លើយតបផងដែរ។ អ្នកឆ្លើយតបបានទទួលប្រាក់ចំនួន ៨០០០ រៀលសម្រាប់ការចូលរួមនៅក្នុងការវាយតម្លៃអំពីពលកម្មដោយបង្ខំ និង ៨០០០ រៀលសម្រាប់អ្នកឆ្លើយតបម្នាក់ៗដែលបានជ្រើសរើសដោយជោគជ័យក្នុងការសិក្សានេះ។

## សកម្មភាពប្រមូលទិន្នន័យ

សកម្មភាពប្រមូលទិន្នន័យ រួមមាន ការស្ទង់មតិអំពីប្រេវ៉ាឡង់នៃពលកម្មដោយបង្ខំឆ្លងដែន ដែលធ្វើឡើងនៅក្នុងខេត្តចំនួនបួននៅប្រទេសកម្ពុជា (ខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និង សៀមរាប)។ សកម្មភាពគាំទ្ររួមមាន អ្នកត្រួតពិនិត្យត្រូវកំណត់អំពីលក្ខណៈសម្បត្តិរបស់អ្នកឆ្លើយតបសក្តានុពលក្នុងការចូលរួមនៅក្នុងការសិក្សា (ឧទាហរណ៍ វាយតម្លៃថាតើពួកគាត់សមស្របទៅនឹងលក្ខណៈវិនិច្ឆ័យរួមបញ្ចូលដែរឬទេ)។ ឧបករណ៍ប្រមូលទិន្នន័យសម្រាប់ការស្ទង់មតិគឺត្រូវបានរៀបចំជារចនាសម្ព័ន្ធពាក់ព័ន្ធនឹងនិយមន័យស្ថិតិអំពីពលកម្មដោយបង្ខំ ដែលបានប្រើប្រាស់ដោយការិយាល័យតាមដានត្រួតពិនិត្យ និងប្រឆាំងការជួញដូរមនុស្ស (TIP) នៃក្រសួងការបរទេសសហរដ្ឋអាមេរិក អង្គការពលកម្មអន្តរជាតិ រដ្ឋាភិបាលនៃប្រទេសកម្ពុជា ព្រមទាំងត្រូវបានសម្រិតសម្រាំងដោយមានការពិគ្រោះយោបល់ជាមួយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងនៅក្នុងអំឡុងពេលនៃការវាយតម្លៃផ្តួចផ្តើមផងដែរ។ ប៉ារ៉ាម៉ែត្រលម្អិតអំពីឧបករណ៍ប្រមូលទិន្នន័យ រួមទាំង វិធីសាស្ត្រជ្រើសសំណាកគំរូ រយៈពេលប៉ាន់ប្រមាណនៃការទំនាក់ទំនងជាមួយអ្នកឆ្លើយតប និងប្រធានបទដែលត្រូវលើកឡើង គឺមានបញ្ជាក់នៅក្នុងតារាង ១១។

*តារាង ១៖ សកម្មភាពប្រមូលទិន្នន័យ និងប៉ារ៉ាម៉ែត្រ*

| សកម្មភាព | ការស្ទង់មតិអំពីប្រេវ៉ាឡង់នៃពលកម្មដោយបង្ខំឆ្លងដែន | អ្នកត្រួតពិនិត្យតាមទូរស័ព្ទ |
|---|---|---|
| សំណាកគំរូគោលដៅ | ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះចំនួន ១២០០ ១.២០០ នាក់ នៅក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងសៀមរាប | អ្នកចូលរួមក្នុងការសិក្សាសក្តានុពលទាំងអស់ |
| ការជ្រើសរើស ឬវិធីសាស្ត្រជ្រើសសំណាកគំរូ | ការជ្រើសសំណាកគំរូជាចង្កោមចៃដន្យនៅក្នុងភូមិ ការសម្ភាសន៍មេភូមិ ដើម្បីបង្កើតគ្រោងសំណាកគំរូភូមិ ការបន្ថែមទៅក្នុងគ្រោងសំណាកគំរូនូវព័ត៌មានដែលប្រមូលបានពីអ្នកឆ្លើយតប | ការជ្រើសរើសដោយចៃដន្យពីគ្រោងសំណាកគំរូភូមិ |
| រយៈពេលប៉ាន់ប្រមាណ | ៦០ នាទី | ១០ នាទី |
| គោលបំណង | វាយតម្លៃស្ថានភាពពលកម្មដោយបង្ខំ និងឆន្ទៈក្នុងការពឹងពាក់លើប្រព័ន្ធយុត្តិធម៌ | កំណត់លក្ខណៈសម្បត្តិក្នុងការចូលរួមនៅក្នុងការសិក្សា |
| ប្រធានបទស្ទង់មតិ | • ព័ត៌មានប្រជាសាស្ត្រ<br>• ព័ត៌មានលម្អិតទូទៅអំពីការងារថ្មីៗបំផុតនៅក្រៅប្រទេសកម្ពុជា<br>• ការវាយតម្លៃសូចនាករស្តីពីពលកម្មដោយបង្ខំ៖ លក្ខខណ្ឌរស់នៅ ការជ្រើសរើសការងារមិនស្មើភាព លក្ខខណ្ឌធ្វើការ និងការងារ (ការងារ និងជីវិតស្ថិតក្រោមការបង្ខិតបង្ខំ) សេរីភាពនៃការធ្វើដំណើរ និងលទ្ធភាពនៃការឈប់ធ្វើការងារឱ្យនិយោជកដោយពុំមានហានិភ័យ<br>• ការបំភិតបំភ័យជាមធ្យោបាយនៃការបង្ខិតបង្ខំ<br>• បទពិសោធន៍កន្លងមកអំពីការទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌<br>• ឆន្ទៈប៉ាន់ប្រមាណក្នុងការទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌<br>• ចំណេះដឹងអំពីប្រជាពលរដ្ឋក្នុងសហគមន៍ផ្សេងទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | • អាយុ<br>• ប្រទេសស្នាក់នៅបច្ចុប្បន្ន<br>• ប្រទេសគោលដៅចំណាកស្រុក<br>• រយៈពេលត្រលប់មកវិញ<br>• ការពិចារណាជាក់លាក់អំពីវិធាននៃការសិក្សា |

## ការបណ្តុះបណ្តាល និងការចុះទីតាំង

ចំពោះការប្រមូលទិន្នន័យ មជ្ឈមណ្ឌលស្រាវជ្រាវ ណរក បានផ្តល់ការងារបន្តទៅឱ្យក្រុមហ៊ុន Chhat Group ដែលជាក្រុមហ៊ុនប្រមូលទិន្នន័យ ស្រាវជ្រាវ និងពិគ្រោះយោបល់ក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន Chhat Group គឺត្រូវបានជ្រើសរើស ដោយផ្អែកលើបទពិសោធន៍របស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងសកម្មភាពប្រមូលទិន្នន័យនៅក្នុងប្រទេសកម្ពុជា សមត្ថភាពក្នុងការជ្រើសរើសអ្នកសម្ភាសន៍ដែលមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងចំនួនច្រើន ការបង្ហាញជាភស្តុតាងអំពីជំនាញនៅក្នុងការគ្រប់គ្រងការស្រាវជ្រាវវិធីសាស្ត្រចម្រុះ បទពិសោធន៍ក្នុងការប្រើប្រាស់កុំព្យូទ័រសម្រាប់ការប្រមូលទិន្នន័យ លទ្ធផលកន្លងមកអំពីការអនុវត្តលំហាត់ដែលមានវិសាលភាព និងកម្រិតស្រដៀងគ្នា និងផ្តល់នូវគុណតម្លៃសមនឹងការចំណាយ។

### ◢ ការបណ្តុះបណ្តាលអ្នកសម្ភាសន៍ និងការអនុវត្តសាកល្បង

មជ្ឈមណ្ឌលស្រាវជ្រាវ ណរក (NORC) បានរៀបចំការបណ្តុះបណ្តាលគ្រូបង្គោលជាភាសាអង់គ្លេសរយៈពេល ២ថ្ងៃ ជាមួយក្រុមថ្នាក់ដឹកនាំស្នូលរបស់ក្រុមហ៊ុន Chhat Group ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២២ ដល់ ២៣ ខែឧសភា ឆ្នាំ២០២២។ បន្ទាប់ពីការបណ្តុះបណ្តាលនេះ ក្រុមថ្នាក់ដឹកនាំស្នូល បានរៀបចំការបណ្តុះបណ្តាលជាភាសាខ្មែររយៈពេលប្រាំពីរថ្ងៃ និងបានធ្វើតេស្តអនុវត្តសាកល្បងជាមួយមន្ត្រីអង្កេតការសម្ភាសន៍។ ការបណ្តុះបណ្តាលនេះ គឺផ្តោតលើការតម្រង់ទិសអ្នកចូលរួមនៅក្នុងការសិក្សា នីតិវិធីប្រមូលទិន្នន័យ ការជ្រើសសំណាកគំរូ ភស្តុភារ ការត្រួតពិនិត្យអ្នកឆ្លើយតប ការចុះស្ទង់មតិ និងការអនុវត្តការស្រាវជ្រាវដែលគិតគូរលើការប៉ះទង្គិចផ្លូវចិត្ត។ លើសពីនេះ ការបណ្តុះបណ្តាលទាំងពីរបានរួមបញ្ចូល "ការត្រួតពិនិត្យឯកសារ (lab review)" នៃការស្ទង់មតិ។ គោលបំណងនៃការត្រួតពិនិត្យឯកសារ គឺដើម្បីដកស្រង់នូវបទពិសោធន៍ស្រាវជ្រាវដ៏ទូលំទូលាយរបស់អ្នកចូលរួមនៅក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹង និងភាពសមស្របតាមបរិបទនៃសំណួរស្ទង់មតិ ធានាបាននូវជម្រើសឆ្លើយតបច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងមានលក្ខណៈពិសេសតាមបុគ្គល និងកំណត់រកនូវការណែនាំបន្ថែមដែលអ្នកសម្ភាសន៍អាចនឹងត្រូវការចាំបាច់ ដើម្បីជួយពួកគេក្នុងការបញ្ជាក់ ឬស្ទាបស្ទង់អំពីអ្នកឆ្លើយតប ក្នុងករណីដែលសំណួរមានលក្ខណៈមិនច្បាស់លាស់។ ការបណ្តុះបណ្តាលមន្ត្រីអង្កេតការសម្ភាសន៍ ក៏បានរួមបញ្ចូលនៅក្នុងការសាកល្បងនៅទីតាំងផ្ទាល់នៃឧបករណ៍ស្ទង់មតិផងដែរ។

ឧបករណ៍ស្ទង់មតិ គឺត្រូវបានធ្វើបច្ចុប្បន្នភាពដោយផ្អែកលើការត្រួតពិនិត្យឯកសារ និងបានចុះអនុវត្តសាកល្បងនៅទីតាំងជាមួយនឹងពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះក្នុងខេត្តគោលដៅ ប៉ុន្តែស្ថិតនៅក្រៅភូមិគោលដៅ។ ការធ្វើតេស្តសាកល្បងនៅទីតាំងផ្ទាល់ មានគោលបំណងវាយតម្លៃថាតើអ្នកឆ្លើយតបជួបការលំបាកក្នុងការស្វែងយល់ដឹង ឬរំពឹងដែរឬទេ កំណត់ថាតើឧបករណ៍ឬវិធីសាស្ត្រមួយណាដែលមានប្រយោជន៍ក្នុងការលើកកម្ពស់ការយល់និងការរំពឹក កំណត់ថាតើសំណួរណាមួយស្ថិតក្រោមការឆ្លើយតបលម្អៀង ឬត្រូវបានយល់ថាមានលក្ខណៈរសើបខ្លាំងពេកចំពោះអ្នកឆ្លើយតប និងកំណត់ថាតើមានបញ្ហា ឬបញ្ហាប្រឈមណាមួយផ្សេងទៀតដែលមិនបានដឹងមុនដែរឬទេ។ បន្ទាប់ពីការធ្វើតេស្តសាកល្បងនៅទីតាំងផ្ទាល់ មជ្ឈមណ្ឌលស្រាវជ្រាវ ណរក និងក្រុមហ៊ុន Chhat Group បានរៀបចំវគ្គផ្តល់ព័ត៌មានបន្ថែមជាមួយនឹងមន្ត្រីអង្កេតការសម្ភាសន៍ ដើម្បីកំណត់រកការកែសម្រួលស្ថាពរចាំបាច់ណាមួយចំពោះឧបករណ៍មុនពេលការបណ្តុះបណ្តាលចម្បង។

បន្ទាប់ពីការបណ្តុះបណ្តាល អ្នកសម្ភាសន៍ ២២ នាក់ ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការងារនៅទីតាំងផ្ទាល់។ ការជ្រើសរើសគឺផ្អែកលើវត្តមាន និងការចូលរួមក្នុងការបណ្តុះបណ្តាល លទ្ធផលអនុវត្តសាកល្បង និងវិញ្ញាសាសរសេរ។ បន្ទាប់មក ក្រុមត្រូវបានជ្រើសរើសធ្វើដំណើរទៅខេត្តចាត់តាំងដើម្បីប្រមូលទិន្នន័យក្នុងចន្លោះថ្ងៃទី១១ ខែមិថុនា ដល់ថ្ងៃទី ១១ ខែកក្កដា។

## ◢ ការធានាគុណភាពទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើងដោយប្រើប្រាស់កុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី SurveyCTO ឬឧបករណ៍ប្រមូលទិន្នន័យបើកចំហ (ODK)។ កម្មវិធីស្ទង់មតិ គឺត្រូវបានរៀបចំឡើងនៅក្នុងស្ថាប័នដោយ មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) និងវេទិកាឬប្រព័ន្ធប្រមូលទិន្នន័យ គឺត្រូវបានគ្រប់គ្រងជាចម្បងដោយក្រុមស្រាវជ្រាវ។ គ្រប់កុំព្យូទ័រ និងសឺវើទាំងអស់ គឺត្រូវបានធ្វើកូដនីយកម្ម ដើម្បីធានាបាននូវសុវត្ថិភាពទិន្នន័យកម្រិតអតិបរិមា។ ទិន្នន័យត្រូវបានទាញចូលក្នុងសឺវើជាប្រចាំថ្ងៃ (ដោយអនុញ្ញាតឱ្យតភ្ជាប់) ដើម្បីអនុញ្ញាតឱ្យមានការត្រួតពិនិត្យគុណភាពទិន្នន័យជាក់ស្តែងភ្លាមៗ។

ពិធីសារនៃការធានាគុណភាពទិន្នន័យ (DQA) គឺត្រូវបានបង្កើតឡើង ដើម្បីកំណត់អំពីបទដ្ឋានឬលក្ខខណ្ឌតម្រូវគុណភាពទិន្នន័យ និងសមាជិកក្រុមទទួលខុសត្រូវក្នុងការធានាឱ្យបាននូវគុណភាពទិន្នន័យខ្ពស់ក្នុងអំឡុងពេលបំពេញការងារនៅទីតាំងផ្ទាល់។ ការត្រួតពិនិត្យគុណភាពទិន្នន័យ (DQRs) គឺត្រូវបានអនុវត្តដោយក្រុមគ្រប់គ្រងទិន្នន័យរបស់ មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) នៅចន្លោះពេលទៀងទាត់នៅពេញមួយរយៈពេលនៃការប្រមូលទិន្នន័យ។ DQR គឺមានគោលបំណងកំណត់រកជាមុន និងដោះស្រាយនូវរាល់បញ្ហានានាពាក់ព័ន្ធនឹងការរៀបចំកម្មវិធីស្ទង់មតិ ភាពច្បាស់លាស់នៃសំណួរ និងកំហុសឬការអនុវត្តការងាររបស់មន្ត្រីអង្កេតសម្ភាសន៍។

## ◢ សីលធម៌នៃការស្រាវជ្រាវ និងការអនុញ្ញាតដល់ការសិក្សា

ការសិក្សានេះ ត្រូវបានរៀបចំឡើងស្របតាមគោលការណ៍ណែនាំស្តីពីការស្រាវជ្រាវលើមនុស្ស ទាំងក្នុងសហរដ្ឋអាមេរិក និងនៅកម្ពុជា។ មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) អនុវត្តតាមពិធីសារដែលបានបង្កើតឡើងសម្រាប់ការប្រមូលការយល់ព្រមដែលមានការព័ត៌មានគ្រប់គ្រាន់ ការការពារអនាមិកភាព និងការកំណត់អត្តសញ្ញាណព័ត៌មាន ព្រមទាំងធានាបាននូវការប្រមូលទិន្នន័យប្រកដោយសីលធម៌ — រួមទាំងការប្រមូលទិន្នន័យពីក្រុមប្រជាជនងាយរងគ្រោះផងដែរ។ ដើម្បីធានាបាននូវអនុលោមភាពតាមបទដ្ឋានសីលធម៌កម្រិតខ្ពស់ រាល់ការស្រាវជ្រាវទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រជាជនងាយរងគ្រោះ ចាំបាច់ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (IRB) ជាមុនសិនមុននឹងចុះប្រមូលទិន្នន័យ និងគ្រប់បុគ្គលិកស្រាវជ្រាវទាំងអស់ ត្រូវតែបញ្ចប់វគ្គសិក្សាដែលមានបញ្ជាក់ដោយវិញ្ញាបនបត្រអំពីការការពារអ្នកចូលរួមក្នុងការស្រាវជ្រាវ តាមរយៈ វិទ្យាស្ថានជាតិសុខាភិបាល (NIH) ឬ គំនិតផ្តួចផ្តើមបណ្តុះបណ្តាលស្ថាប័ន និងការសហការ (CITI)។

ក្រុមការងារចុះទីតាំង គឺបានទទួលការបណ្តុះបណ្តាលយ៉ាងពេញលេញអំពីក្រមសីលធម៌នៃការស្រាវជ្រាវ រួមទាំងនីតិវិធីរក្សាព័ត៌មានសម្ងាត់ និង ការយល់ព្រមដែលមានការព័ត៌មានគ្រប់គ្រាន់ផងដែរ។ ការយល់ព្រមឬការអនុញ្ញាត គឺត្រូវបានទទួលតាមពាក្យសម្តីពីអ្នកចូលរួមនៅក្នុងការសិក្សា ហើយអ្នកឆ្លើយតបទាំងអស់បានទទួលសន្លឹកព័ត៌មានអំពីការយល់ព្រមឬការសិក្សាដែលបានបោះពុម្ព ដែលចុះហត្ថលេខាឬបញ្ជាក់ដោយមន្ត្រីអង្កេតការសម្ភាសន៍ ក្នុងគោលបំណងរក្សាទុកជាកំណត់ត្រា។ មជ្ឈមណ្ឌលស្រាវជ្រាវ ណក (NORC) ក៏បានផ្តល់ជូនអ្នកសម្ភាសន៍នូវការបណ្តុះបណ្តាលផ្នែកលើវិបទអំពីការសង្គ្រោះផ្លូវចិត្តបឋម និងការស្រាវជ្រាវគិតគូរលើការប៉ះទង្គិចផ្លូវចិត្តផងដែរ។

មជ្ឈមណ្ឌលស្រាវជ្រាវ ណក បានស្នើសុំ និងបានទទួលការអនុម័តពីក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (IRB) ផ្ទៃក្នុងរបស់ខ្លួនដែលអនុវត្តតាមដំណើរការផ្លូវការមួយ សម្រាប់ការធានាឱ្យបានថារាល់គម្រោងស្រាវជ្រាវទាំងអស់ គឺត្រូវបានអនុវត្តស្របតាមគោលនយោបាយសហព័ន្ធស្តីពីការការពារមនុស្សជាកម្មវត្ថុនៃការស្រាវជ្រាវរបស់សហរដ្ឋអាមេរិក។ ក្រុមប្រឹក្សាត្រួត

ពិនិត្យស្ថាប័នរបស់ មជ្ឈមណ្ឌលស្រាវជ្រាវ ណាក គឺបានចុះបញ្ជីនៅក្រសួងសុខាភិបាល និងការិយាល័យសេវាប្រជាជនសម្រាប់ការការពារការស្រាវជ្រាវលើមនុស្សរបស់សហរដ្ឋអាមេរិក (ការធានាទូទាំងសហព័ន្ធ FWA ០០០០០១៩២)។ រដ្ឋាភិបាលកម្ពុជា មិនមានគោលនយោបាយផ្លូវការណាមួយឡើយ ពាក់ព័ន្ធនឹងការអនុម័តលើការស្រាវជ្រាវអំពីឥរិយាបថសង្គម។ ទោះជាយ៉ាងនេះក្តី អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានធ្វើការត្រួតពិនិត្យលើពិធីសារសីលធម៌របស់ការសិក្សានេះរួចរាល់ហើយ។ ក្នុងអំឡុងពេលនៃការវាយតម្លៃផ្តួចផ្តើម មជ្ឈមណ្ឌលស្រាវជ្រាវ ណាក ក៏បានស្វែងរកធាតុចូលពីអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់ពលករចំណាកស្រុកក្នុងមូលដ្ឋាន អំពីពិធីសារសីលធម៌នៃការសិក្សានេះផងដែរ រួមមានការលើកទឹកចិត្ត ហានិភ័យ និងការយល់ដឹងអំពីហានិភ័យដែលអ្នកឆ្លើយតបអាចនឹងជួបប្រទះ ព្រមទាំងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យដែលបានណែនាំផងដែរ។

## ដែនកំណត់នៃការសិក្សា

ស្របពេលក្រុមការងារមានទំនុកចិត្តលើរបកគំហើញនៃការសិក្សា និងភាពជាប់ទាក់ទិននៃរបកគំហើញទាំងនោះក៏ដោយ ក៏មានដែនកំណត់មួយចំនួនដែលនឹងបង្កជាបញ្ហាប្រឈមចំពោះការបកស្រាយរបកគំហើញនៃការសិក្សានេះផងដែរ។

### ការប៉ាន់ប្រមាណអំពីពលកម្មដោយបង្ខំ អនុវត្តតែចំពោះការងារថ្មីៗបំផុតរបស់ "ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះ"

ដែនកំណត់សំខាន់មួយនៃការរចនាដែលបានស្នើឡើងគឺថា ចំនួនពលករដែលរងពលកម្មដោយបង្ខំ នឹងធ្វើការឆ្លុះបញ្ចាំងតែអំពីបទពិសោធន៍របស់ពលករចំណាកស្រុក ដែលទើបតែត្រលប់មកពីទីតាំងទិសដៅកាលពីពេលថ្មីៗប៉ុណ្ណោះ (ឧទាហរណ៍ រយៈពេល ១៨ ខែ ឬតិចជាងនេះមុនពេលការសិក្សា)។ បទពិសោធន៍របស់ពលករចំណាកស្រុកក្នុងស្ថានភាពពលកម្មដោយបង្ខំ ដែលមានកម្រិតកំណត់ហួសហេតុលើសេរីភាព ដែលពុំមានលទ្ធភាពត្រលប់មកប្រទេសកម្ពុជាវិញ នឹងពុំរួមបញ្ចូលក្នុងការសិក្សានេះឡើយ។ លើសពីនេះ ពលករដែលត្រលប់មកវិញម្នាក់ៗ នឹងត្រូវបានសួរតែអំពីបទពិសោធន៍ការងារថ្មីបំផុតរបស់ពួកគេប៉ុណ្ណោះ ដែលនៅក្នុងការងារនោះ ពួកគេអាចនឹងធ្លាប់បានបម្រើការងារសម្រាប់រយៈពេលខ្លី ឬរយៈពេលវែងប៉ុណ្ណោះ។ ប្រសិនបើអ្នកឆ្លើយតបបានធ្វើចំណាកស្រុកលើសពីម្តងក្នុងរយៈពេល ១៨ ខែចុងក្រោយ និងរាយការណ៍ថា ពួកគាត់មិនធ្លាប់ជួបប្រទះនឹងពលកម្មដោយបង្ខំឬការជួញដូរពលកម្មនៅក្នុងការងារចុងក្រោយរបស់គាត់ទេ នោះមិនមែនមានន័យថាគាត់មិនធ្លាប់ជួបប្រទះនឹងពលកម្មដោយបង្ខំឬការជួញដូរពលកម្មក្នុងរយៈពេល ១៨ ខែចុងក្រោយឡើយ។

### ប្រជាជនដែលបានផាត់ចេញពីវិសាលភាពនៃសកម្មភាពប្រមូលទិន្នន័យ

បុគ្គលដែលអាចនឹងមានការលំបាកខ្លាំងបំផុតក្នុងការទៅដល់ អាចរួមមាន ឧទាហរណ៍ ១) ពលករត្រលប់មកវិញដែលពុំបានបញ្ចេញព័ត៌មាន ឬពុំមានបំណងបញ្ចេញព័ត៌មានថាត្រូវបានគេបោកបញ្ឆោត ឬបោកប្រាក់ដោយខ្លាចត្រូវបានគេមាក់ងាយ ឬមានអារម្មណ៍ខ្មាសគេ និង ២) បុគ្គលខ្លាចការធ្វើទុក្ខបុកម្នេញពីសំណាក់អ្នកជួញដូរឬអ្នកជ្រើសរើសពលករក្នុងមូលដ្ឋាន។ បុគ្គលត្រូវបានគេកេងប្រវ័ញ្ចជាពិសេសក្នុងវិស័យពលកម្មពុំប្រក្រតី ដូចជាការងារបម្រើផ្លូវភេទ សុំទាន ឬការឆក់ប្លន់ក៏អាចនឹងមានការលំបាកក្នុងការចុះទៅដល់ និងទទួលបានការបញ្ចេញព័ត៌មាន ឬការផ្តល់ទំនាក់ទំនងផងដែរ។

## គោលការណ៍ណែនាំអំពីជំងឺកូវីដ-១៩ មានឥទ្ធិពលលើការធ្វើដំណើរឆ្លងដែនរបស់ពលករចំណាកស្រុក

ការចុះទៅដល់ពលករដែលត្រលប់មកវិញ អាចនឹងរងការប៉ះពាល់ពីគោលការណ៍ណែនាំដែលមានការប្រែប្រួល ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័កឬការដាក់ឱ្យនៅដាច់ដោយឡែក នៅពេលត្រលប់ចូលមកក្នុងប្រទេសកម្ពុជាវិញ។ លើសពីនេះ នៅក្នុងរយៈពេល ១៨ ខែចុងក្រោយ គោលការណ៍ណែនាំស្តីពីជំងឺកូវីដ-១៩ មានឥទ្ធិពលជាថ្មីម្តងទៀតលើសមត្ថភាពរបស់ប្រជាជនក្នុងការធ្វើចំណាកស្រុកទៅធ្វើការ ឬត្រលប់មកផ្ទះវិញពីចំណាកស្រុកក្រៅប្រទេស។ ជាលទ្ធផល ក្រុមប្រជាជនគោលដៅមូលដ្ឋាន — ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះ—អាចនឹងមិនមែនជាអ្នកតំណាងឱ្យក្រុមប្រជាជនដែលបានកំណត់សម្រាប់ការសិក្សានោះទេ ហើយអត្រាប្រេវ៉ាឡង់អំពីពលកម្មដោយបង្ខំ ដែលបានប៉ាន់ប្រមាណនៅពេលនេះ អាចនឹងមិនអាចយកមកប្រៀបធៀបបានឡើយ ជាមួយនឹងការប៉ាន់ប្រមាណដែលធ្វើឡើងនាពេលអនាគត នៅពេលដែលការរីករាលដាលនៃជំងឺផុតរលត់ទៅវិញ។





# ៣. របកគំហើញ

## លក្ខណៈសម្បត្តិប្រជាសាស្ត្រ

ដូចដែលបានបង្ហាញក្នុងតារាង ២ បំណែងចែកយេនឌ័រដែលមានទំនោរទៅរកខាងស្ត្រី ដោយមានស្ត្រី (៦០,១៣%) ច្រើនជាងបុរស (៣៩,៨៧%)។ ពហុភាគនៃសំណាកគំរូ គឺ ៣១-៤៥ ឆ្នាំ (៤០,១២%) និងប្រហែលជា ១/៤ នៃសំណាកគំរូស្ថិតនៅក្នុងចន្លោះអាយុមួយក្នុងចំណោមចន្លោះអាយុទាំងពីរខាងក្រោម៖ ១៨-៣០ ឆ្នាំ (២៦,៩៩%) និង ៤១-៥០ ឆ្នាំ (២៥,៥០%)។ ៧,៣៩% នៃសំណាកគំរូ គឺមានអាយុ ៥០ ឆ្នាំឡើងទៅ។

*តារាង ២៖ ប្រជាសាស្ត្ររបស់អ្នកឆ្លើយតប (ផលធៀប)*

| សំណាកគំរូសរុប | | N** វិជ្ជមាន | ស្ថិតិគំរូ* |
|---|---|---|---|
| ភេទ | ប្រុស | ៤៨០ | ៣៩,៨៧% |
| | ស្រី | ៧២៤ | ៦០,១៣% |
| អាយុ | ១៨ – ៣០ | ៣២៥ | ២៦,៩៩% |
| | ៣១ – ៤០ | ៤៨៣ | ៤០,១២% |
| | ៤១ – ៥០ | ៣០៧ | ២៥,៥០% |
| | ៥០+ | ៨៩ | ៧,៣៩% |
| ជនជាតិ | ខ្មែរ | ១១៨២ | ៩៨,១៧% |
| | ផ្សេងៗ | ២២ | ១,៨៣% |
| កម្រិតវប្បធម៌ | មិនបានចូលរៀនផ្លូវការ | ៩៤ | ៧,៨១% |
| | មិនបានបញ្ចប់បឋមសិក្សា | ៥៥៣ | ៤៥,៩៣% |
| | បានបញ្ចប់បឋមសិក្សា | ១៥៨ | ១៣,១២% |
| | មិនបានបញ្ចប់មធ្យមសិក្សា | ២៤៦ | ២០,៤៣% |
| | បានបញ្ចប់មធ្យមសិក្សា | ១២៥ | ១០,៣៨% |
| | មិនបានបញ្ចប់វិទ្យាល័យ/ការអប់រំវិជ្ជាជីវៈ | ១៩ | ១,៥៨% |
| | បានបញ្ចប់វិទ្យាល័យ/ការអប់រំវិជ្ជាជីវៈ | ៩ | ០,៧៥% |

| ខេត្ត | | បន្ទាយមានជ័យ | កំពង់ចាម | ព្រៃវែង | សៀមរាប |
|---|---|---|---|---|---|
| ភេទ | ប្រុស | ១០៣ | ១៥១ | ១២២ | ១០៤ |
| | ស្រី | ១៩៧ | ១៥០ | ១៧៨ | ១៩៩ |
| អាយុ | ១៨ – ៣០ | ៨៦ | ៦៩ | ៦៦ | ១០៤ |
| | ៣១ – ៤០ | ១៣៥ | ១២២ | ១១៧ | ១០៩ |
| | ៤១ – ៥០ | ៦០ | ៨៥ | ៩១ | ៧១ |
| | ៥០+ | ១៩ | ២៥ | ២៦ | ១៩ |

| ខេត្ត | | បន្ទាយមានជ័យ | កំពង់ចាម | ព្រៃវែង | សៀមរាប |
|---|---|---|---|---|---|
| ជនជាតិ | ខ្មែរ | ២៩៩ | ២៨១ | ៣០០ | ៣០២ |
| | ផ្សេងៗ | ១ | ២០ | ០ | ១ |
| កម្រិតវប្បធម៌ | មិនបានចូលរៀនផ្លូវការ | ២៧ | ២០ | ១៨ | ២៩ |
| | មិនបានបញ្ចប់បឋមសិក្សា | ១២៦ | ១០៨ | ១៣២ | ១៨៧ |
| | បានបញ្ចប់បឋមសិក្សា | ៤៩ | ៣៩ | ៣៨ | ៣២ |
| | មិនបានបញ្ចប់មធ្យមសិក្សា | ៥៧ | ៨៤ | ៧០ | ៣៥ |
| | បានបញ្ចប់មធ្យមសិក្សា | ៣៥ | ៣៤ | ៣៩ | ១៧ |
| | មិនបានបញ្ចប់វិទ្យាល័យ/ការអប់រំវិជ្ជាជីវៈ | ៣ | ១២ | ២ | ២ |
| | បានបញ្ចប់វិទ្យាល័យ/ការអប់រំវិជ្ជាជីវៈ | ៣ | ៤ | ១ | ១ |

*សម្គាល់៖ *ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤); **ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ។*

បើគិតតាមជនជាតិ ៩៨% នៃអ្នកឆ្លើយតប បានកំណត់អត្តសញ្ញាណជាជនជាតិខ្មែរ។ អ្នកឆ្លើយតបមិនមែនជាជនជាតិខ្មែរស្ទើរតែទាំងអស់ គឺមកពីខេត្តកំពង់ចាម។ ពាក់ព័ន្ធនឹងកម្រិតវប្បធម៌ ពលករចំណាកស្រុកជាងពាក់កណ្តាលបានទទួលការអប់រំក្រៅផ្លូវការ ឬការអប់រំថ្នាក់បឋមសិក្សាមិនបានចប់។ មួយចំណែកនៃអ្នកឆ្លើយតបដែលមិនមានការអប់រំ ឬមានការអប់រំនៅថ្នាក់បឋមសិក្សាមិនបានពេញលេញ គឺមានចំណែកខ្ពស់ជាងគេនៅក្នុងខេត្តសៀមរាប ពោលគឺមាន ៧១%។ អ្នកដែលបានបញ្ចប់ការអប់រំនៅមធ្យមសិក្សា មានចំនួន ១០% នៃសំណាកគំរូ និងអ្នកដែលមិនកម្រិតសញ្ញាបត្រថ្នាក់វិទ្យាល័យ ឬអប់រំវិជ្ជាជីវៈ គឺមានតែ ២% ប៉ុណ្ណោះ។



## លក្ខណៈសម្បត្តិការងារ

ដូចដែលបានបង្ហាញក្នុងរូបភាព ២ ទិសដៅការងារលេចធ្លោរជាងគេសម្រាប់ពលករចំណាកស្រុកកម្ពុជាដែលបានកំណត់យកជាសំណាកគំរូ គឺប្រទេសថៃ (៨៨%)។ ទោះជាយ៉ាងនេះក្តី មួយចំណែកតូចនៃពលករ គឺបានបម្រើការងារនៅក្នុងសាធារណរដ្ឋកូរ៉េ (៦%) ឬប្រទេសម៉ាឡេស៊ី (៣%)។ ចំពោះប្រភេទការងារវិញ សំណង់ និង រោងចក្រគឺមានចំណែកធំបំផុតនៃការងារទាំងអស់ដែលបានរាយការណ៍ (៣២% រៀងគ្នា) បន្ទាប់មកគឺកសិកម្ម (១៧%) សេវាកម្ម (៧%) នេសាទ (៤%) និងការងារតាមផ្ទះ (៣%)។ ការបែងចែកនៃវិស័យការងារនៅក្នុងក្រុមយេនឌ័រនីមួយៗ នៅក្នុងឧស្សាហកម្មពេញនិយមបំផុត ដូចជាសំណង់ (៣០% បុរស និង ៣៤% ស្ត្រី) រោងចក្រ(៣៥% បុរស និង ៣០% ស្ត្រី) កសិកម្ម (១៥% បុរស និង ១៨% ស្ត្រី) និងសេវាកម្ម (៦% បុរស និង ៨% ស្ត្រី)។

*រូបភាព ២៖ ប្រទេសដែលធ្វើការ និងឧស្សាហកម្មការងាររបស់អ្នកឆ្លើយតប*







*សម្គាល់៖ ប្រភេទនានាត្រូវបានបញ្ចូល តែនៅពេលដែលមានការរាយការណ៍ដោយអ្នកឆ្លើយតបយ៉ាងហោចណាស់ ២ ភាគរយនៃអ្នកឆ្លើយតបសរុបប៉ុណ្ណោះ ចំពោះប្រភេទទាំងអស់ផ្សេងទៀត គឺត្រូវបញ្ចូលគ្នាតែមួយជាមួយប្រភេទផ្សេងទៀត។*

*តារាង ៣៖ ឧស្សាហកម្មការងាររបស់អ្នកឆ្លើយតប (តាមយេនឌ័រ)*

| | អ្នកឆ្លើយតបបុរស (n = ៨៨០) | អ្នកឆ្លើយតបស្ត្រី (n = ៧២៤) |
|---|---|---|
| សំណង់ | ១៩៥ | ២៤៦ |
| រោងចក្រ | ១៦៧ | ២៤៦ |
| កសិកម្ម | ៧២ | ១៣៣ |
| សេវាកម្ម | ២៧ | ៥៧ |
| នេសាទ (នៅលើទូក) | ៤១ | ៧ |
| ការងារតាមផ្ទះ | ៥ | ៣៥ |
| ផ្សេងៗ | ១៥ | ១៤ |
| កែច្នៃគ្រឿងសមុទ្រ | ៨ | ១៤ |

*សម្គាល់៖ ប្រភេទនានាគឺរួមបញ្ចូល តែនៅពេលដែលមានការរាយការណ៍ដោយអ្នកឆ្លើយតបយ៉ាងហោចណាស់ ២ ភាគរយនៃអ្នកឆ្លើយតបសរុបប៉ុណ្ណោះ ចំពោះប្រភេទទាំងអស់ផ្សេងទៀត គឺត្រូវរួមបញ្ចូលគ្នាតែមួយជាមួយប្រភេទផ្សេងទៀត។*

ដូចបានបង្ហាញក្នុងតារាង ៤ ពលករចំណាកស្រុកកម្ពុជាភាគច្រើន ទទួលបានទិដ្ឋាការការងារសម្រាប់ប្រទេសទៅបម្រើការងាររបស់ពួកគេ ដែលមានចំនួនជិត ៨០,៧៣% នៃសំណាកគំរូ បន្ទាប់មកពលករមួយចំនួនតូចបានទទួលទិដ្ឋាការទេសចរ (៤,២៤%) និងទិដ្ឋាការសិស្ស (០,៨៣%)។ អ្នកឆ្លើយតបមួយភាគតូច បានធ្វើការដោយមិនមានទិដ្ឋាការ ឬស្ថិតក្រោមលក្ខខណ្ឌមិនមានឯកសារផ្សេងទៀត (១៣,៦២%)។

អ្នកឆ្លើយតបបានរាយការណ៍អំពីយុទ្ធសាស្ត្រជាច្រើនសម្រាប់ការទទួលបានការងារនៅក្នុងប្រទេសគោលដៅ។ អ្នកឆ្លើយតបស្ទើរតែពាក់កណ្តាល (៤៣,៨៥%) បានរាយការណ៍ថា ពួកគាត់មានសមាជិកគ្រួសារដែលកំពុងរស់នៅក្នុងប្រទេសគោលដៅស្រាប់ហើយ។ នៅពេលបូកសរុបភាគរយនៃអ្នកឆ្លើយតបដែលមានមិត្តភក្តិរស់នៅក្នុងប្រទេសគោលដៅស្រាប់ (២២,០១%) អ្នកឆ្លើយតបភាគច្រើន (៦៥,៨៦%) បានទទួលការងារតាមបណ្តាញសង្គម។ បណ្តាញជ្រើសរើសពលករផ្សេងទៀត រួមមាន ទីភ្នាក់ងារជ្រើសរើសពលករផ្តល់ការងារផ្លូវការដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាល (១១,២១%) ឬការស្វែងរកការងារដោយខ្លួនឯង (១០,១៣%)។ ម្តងម្កាល អ្នកឆ្លើយតបបានទទួលឱកាសការងារតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ដែលពុំស្គាល់អំពីស្ថានភាពចុះបញ្ជី (៣,១៦%) ទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលមិនបានចុះបញ្ជីជាមួយរដ្ឋាភិបាល (២,៨២%) មេខ្យល់ឯកជន ឬអ្នករត់ពន្ធមនុស្ស (២,០៨%) ឬ បុគ្គលដែលមានទំនាក់ទំនងជាមួយការជ្រើសរើសការងារនៅក្នុងប្រទេសគោលដៅ (១,៨៣%)។

**អ្នកឆ្លើយតបបានរាយការណ៍អំពីយុទ្ធសាស្ត្រជាច្រើនសម្រាប់ការទទួលបានការងារនៅក្នុងប្រទេសទិសដៅ។**

**អ្នកឆ្លើយតបស្ទើរតែពាក់កណ្ដាល (៤៣.៨៥%) បានលើកឡើងថាពួកគាត់មានសមាជិកគ្រួសារដែលកំពុងរស់នៅក្នុងប្រទេសទិសដៅស្រាប់។**

១/៤ នៃសំណាកគំរូ ពោលគឺ ២៥,០៨% បានបង់កម្រៃសេវាដើម្បីរក្សាការងារក្នុងប្រទេសគោលដៅ ដែលពាក់កណ្ដាល (៥០,៥៨%) នៃអ្នកឆ្លើយតប ចាំបាច់ត្រូវយកកម្ចីដើម្បីទូទាត់កម្រៃសេវាទាំងនោះ។ ចំពោះប្រភពនៃប្រាក់កម្ចីវិញ មិត្តភក្តិ និងសមាជិកគ្រួសារ គឺជាប្រភពផ្តល់កម្ចីធំបំផុត ដែលស្មើនឹង ៤០,៩៥% នៃអ្នកដែលយកកម្ចី បន្ទាប់មកគឺធនាគារ (៣០,៧៦%) និងនិយោជក (១៨,០៩%)។ ជាទូទៅ កម្រណាស់ដែលពលករចំណាកស្រុកខ្ចីប្រាក់ដោយផ្ទាល់ពីមេខ្យល់ឯកជន (មានត្រឹមតែ ៥,៤៣% ប៉ុណ្ណោះ)។

ចំនួនទឹកប្រាក់ជាមធ្យមនៃកម្រៃសេវាជ្រើសរើសពលករដែលបានបង់ ដើម្បីរក្សាបានការងារនៅក្នុងប្រទេសគោលដៅ គឺមានចំនួន ១.៦៤២.៥២០ រៀល (KHR) ឬប្រហែល ៤០១ ដុល្លារអាមេរិក និងមានចន្លោះទាបបំផុតពី ២០.០០០ រៀល (ប្រហែល ៥០ ដុល្លារអាមេរិក) ទៅ ៣០.០០០.០០០ រៀល (ប្រហែល ៧.៣១៧ ដុល្លារអាមេរិក) ដែលបង្ហាញអំពីភាពខុសគ្នាយ៉ាងខ្លាំងលើស្ថានភាពផ្ទាល់ខ្លួន។ សំណាកគំរូ ៤,៨២% ពុំច្បាស់ថាតើការទូទាត់សរុបដែលពួកគេបានបង់ជូនដល់អ្នកជ្រើសរើសពលករ រួមបញ្ចូលថ្លៃចំណាយផ្សេងៗក្រៅពីកម្រៃសេវាជ្រើសរើសពលករ ឬមួយយ៉ាងណានោះទេ។ ដូច្នេះ យើងបានធ្វើការគណនាជាច់ដោយឡែកជាមធ្យម និងចន្លោះនៃថ្លៃសេវាដែលបានរាយការណ៍។ ដូចការរំពឹងទុក ចំនួនទឹកប្រាក់ជាមធ្យម គឺខ្ពស់ជាង (៣.៨៥៣.១៩០ រៀល ឬប្រហែល ៩៤០ ដុល្លារអាមេរិក) ប៉ុន្តែចន្លោះនេះ គឺមានលក្ខណៈស្របគ្នា ដោយមានចន្លោះពី ៣០.០០០ រៀល (ប្រហែល ៧០៧ ដុល្លារអាមេរិក) ទៅ ២៨.៧០០.០០០ រៀល (ប្រហែល ៧០០០ ដុល្លារអាមេរិក)។ ជាចុងក្រោយ យើងបានរកឃើញថា ចំនួនទឹកប្រាក់កម្ចីជាមធ្យមដែលពលករចំណាកស្រុកបានខ្ចី គឺមានចំនួនច្រើនជាង (៣.៦៦៦.៨២៧ រៀល ឬប្រហែល ៨៩០ ដុល្លារអាមេរិក) កម្រៃជាមធ្យមដែលបានបង់ដើម្បីទទួលបានការងារ។ ចំនួនទឹកប្រាក់ដែលបានខ្ចីតាមពលករចំណាកស្រុកម្នាក់ៗ ក៏មានភាពខុសគ្នាខ្លាំងផងដែរ ដោយមានចន្លោះពី ៣០.០០០ រៀល (ប្រហែល ៧០៧ដុល្លារអាមេរិក) ដល់ ១២០.០០០.០០០ រៀល (ប្រហែល ២៩.២៦៨ ដុល្លារអាមេរិក)។

**យើងបានរកឃើញថា ចំនួនទឹកប្រាក់កម្ចីជាមធ្យមដែលពលករចំណាកស្រុកបានខ្ចី គឺមានចំនួនខ្ពស់ជាងកម្រៃជាមធ្យមដែលបានបង់ដើម្បីទទួលបានការងារ។**

*តារាង ៩៖ លក្ខណៈសម្បត្តិការងារ*

| | | N** វិជ្ជមាន | ស្ថិតិគំរូ* |
|---|---|---|---|
| ប្រភេទទិដ្ឋាការ | សិស្ស | ១០ | ០,៨៣% |
| | ធ្វើការ | ៩៧២ | ៨០,៧៣% |
| | ទេសចរ | ៥១ | ៤,២៤% |
| | ខ្ញុំបានធ្វើការដោយមិនមានទិដ្ឋាការ | ១៦៤ | ១៣,៦២% |
| | ផ្សេងៗ | ៧ | ០,៥៨% |
| របៀបទទួលបានការងារ | មានសមាជិកគ្រួសារនៅក្នុងប្រទេសគោលដៅស្រាប់ | ៥២៨ | ៤៣,៨៥% |

| តារាង ៤៖ លក្ខណៈសម្បត្តិការងារ | | | N** វិជ្ជមាន | ស្ថិតិគំរូ* |
|---|---|---|---|---|
| | | មានមិត្តភក្តិនៅក្នុងប្រទេសគោលដៅស្រាប់ | ២៦៥ | ២២,០១% |
| | | ទីភ្នាក់ងារជ្រើសរើសពលករផ្តល់ការងារផ្លូវការដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាល | ១៣៥ | ១១,២១% |
| | | ទីភ្នាក់ងារជ្រើសរើសពលករឯកជន (មិនបានចុះបញ្ជីជាមួយរដ្ឋាភិបាល) | ៣៤ | ២,៨២% |
| | | ទីភ្នាក់ងារជ្រើសរើសពលករ (អ្នកឆ្លើយតបមិនច្បាស់ថាបាន ឬមិនបានចុះបញ្ជី) | ៣៨ | ៣,១៦% |
| | | បុគ្គលដែលមានទំនាក់ទំនងជាមួយការជ្រើសរើសការងារនៅក្នុងប្រទេសគោលដៅ | ២២ | ១,៨៣% |
| | | ខ្ញុំរកការងារបានដោយខ្លួនឯង | ១២២ | ១០,១៣% |
| | | មេខ្យល់ឯកជនឬអ្នករត់ពន្ធមនុស្ស | ២៥ | ២,០៨% |
| | | ផ្សេងៗ | ៣៥ | ២,៩១% |
| | | បង់កម្រៃដើម្បីទទួលបានការងារ | ៣០២ | ២៥,០៨% |
| | | យកកម្ចី | ៦០៩ | ៥០,៥៨% |
| ប្រភពនៃកម្ចីដែលបានយក | | **និយោជក** | ១១០ | ១៨,០៩% |
| ប្រភពនៃកម្ចីដែលបានយក | | **មេខ្យល់ឯកជន** | ៣៣ | ៥,៤៣% |
| ប្រភពនៃកម្ចីដែលបានយក | | **មិត្តភក្តិ/សមាជិកគ្រួសារ** | ២៤៩ | ៤០,៩៥% |
| ប្រភពនៃកម្ចីដែលបានយក | | **ធនាគារ** | ១៨៧ | ៣០,៧៦% |
| ប្រភពនៃកម្ចីដែលបានយក | | **ផ្សេងៗ** | ២៩ | ៤,៧៧% |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | តម្លៃជ្រើសរើស ការងារប៉ុណ្ណោះ៖ | **មធ្យម** | ១.៦៤២.៥២០,០០ | |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | តម្លៃជ្រើសរើស ការងារប៉ុណ្ណោះ៖ | **គម្លាតស្តង់ដារ** | ៣.៨៩៧.៧៦៦,០០ | |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | តម្លៃជ្រើសរើស ការងារប៉ុណ្ណោះ៖ | **ចន្លោះ** | ២០.០០០,០០ | ៣០.០០០.០០០,០០ |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | អត្រាសរុប (អាច ឬមិនអាច រួមបញ្ចូលចំណាយផ្សេងៗ) | **មធ្យម** | ៣.៨៥៣.១៩០,០០ | |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | អត្រាសរុប (អាច ឬមិនអាច រួមបញ្ចូលចំណាយផ្សេងៗ) | **គម្លាតស្តង់ដារ** | ៥.៧៣៩.៩១៣,០០ | |
| បង់កម្រៃសេវាដើម្បីទទួលបានការងារ ជាប្រាក់រៀលខ្មែរ (KHR) | អត្រាសរុប (អាច ឬមិនអាច រួមបញ្ចូលចំណាយផ្សេងៗ) | **ចន្លោះ** | ៣០.០០០,០០ | ២៨.៧០០.០០០,០០ |
| ចំនួនទឹកប្រាក់កម្ចីគិតជាប្រាក់រៀលខ្មែរ (KHR) | | **មធ្យម** | ៣.៦៦៦.៨២៧,០០ | |
| ចំនួនទឹកប្រាក់កម្ចីគិតជាប្រាក់រៀលខ្មែរ (KHR) | | **គម្លាតស្តង់ដារ** | ៧.៥៣៨.៤២៧,០០ | |
| ចំនួនទឹកប្រាក់កម្ចីគិតជាប្រាក់រៀលខ្មែរ (KHR) | | **ចន្លោះ** | ៣០.០០០,០០ | ១២០.០០០.០០០,០០ |

*សម្គាល់៖ *ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤); **ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ។*

# លំនាំនៃការរំលោភបំពានពលកម្មដោយបង្ខំ

## ◢ បានប្រព្រឹត្ត ឬបានគំរាមថានឹងប្រព្រឹត្តអំពើហិង្សាផ្លូវកាយ/ផ្លូវភេទ

ស្ថិតិសង្ខេបទាំងអស់ដែលបានបង្ហាញនៅក្នុងផ្នែកខាងក្រោមនេះ គឺបានថ្លឹងថ្លែងជាមធ្យម ដោយប្រើប្រាស់ការថ្លឹងថ្លែងគំរូ ដែលមានពណ៌នានៅក្នុង ឧបសម្ព័ន្ធ I. នីតិវិធីជ្រើសសំណាកគំរូ និងការប៉ាន់ប្រមាណប្រមាណប្រជាជន។

ដូចដែលបានបង្ហាញនៅក្នុងតារាង ៥ យើងបានរកឃើញថា អំពើហិង្សាផ្លូវកាយជាក់ស្តែង ឬដែលបានគំរាមក្នុងចំណោមពលករចំណាកស្រុកកម្ពុជា នៅក្នុងប្រទេសគោលដៅ គឺកម្រិតត្រឹម៖ ១៣,៦១% នៃអ្នកឆ្លើយតប បានលើកឡើង ថាធ្លាប់បានជួបប្រទះអំពើហិង្សាផ្លូវកាយជាក់ស្តែង ឬដែលបានគំរាមកំហែងប្រព្រឹត្តដោយនិយោជករបស់ពួកគេ ឬបុគ្គលដែលធ្វើការឱ្យនិយោជករបស់ពួកគេ។

អ្នកឆ្លើយតបក្នុងចំនួនស្មើគ្នាបានរាយការណ៍ថា និយោជករបស់ពួកគេបានគំរាម ឬបានប្រព្រឹត្ត ឬប្រព្រឹត្តដោយផ្ទាល់នូវអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទមកលើពួកគេ ដើម្បីឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ (១៣,៥៩%)។

យើងប៉ាន់ប្រមាណប្រមាណថា ប្រេវ៉ាឡង់នៃនិយោជកដែលបានគេធ្វើបាប ឬគំរាមកំហែងធ្វើបាបដល់គ្រួសាររបស់និយោជិត ដើម្បីឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ គឺស្មើនឹង ០,៤១%។ យើងរកឃើញថា ការភ័យខ្លាចចំពោះផលវិបាកមកលើផ្លូវកាយ ប្រសិនបើពួកគាត់ឈប់ពីការងារមុនពេលកិច្ចសន្យាផុតសុពលភាព គឺកម្រកើតមានណាស់ (០,០៤%)។

*តារាង ៥៖ ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| និយោជកបានគំរាមកំហែង ឬបានប្រព្រឹត្តអំពើហិង្សាលើផ្លូវកាយ ឬផ្លូវភេទមកលើអ្នក ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកពុំចង់ធ្វើ។ | ១៦៣ | ១៣,៥៤% | ១៣,៥៩% | ១១,១៥% | ១៦,០៤% |
| អំពើហិង្សាអាចនឹងកើតឡើងចំពោះពលករចំណាកស្រុក ប្រសិនបើពួកគេហ៊ានឈប់ពីការងារមុនពេលកិច្ចសន្យាផុតសុពលភាព។ | ២ | ០,១៧% | ០,០៤% | -០,០២% | ០,១០% |
| និយោជកបានធ្វើបាបគ្រួសាររបស់អ្នក ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកពុំចង់ធ្វើ ឬបានគំរាមកំហែងអ្នកឱ្យធ្វើកិច្ចការនោះ។ | ៧ | ០,៥៨% | ០,៤១% | ០,០៤% | ០,៧៩% |
| **ណាមួយខាងលើ** | **១៦៤** | **១៣,៦២%** | **១៣,៦១%** | **១១,១៧%** | **១៦,០៦%** |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*

## ◢ ការរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរ/ការប្រាស្រ័យទាក់ទង

តារាង ៦ បង្ហាញអំពីការប៉ាន់ប្រមាណប្រមាណលើការរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរ/ការប្រាស្រ័យទាក់ទង។ យើងរកឃើញថា អ្នកឆ្លើយតបតិចជាងពាក់កណ្តាល ពោលគឺ ៣៩,៦៧% ធ្លាប់បានជួបប្រទះទម្រង់មួយនៃការរំលោភបំពានយ៉ាងហោចណាស់មួយដង។ ទូទៅបំផុត គឺជាការរាយការណ៍ពីអ្នកឆ្លើយតបដែលរស់នៅក្នុងផ្ទះដែលនិយោជកផ្តល់ជូន ដែលពួកគេមិនត្រូវបានអនុញ្ញាតឱ្យទៅរស់នៅកន្លែងផ្សេងក្រៅពីផ្ទះដែលនិយោជកផ្តល់ជូន និងរក្សាការងាររបស់ពួកគេ (២៥,១៤%) ឬការលើកឡើង ថា និយោជកពុំអនុញ្ញាតឱ្យនិយោជិតធ្វើដំណើរដោយសេរីក្នុងសហាគមន៍បន្ទាប់ពីចប់វេនការងារ (១៦,៦០%)។ អ្នកឆ្លើយតប ៧,០៨% បានរាយការណ៍ថា និយោជករបស់ពួកគេដកទុកឯកសារអត្តសញ្ញាណរបស់ពួកគេ ដើម្បីឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ។ អ្វីដែលកើតឡើងពុំសូវទូទៅក្នុងចំណោមពលករចំណាកស្រុកកម្ពុជា គឺការរាយការណ៍អំពីនិយោជកដកហូតសេរីភាពរបស់ពួកគេក្នុងការធ្វើដំណើរ/ប្រាស្រ័យទាក់ទង ឬទុកពួកគេចោលនៅកន្លែងដាច់ស្រយាល ប្រសិនបើពួកគេឈប់ពីការងារមិនចប់កិច្ចសន្យា (៤,២៣%) និយោជក ឬអ្នកជ្រើសរើសពលករដកទុកឯកសារអត្តសញ្ញាណ (៣,៣២%) និងនិយោជកប្រើប្រាស់ ឬគំរាមកំហែងប្រើប្រាស់ការដាក់ឱ្យនៅដាច់ដោយឡែកតែម្នាក់ឯង ការបង្ខាំងទុក និងការតាមដាន ដើម្បីបង្ខំឱ្យអ្នកឆ្លើយតបធ្វើអ្វីដែលពួកគេពុំចង់ធ្វើ (១,៨៤%)។

*តារាង ៦៖ ការរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរ/ការប្រាស្រ័យទាក់ទង*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| និយោជកធ្លាប់ដកហូតឯកសារអត្តសញ្ញាណ ឬបានគំរាមដកហូតដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៨៧ | ៧,២៣% | ៧,០៨% | ៥,១៧% | ៨,៩៩% |
| និយោជក ឬអ្នកជ្រើសរើសពលករ កាន់ឯកសារអត្តសញ្ញាណរបស់អ្នកដូចជាលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ។ | ៤៤ | ៣,៦៦% | ៣,៣២% | ១,៨៩% | ៤,៧៥% |
| បន្ទាប់ពីអ្នកចប់វេនការងារ និយោជករបស់អ្នកមិនអនុញ្ញាតឱ្យអ្នកធ្វើដំណើរដោយសេរីនៅក្នុងសហាគមន៍ឡើយ។ | ១៨៦ | ១៥,៤៥% | ១៦,៦០% | ១៣,៩២% | ១៩,២៩% |
| (ប្រសិនបើអ្នកឆ្លើយតបរស់នៅផ្ទះដែលនិយោជិតផ្តល់ជូន) មិនអនុញ្ញាតឱ្យ រស់នៅកន្លែងណាផ្សេងទៀត និងរក្សាការងាររបស់អ្នក ប្រសិនបើអ្នកបានសម្រេចចិត្តរស់នៅក្នុងផ្ទះដែលនិយោជកផ្តល់ជូន។ | ៣០០ | ២៤,៩២% | ២៥,១៤% | ២២,០៣% | ២៨,២៦% |
| ការបាត់បង់សេរីភាពក្នុងការធ្វើដំណើរ ឬការប្រាស្រ័យទាក់ទង ឬត្រូវបានយកទៅបំបរបង់ចោល ប្រសិនបើឈប់ពីការងារមិនចប់កិច្ចសន្យា។ | ៥៦ | ៤,៦៥% | ៤,២៣% | ២,៧៥% | ៥,៧០% |
| និយោជកបានដាក់ឱ្យអ្នកនៅដាច់ដោយឡែកតែឯង បង្ខាំងអ្នក និងតាមដានអ្នក ឬបានគំរាមកំហែងធ្វើដូច្នេះ។ | ២២ | ១,៨៣% | ១,៨៤% | ០,៧៥% | ២,៩៣% |

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន ប៉ាន់ប្រមាណ | ចន្លោះជឿជាក់ ៩៥% | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| ណាមួយខាងលើ | ៩៧៧ | ៣៩,៦២% | ៣៩,៦៧% | ៣៦,១៧% | ៤៣,១៨% |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*

## ◢ ការបំពេញការងារដែលមានការរំលោភបំពាន/ដោយបង្ខំ

តារាង ៧ បង្ហាញអំពីអត្រារងគ្រោះសម្រាប់ការអនុវត្តពលកម្ម ឬយុទ្ធវិធីការងារដែលមានលក្ខណៈរំលោភបំពានមួយចំនួនប្រព្រឹត្តដោយនិយោជក ដើម្បីបង្ខិតបង្ខំនិយោជិតឱ្យធ្វើអ្វីដែលពួកគេមិនចង់ធ្វើ ឬក្នុងគោលបំណងកេងប្រវ័ញ្ចទាំងស្រុងលើពលករចំណាកស្រុកដើម្បីផលចំណេញ។ អ្នកឆ្លើយតបភាគច្រើន ពោលគឺមាន ៥៨,៨៩% បានរាយការណ៍ថាធ្លាប់បានទទួលរងការរំលោភបំពានយ៉ាងហោចណាស់មួយក្នុងចំណោមការរំលោភបំពាននៅកន្លែងធ្វើការដែលបានរៀបរាប់។ ជាពិសេស បច្ចេកទេសបង្ខិតបង្ខំទូទៅបំផុតដែលបានរាយការណ៍ គឺនិយោជកដាក់បន្ទុក (ឬគំរាមដាក់បន្ទុក) ថ្លៃចំណាយហិរញ្ញវត្ថុ ផ្លូវច្បាប់ និងការបង្ខូចកេរ្តិ៍ឈ្មោះមកលើពលករណាដែលឈប់ពីការងារមុនពេលចប់កិច្ចសន្យា៖ អ្នកឆ្លើយតប ៤៧,៩២% បានរាយការណ៍ថាធ្លាប់បានទទួលរងការរំលោភបំពានបែបនេះ។

វិធីសាស្ត្របង្ខិតបង្ខំទូទៅបំផុតបន្ទាប់ដែលនិយោជកប្រើប្រាស់ក្នុងការ ភាពមិនស្ម័គ្រចិត្តឱ្យពលករធ្វើអ្វីដែលពួកគេមិនចង់ធ្វើនោះគឺ ការមិនបើកប្រាក់ឱ្យពលករ ឬមិនអនុញ្ញាតឱ្យពួកគេរក្សាទុកប្រាក់ដែលពួកគេខំរកបាន (៩,៦៩%)។

វិធីសាស្ត្របង្ខិតបង្ខំមិនសូវពេញនិយមដែលអ្នកឆ្លើយតបបានរាយការណ៍នៅអត្រាស្រដៀងគ្នា (ចន្លោះពី ៤-៦%) គឺជាការដកហូត (ឬគំរាមដកហូត) ប្រាក់ឈ្នួលដែលត្រូវទទួល រួមទាំងប្រាក់ថែមម៉ោង (៥,៨២%) ការរាយការណ៍ (ឬគំរាមរាយការណ៍) ពលករចំណាកស្រុកទៅកាន់អាជ្ញាធរ (៥,៤៧%) ភាពមិនស្ម័គ្រចិត្តឱ្យពលករធ្វើការងារដោយមិនទទួលបានប្រាក់ឈ្នួល/កាត់ប្រាក់ឈ្នួលដើម្បីសងកម្ចីដែលជំពាក់និយោជក ឬ ទីភ្នាក់ងារជ្រើសរើសពលករ (៤,៧៦%) ឬនិយោជកបញ្ចុះបញ្ចូល (ឬគំរាមបញ្ចុះបញ្ចូល) និយោជកផ្សេងទៀតនៅក្នុងតំបន់របស់ពួកគេមិនឱ្យជ្រើសរើសពលករ ឬគ្រួសាររបស់ពួកគេឱ្យចូលបម្រើការងារ (៤,១០%)។ ការរំលោភបំពានដែលរាយការណ៍តិចបំផុត (ដោយអ្នកឆ្លើយតប ១,៨៧%) គឺនិយោជកបំភ្លៃ (ឬគំរាមបំភ្លៃ) ចំនួនទឹកប្រាក់បំណុលដែលពលករជំពាក់ ដើម្បីធ្វើឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ។

*តារាង ៧៖ ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជនប៉ាន់ប្រមាណ | ចន្លោះជឿជាក់ ៩៥% | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| ផលវិបាកហិរញ្ញវត្ថុ ផ្លូវច្បាប់ ឬកេរ្តិ៍ឈ្មោះធ្ងន់ធ្ងរ ប្រសិនបើពលករឈប់ពីការងារមុនពេលចប់កិច្ចសន្យា។ | ៥៧៧ | ៤៧,៩២% | ៤៧,៥៤% | ៤៤,០៨% | ៥០,៩៩% |
| និយោជកបានកាត់ទុកប្រាក់ឈ្នួលដែលត្រូវទទួលបានដោយមិនស្មើភាព រួមទាំងប្រាក់ឈ្នួលថែមម៉ោង ឬបានគំរាមកាត់ប្រាក់ឈ្នួល ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៨១ | ៦,៧៣% | ៥,៨២% | ៤,១៣% | ៧,៥០% |

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| និយោជកបានរាយការណ៍អ្នកទៅកាន់អាជ្ញាធរ ដើម្បីឱ្យអ្នកធ្វើកិច្ចការអ្វីមួយ ឬបានគំរាមធ្វើដូច្នោះ។ | ៧៩ | ៦,៥៦% | ៥,៤៧% | ៣,៩៧% | ៦,៩៦% |
| និយោជកបានបញ្ចុះបញ្ចូលនិយោជកផ្សេងទៀតនៅក្នុងតំបន់របស់ពួកគេមិនឱ្យជ្រើសរើសអ្នក ឬគ្រួសាររបស់អ្នកឱ្យចូលបម្រើការងារ ឬបានគំរាមធ្វើដូច្នោះ ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៥៩ | ៤,៩០% | ៤,១០% | ២,៨០% | ៥,៣៩% |
| និយោជកបានបំភ្លៃចំនួនទឹកប្រាក់បំណុលដែលអ្នកជំពាក់ ឬបានគំរាមកំហែងធ្វើដូច្នោះ ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៣១ | ២,៥៧% | ១,៨៧% | ១,០២% | ២,៧៣% |
| បានបង្ខំឱ្យធ្វើការងារដោយមិនទទួលបានប្រាក់ឈ្នួល/កាត់ប្រាក់ឈ្នួលដើម្បីសងកម្ចីដែលជំពាក់និយោជក ឬ ទីភ្នាក់ងារជ្រើសរើសពលករ។ | ៦៧ | ៥,៥៦% | ៤,៧៦% | ៣,២១% | ៦,៣១% |
| មិនបានបើកប្រាក់ ឬមិនអនុញ្ញាតឱ្យរក្សាទុកប្រាក់ដែលអ្នករកបាន។ | ១១៨ | ៩,៨០% | ៩,៦៩% | ៧,៦២% | ១១,៧៦% |
| **ណាមួយខាងលើ** | **៧០៩** | **៥៨,៨៩%** | **៥៧,៣១%** | **៥៣,៨៦%** | **៦០,៧៦%** |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*



## បរិយាកាសការងារដែលឆបោកឬអយុត្តិធម៌ឬអសុវត្ថិភាព

តារាង ៨ តំណាងឱ្យបទពិសោធន៍រងគ្រោះពីការអនុវត្តការងារមិនស្មើភាព ឬឆបោក ឬបរិយាកាសការងារមិនមានសុវត្ថិភាពជាច្រើនប្រភេទ។ ដោយសារតែការរំលោភបំពានដែលបានរកឃើញមានកម្រិតខុសៗគ្នា អ្នកឆ្លើយតបលើសពីមួយភាគបួន ពោលគឺ ២៨,២២% បានរាយការណ៍ថាធ្លាប់ទទួលរងការរំលោភបំពានយ៉ាងហោចណាស់មួយក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់។ ការរំលោភបំពានដែលបានរាយការណ៍ច្រើនបំផុត គឺអ្នកឆ្លើយតបមិនទទួលបានប្រាក់ឈ្នួលបន្ថែម ឬទទួលបានប្រាក់ឈ្នួលតិចជាងអត្រាធម្មតាសម្រាប់ការងារថែមម៉ោង (៨,៧៩%)។ ការអនុវត្តការងារឆបោក និងមានគ្រោះថ្នាក់បានរាយការណ៍ក្នុងទិន្នន័យស្រដៀងគ្នា៖ ទិដ្ឋភាពមួយចំនួននៃការងារ (ដូចជា ភារកិច្ច ប្រាក់ឈ្នួល ការទូទាត់ប្រាក់ថែមម៉ោង កន្លែងស្នាក់នៅ ឬទីតាំង) គឺមានលក្ខណៈយ៉ាប់យ៉ឺនជាងអ្វីដែលអ្នកជ្រើសរើសពលករបានសន្យា (៨,៤៤%) និងនិយោជកដាក់បន្ទុក (ឬគំរាមដាក់បន្ទុក) ពន្ធអាករ ឬកម្រៃលើសកម្រិតលើអ្នកឆ្លើយតបដើម្បីធ្វើឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ (៧,៥៦%)។

ការរំលោភបំពានដែលពុំសូវកើតមាន គឺមានការរាយការណ៍ថា និយោជកបានគំរាមកំហែងធ្វើយ៉ាងណាឱ្យស្ថានភាពរបស់ពលករកាន់តែយ៉ាប់យ៉ឺន (៤,៧៨%)។ លើសពីនេះ អ្នកឆ្លើយតប ៣,០៤% បានរាយការណ៍ថា និយោជកបានបង្ខំឱ្យពួកគេធ្វើការងារលើសម៉ោង ដើម្បីទុកជាការពិន័យ។

អ្នកឆ្លើយតបមួយចំនួនតូច (២,៥២%) បានរាយការណ៍ថា និយោជកបានបង្អត់អាហារ និងទឹក ឬមិនឱ្យពលករចំណាកស្រុកបានគេងគ្រប់គ្រាន់ ដើម្បីបង្ខំពួកគេឱ្យធ្វើអ្វីដែលពួកគេមិនចង់ធ្វើ។ ទោះជាយ៉ាងនេះក្តី អ្នកឆ្លើយតបត្រឹមតែ ០,៥០% ប៉ុណ្ណោះ បានរាយការណ៍ថា និយោជករបស់ពួកគេបានបង្អត់អាហារ ឬទឹកពីពួកគេ ដើម្បីបង្ខំពួកគេឱ្យធ្វើអ្វីដែលពួកគេពុំចង់ធ្វើ។

ការរាយការណ៍អំពីនិយោជកមានចេតនាកាត់ចេញ (ឬគំរាមកាត់ចេញ) ពីការងារនាពេលអនាគត ឬឱកាសការងារថែមម៉ោងជាតាក់ទិចក្នុងភាពមិនស្ម័គ្រចិត្តពលករចំណាកស្រុក គឺត្រូវបានរកឃើញថាកើតឡើងក្នុងទិន្នន័យស្រដៀងគ្នា (២,១៥%)។ អ្នកឆ្លើយតប ២,០០% បានរាយការណ៍ថា ពួកគេពុំត្រូវបានអនុញ្ញាតឱ្យរស់នៅកន្លែងណាផ្សេងក្រៅពីផ្ទះដែលនិយោជិកផ្តល់ឱ្យនោះទេ និងបានទ្រាំរស់ក្នុងលក្ខខណ្ឌយ៉ាប់យ៉ឺនជាងអ្វីដែលបានសន្យា ដូចជា កន្លែងស្នាក់នៅពុំមានសុវត្ថិភាព ដេកបន្ទប់រួមគ្នាជាមួយមនុស្សជាច្រើនផ្សេងទៀត ឬពុំមានកន្លែងសម្រាប់ទុកដាក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។

*តារាង ៨៖ បរិយាកាសការងារដែលឆបោក/អយុត្តិធម៌/អសុវត្ថិភាព*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| ទិដ្ឋភាពមួយចំនួននៃការងារ (ដូចជា ភារកិច្ច ប្រាក់ឈ្នួល ការទូទាត់ប្រាក់ថែមម៉ោង កន្លែងស្នាក់នៅ ឬទីតាំង) គឺមានលក្ខណៈយ៉ាប់យ៉ឺនជាងអ្វីដែលអ្នកជ្រើសរើសពលករបានសន្យា។ | ៩៩ | ៨,២២% | ៨,៤៤% | ៦,៤៣% | ១០,៤៥% |
| និយោជកបានគំរាមកំហែងធ្វើយ៉ាងណាឱ្យលក្ខខណ្ឌការងាររបស់អ្នកកាន់តែយ៉ាប់យ៉ឺន ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៦៥ | ៥,៤០% | ៤,៧៨% | ៣,៣០% | ៦,២៦% |
| និយោជកបានដកហូតការគេងរបស់អ្នក ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកពុំចង់ធ្វើ។ | ៣៩ | ៣,២៤% | ២,៥២% | ១,៤២% | ៣,៦១% |
| ពុំមានការផ្តល់កម្រៃបន្ថែមសម្រាប់ការងារថែមម៉ោង តិចជាងអត្រាធម្មតា។ | ១២២ | ១០,១៣% | ៨,៧៩% | ៦,៩១% | ១០,៦៧% |
| និយោជកបានធ្វើឱ្យអ្នកធ្វើការងារបន្ថែមជាការពិន័យ។ | ៣៧ | ៣,០៧% | ៣,០៤% | ១,៨១% | ៤,២៨% |

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជនប៉ាន់ប្រមាណ | ចន្លោះជឿជាក់ ៩៥% | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| និយោជកបានដកអ្នកចេញពីឱកាសការងារ ឬឱកាសធ្វើការថែមម៉ោង ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ៣៣ | ២,៧៤% | ២,១៥% | ១,៣២% | ២,៩៨% |
| និយោជកបានដាក់បន្ទុកពន្ធអាករឬកម្រៃហួសកម្រិតទៅលើអ្នក ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ ឬបានគំរាមកំហែងឱ្យអ្នកធ្វើតាម។ | ៨៨ | ៧,៣១% | ៧,៥៦% | ៥,៥៨% | ៩,៥៣% |
| និយោជកបានបង្អត់អាហារ ឬទឹកពីអ្នក ដើម្បីឱ្យអ្នកធ្វើអ្វីដែលអ្នកមិនចង់ធ្វើ។ | ១២ | ១,០០% | ០,៥០% | ០,១៨% | ០,៨២% |
| (ចំពោះអ្នកឆ្លើយតបដែលរស់នៅក្នុងផ្ទះដែលនិយោជកផ្តល់ជូន) មិនអនុញ្ញាតឱ្យទៅរស់នៅកន្លែងផ្សេង លក្ខខណ្ឌរស់នៅយ៉ាប់យ៉ឺន មានមនុស្សច្រើនពេកដេកក្នុងបន្ទប់តែមួយរួមគ្នា កន្លែងស្នាក់នៅមិនមានសុវត្ថិភាព មិនមានកន្លែងសម្រាប់ទុកដាក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ | ៣២ | ២,៦៦% | ២,០០% | ០,៩៧% | ៣,០២% |
| ចំណុចណាមួយដូចខាងលើ | ៣៥១ | **២៩,១៥%** | **២៨,២២%** | **២៥,០០%** | **៣១,៤៣%** |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*

## ◢ សោហ៊ុយច្រើនហួសហេតុក្នុងការចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន

ការវិភាគចុងក្រោយរបស់ក្រុមការងារ គឺបានអនុវត្តយុទ្ធសាស្ត្រកំណត់លក្ខណៈសម្បត្តិពីរជំហានដែលបាន និងកំពុងប្រើប្រាស់ក្នុងការសិក្សាមួយចំនួនផ្សេងទៀត (សូមមើល Zhang et al,. ២០១៩; Vincent. Zhang. Dank. ២០១៩) ដើម្បីកំណត់ករណីដែលអាចកើតមាននៃការជួញដូរមនុស្ស ឬពលកម្មដោយបង្ខំ។ យុទ្ធសាស្ត្រនេះ មាននូវធាតុផ្សំសំខាន់ៗចំនួនពីរ៖ (១) ការរំលោភសិទ្ធិមនុស្សប្រព្រឹត្តដោយនិយោជក ឬការអនុវត្តពលកម្មមិនស្មើភាពឬកេងប្រវ័ញ្ចសុទ្ធសាធ ដែលមានលក្ខណៈបង្ខិតបង្ខំ និង (២) ការពុំអាចឈប់ពីការងារដោយអាចនាំឱ្យមានការពិន័យធ្ងន់ធ្ងរ។ ក្រុមការងារអាចនិយាយបានម្យ៉ាងទៀតថា ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាជនរងគ្រោះ នៃពលកម្មដោយបង្ខំ ពលករចាំបាច់ត្រូវ (១) ធ្លាប់បានទទួលរងការរំលោភបំពាន ឬការរំលោភសិទ្ធិប្រភេទណាមួយនៅកន្លែងធ្វើការ ឬដែលប្រព្រឹត្តដោយនិយោជក និង (២) ដឹងថាខ្លួនពុំមានលទ្ធភាពចាកចេញពីបរិយាកាសការងារនោះទេ ដោយសារពួកគេភ័យខ្លាចទទួលរងផលវិបាកធ្ងន់ធ្ងរ ឧទាហរណ៍ ផលវិបាកនៃការចាកចេញពីកន្លែងធ្វើការដែលមានលក្ខណៈរំលោភបំពាន ឬការដាក់ពិន័យពេលឈប់ពីការងារ។

វិធីសាស្ត្រកំណត់លក្ខណៈសម្បត្តិពីរជំហាននេះ បានកើតចេញពីបញ្ហាពុំរ៉ៃ ដែលពុំមានការដោះស្រាយក្នុងការកំណត់អំពីការជួញដូរមនុស្ស - មិនថាការជួញដូរមនុស្សគួរតែកំណត់ជាឧប្បត្តិហេតុ ដូចជាច្បាប់ព្រហ្មទណ្ឌ ឬព្រឹត្តិការណ៍ ឬជាស្ថានភាពកើតឡើង ដែលតាមរយៈនេះ ការប្រឈមដដែលៗ និងរយៈពេលយូរទៅនឹងការរំលោភសិទ្ធិ ឬការអនុវត្តពលកម្មមិនស្មើភាព នឹងត្រូវកំណត់លក្ខណៈសម្បត្តិថាជាការជួញដូរមនុស្ស។ មានចំណុចដែលកំណត់ពុំបានត្រឹមត្រូវអំពីថាតើសកម្មភាពមួយណាដែលគួរចាត់ថ្នាក់ជាសកម្មភាពជួញដូរមនុស្ស។ នៅក្នុងសហគមន៍ស្រាវជ្រាវ មិនមានការព្រមព្រៀងមតិទៅលើការវាស់ស្ទង់ការវាស់វែងជាក់លាក់សម្រាប់ចំណុច ឬកម្រិតកំណត់ដែលបង្កើតឡើងពុំបានល្អនេះឡើយ។ វិធីសាស្ត្រពីរជំហាននេះ ផ្តល់នូវគុណសម្បត្តិច្បាស់លាស់ចំនួនពីរ៖ (១) បង្កើនភាពច្បាស់លាស់លើទស្សនាទាន និងអ្វី

ដែលសំខាន់ជាងនេះទៅទៀតនោះ គឺ (២) សំអាងលើហេតុការណ៍ជាក់ស្តែងសម្រាប់ការអនុវត្តផ្ទាល់។ ដើម្បីចៀសវាងភាពសាមញ្ញនៃការវាស់ស្ទង់វិធានការផ្អែកលើឧប្បត្តិហេតុ ដូចដែលអ្នកជំនាញព្រហ្មទណ្ឌភាគច្រើន នឹងបង្កើតបានជាស្ថិតិបទល្មើស ក៏ដូចជាដើម្បីចៀសពីកិច្ចការស្មុគស្មាញនៃការព្យាយាមកំណត់រយៈពេលនៃការរំលោភសិទ្ធិ វិធីសាស្ត្រពីរជំហាននេះ លើកបញ្ជាក់ហេតុផលថា លក្ខខណ្ឌសម្គាល់អំពីការជួញដូរមនុស្ស គឺត្រូវពិនិត្យមើលទៅលើបុគ្គលដែលមិនអាចចាកចេញពីបរិយាកាសការងារដែលមានលក្ខណៈរំលោភបំពានបាន (អាចជាពលកម្ម ឬផ្លូវភេទ) ដោយពួកគេពុំចាំបាច់ត្រូវចំណាយច្រើនហួសហេតុនោះទេ។ ដូច្នេះ ចំណាយលើការចាកចេញឬការពិន័យ ក៏ជាធាតុផ្សំដ៏សំខាន់ផងដែរក្នុងការកំណត់អំពីកម្រិតវិសាលភាពនៃពលកម្មដោយបង្ខំ។

តារាង ៩ បង្ហាញអំពីការប៉ាន់ប្រមាណប្រមាណសម្រាប់ការរំលោភបំពានពាក់ព័ន្ធនឹងចំណាយលើការចាកចេញ។ យើងបានរកឃើញថា អ្នកឆ្លើយតបតិចជាងពាក់កណ្តាល អាចចាកចេញពីស្ថានភាពការងារដោយសេរី ដោយមិនមានការប្រឈមទៅនឹងផលវិបាកអវិជ្ជមានឡើយ។ ពលករចំណាកស្រុកកម្ពុជា ៥៣,២១% បានរាយការណ៍អំពីថ្លៃចំណាយ ឬឧបសគ្គរាំងលើសកម្រិតយ៉ាងហោចណាស់មួយទម្រង់ ដែលរារាំងពួកគេពុំឱ្យចាកចេញពីស្ថានភាពការងារពុំស្មើភាពឬមានលក្ខណៈរំលោភបំពាន។

ទម្រង់នៃថ្លៃចំណាយលើសកម្រិតដែលបានរាយការណ៍ញឹកញាប់បំផុត គឺការពុំមានលទ្ធភាពចាកចេញ ឬធ្វើការឱ្យនិយោជកផ្សេងទៀតមុនពេលចប់កិច្ចសន្យា។ អ្នកឆ្លើយតប ៣៩,៦៨% បានរាយការណ៍ថា ពួកគេពុំអាចចាកចេញបានឡើយ ដោយសារពួកគេនឹងប្រឈមមុខនឹងផលវិបាកធ្ងន់ធ្ងររួមទាំង អំពើហិង្សាផ្លូវកាយឬផ្លូវភេទ ការបង្អត់អាហារ និងទីជម្រក វិធានការផ្លូវច្បាប់ ឬការបាត់បង់ប្រាក់កម្រៃដែលខំរកបាន។ នៅអត្រាឧប្បត្តិហេតុស្រដៀងគ្នា អ្នកឆ្លើយតប ៣៩,៣៥% បានអះអាងថា ពួកគេមិនមានលទ្ធភាពបដិសេធមិនធ្វើការងារ ដោយពុំទទួលរងផលវិបាកឡើយនៅពេលដែលពួកគេត្រូវបានគេរំពឹងឱ្យធ្វើការងារ។ នៅពេលដែលអ្នកឆ្លើយតបបានរាយការណ៍អំពីការធ្លាប់ទទួលរងទម្រង់នៃការរំលោភបំពានមួយចំនួន ឬការប្រព្រឹត្តចំពោះដោយមិនស្មើភាពគ្នា យើងបានសួរពួកគេថា "ហេតុអ្វីបានអ្នកនៅតែបន្តធ្វើការងារនោះ?" យើងបានរកឃើញថា អ្នកឆ្លើយតបត្រឹមតែ ២,០៩% ប៉ុណ្ណោះ ដែលអាចមានលទ្ធភាពចាកចេញពីការងារដោយសារតែពួកគេភ័យខ្លាចទទួលរងផលវិបាកធ្ងន់ធ្ងរ ដូចជាការមិនអាចមានលទ្ធភាពយកលិខិតឆ្លងដែនមកវិញ ត្រូវបានគេរាយការណ៍ដល់អាជ្ញាធរ ការកាត់យកប្រាក់ឈ្នួល ការត្រូវទូទាត់ប្រាក់ពិន័យដល់និយោជក ឬគ្រួសារ ឬខ្លួនឯងនឹងត្រូវទទួលរងអំពើហិង្សាពីសំណាក់និយោជក។

ជាចុងក្រោយ ក្រុមការងារបានរកឃើញថា ពលករចំណាកស្រុកមួយចំនួនតូច (១០,៨%) ត្រូវបានគេបង្ខំឱ្យទទួលយកកិច្ចសន្យាការងារ ដោយសារផលវិបាកធ្ងន់ធ្ងរ បើពួកគគេបដិសេធ។

*តារាង ៩៖ សោហ៊ុយច្រើនហួសហេតុក្នុងការចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| ការពុំអាចបដិសេធការងារ ដោយពុំមានផលវិបាក ពេលពួកគេត្រូវបានរំពឹងឱ្យធ្វើការ។ | ៤៩២ | ៤០,៨៦% | ៣៩,៣៤% | ៣៥,៩២% | ៤២,៧៦% |
| ពុំមានសេរីភាពក្នុងការចាកចេញ ឬធ្វើការឱ្យនិយោជកផ្សេងទៀតដោយមិនមានផលវិបាក។ | ៤៧៣ | ៣៩,២៩% | ៣៩,៦៨% | ៣៦,២២% | ៤៣,១៤% |
| ការនៅបន្តធ្វើការងារ ដោយសារគ្រោះថ្នាក់នៃការបំភិតបំភ័យ ឬអំពើហិង្សាជាមធ្យោបាយនៃការបង្ខិតបង្ខំ។ | ២៨ | ២,៣៣% | ២,០៩% | ១,០៦% | ៣,១២% |
| ពុំអាចបដិសេធការផ្តល់ជូនការងារដោយពុំមានផលវិបាក។ | ១១៥ | ៩,៥៥% | ១០,០៨% | ៧,៨៦% | ១២,៣១% |
| **ណាមួយខាងលើ** | **៦៤៧** | **៥៣,៧៤%** | **៥៣,២១%** | **៤៩,៦៩%** | **៥៦,៧៣%** |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*

## ◢ សេចក្តីសង្ខេបអំពីការរំលោភបំពានលើការជួញដូរមនុស្ស

ដើម្បីសង្ខេបអំពីទិដ្ឋភាពខុសៗគ្នា នៃការវាស់ស្ទង់ការវាស់វែង ពលកម្មដោយបង្ខំដែលបានបង្ហាញនៅខាងលើ យើងបានបូកសរុបការវាស់វែង ការវាស់ស្ទង់នីមួយៗទាំងអស់ទៅជាកម្រិតវិសាលភាពនៃគ្រោះថ្នាក់ ៤ ប្រភេទ ចំណុចចាប់ផ្តើមពីរជំហាន និងសូចនាករស្តីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ ដូចបានបង្ហាញក្នុងតារាង ១០។ នៅលើកម្រិតវិសាលភាពនៃគ្រោះថ្នាក់ ប្រភេទការសិក្សារបស់ក្រុមការងារយើងបានរកឃើញថាពលករចំណាកស្រុកកម្ពុជា ១៣,៦១% បានរាយការណ៍ថាធ្លាប់បានទទួលរងការរំលោភបំពាន យ៉ាងហោចណាស់មួយក្នុងចំណោមការវាស់ស្ទង់ការវាស់វែងធ្ងន់ធ្ងរបំផុត ពោលគឺ ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ។ ចំពោះការរឹតត្បិតសេរីភាព អ្នកឆ្លើយតប ៣៩,៦៧% បានរាយការណ៍ថាបានជួបប្រទះការរំលោភបំពាន យ៉ាងហោចណាស់មួយក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់។ អំពីការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ យើងបានរកឃើញថា អ្នកឆ្លើយតប ៥៧,៣១% បានទទួលរងការអនុវត្តការងារមានលក្ខណៈរំលោភបំពាន ឬបង្ខិតបង្ខំពីសំណាក់និយោជករបស់ពួកគេ ដើម្បីឱ្យពួកគេធ្វើអ្វីដែលពួកគេមិនចង់ធ្វើ។ ចំពោះបរិយាកាសការងារដែលឆបោក/អយុត្តិធម៌/អសុវត្ថិភាពវិញ យើងបានរកឃើញថា អ្នកឆ្លើយតប ២៨,២២% បានរាយការណ៍ថាបានជួបប្រទះការរំលោភបំពានយ៉ាងហោចណាស់មួយ ក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់។

> នៅពេលដែលទាំងការគំរាមកំហែងដាក់ទណ្ឌកម្ម និង ការបង្ខំ ត្រូវបានរួមបញ្ចូលគ្នាដើម្បីកំណត់លក្ខណៈសម្បត្តិសម្រាប់ការកំណត់និយមន័យរបស់អង្គការពលកម្មអន្តរជាតិអំពីពលកម្មដោយបង្ខំ យើងបានរកឃើញថា អ្នកឆ្លើយតប ៣៩.៥៩% (ឬបួននាក់ក្នុងចំណោមដប់នាក់) នឹងត្រូវកំណត់ថាជាជនរងគ្រោះ

ដោយពិចារណាទៅលើអត្រាខុសៗគ្នា នៃការរំលោភបំពានជួញដូរមនុស្សនៅតាមប្រភេទទាំងបួននេះ យើងបានរកឃើញចំណែកនៃអ្នកឆ្លើយតបដែលត្រូវទៅនឹងប្រភេទទាំងបួននេះ ឬធ្លាប់បានទទួលរងគ្រោះថ្នាក់ក្នុងវិសាលភាពពេញលេញ។ ក្រុមការងារបានរកឃើញថា ពលករចំណាកស្រុកកម្ពុជា ៤,២៧% បានទទួលរងការរំលោភបំពានពលកម្មដោយបង្ខំនៅតាមប្រភេទទាំង ៤នេះ ដោយបង្ហាញឱ្យឃើញអំពីការត្រួតគ្នាតិចតួចរវាងទិដ្ឋភាពទាំង ៤ អំពីការរំលោភបំពានពលកម្មដោយបង្ខំ។

ចំពោះគម្រោងចំណុចចាប់ផ្តើមពីរជំហានរបស់យើងវិញ យើងបានរកឃើញថា អ្នកឆ្លើយតប ៥៣,២១% បានលើកឡើងថាបានជួបប្រទះថ្លៃចំណាយច្រើនហួសហេតុមួយក្នុងចំណោមការវាស់ស្ទង់នៃការចំណាយច្រើនហួសហេតុនានា ដែលរារាំងពួកគេពុំឱ្យចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពានដោយសេរីបាន។

ដូចដែលបានបង្ហាញនៅក្នុងតារាង ១០ តាមរយៈការប្រើប្រាស់សូចនាកររបស់អង្គការពលកម្មអន្តរជាតិ យើងបានរកឃើញថា អ្នកឆ្លើយតប ៩៦,៥១% បានលើកឡើងថាធ្លាប់បានជួបប្រទះការ គំរាមកំហែងដាក់ទណ្ឌកម្មមួយក្នុងចំណោមការវាស់ស្ទង់គំរាមកំហែងដាក់ទណ្ឌកម្ម។ ចំពោះការវាស់វែងនៃភាពមិនស្ម័គ្រចិត្តវិញ យើងបានរកឃើញថា អ្នកឆ្លើយតប ៦០,៥៥% បានទទួលរងការរំលោភបំពានយ៉ាងហោចណាស់មួយ ក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់។ ពេលដែលទាំងការគំរាមកំហែងដាក់ទណ្ឌកម្ម និងភាពពុំស្ម័គ្រចិត្ត ត្រូវបានរួមបញ្ចូលគ្នាដើម្បីកំណត់លក្ខណៈសម្បត្តិសម្រាប់ការកំណត់និយមន័យរបស់អង្គការពលកម្មអន្តរជាតិអំពីពលកម្មដោយបង្ខំ ក្រុមការងារបានរកឃើញថា អ្នកឆ្លើយតប ៣៩,៥៩% នឹងត្រូវកំណត់ថាជា ដែលអាចជាជនរងគ្រោះ។

*តារាង ១០៖ សេចក្តីសង្ខេបអំពីសូចនាករស្តីពីពលកម្មដោយបង្ខំ*

| សំណួរ | N** វិជ្ជមាន | ស្ថិតិគំរូ** | ចំនួនប្រជាជន *ប៉ាន់ប្រមាណ* | ចន្លោះជឿជាក់ *៩៥%* | |
|---|---|---|---|---|---|
| | | | | ក្រោម | លើ |
| កម្រិតវិសាលភាពនៃគ្រោះថ្នាក់ (% វិជ្ជមាន) | | | | | |
| **១. ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ** | ១៦៤ | ១៣,៦២% | ១៣,៦១% | ១១,១៧% | ១៦,០៦% |
| **២. ការរឹតត្បិតសេរីភាព** | ៤៧៧ | ៣៩,៦២% | ៣៩,៦៧% | ៣៦,១៧% | ៤៣,១៨% |
| **៣. ការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ** | ៧០៩ | ៥៨,៨៩% | ៥៧,៣១% | ៥៣,៨៦% | ៦០,៧៦% |
| **៤. បរិយាកាសការងារដែលឆបោក អយុត្តិធម៌ឬអសុវត្ថិភាព** | ៣៥១ | ២៩,១៥% | ២៨,២២% | ២៥,០០% | ៣១,៤៣% |
| ចំណុចណាមួយខាងលើ | ៥៩ | ៤,៩០% | ៤,២៧% | ២,៨៤% | ៥,៦៩% |
| ចំណុចចាប់ផ្តើមពីរជំហាន (% វិជ្ជមាន) | | | | | |
| **៥, ថ្លៃចំណាយហួសហេតុក្នុងការចាកចេញពីបរិយាកាសកាងារដែលមានការរំលោភបំពាន** | ៦៤៧ | ៥៣,៧៤% | ៥៣,២១% | ៤៩,៦៩% | ៥៦,៧៣% |

| | | | | | |
|---|---|---|---|---|---|
| **ចំណុចណាមួយខាងលើ** | ៩៥ | **៣,៧៩%** | **៣,២០%** | **១,៩៩%** | **៩,៥៥%** |
| **សូចនាករស្តីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ (% វិជ្ជមាន)** | | | | | |
| ១, **គំរាមកំហែងដាក់ទណ្ឌកម្ម** | ៥៨៣ | ៩៨,៩២% | ៩៦,៥១% | ៩២,៩៦% | ៥០,០៧% |
| ២, ភាពមិនស្ម័គ្រចិត្ត | ៧៥៩ | ៦២,៦២% | ៦០,៥៥% | ៥៧,០៥% | ៦៩,០៦% |
| ពលកម្មដោយបង្ខំ របស់អង្គការពលកម្មអន្តរជាតិ (ការគំរាម ១ + ភាពមិនស្ម័គ្រចិត្ត ១) | ៥០៨ | **៩២,១៩%** | **៣៩,៥៩%** | **៣៦,១១%** | **៩៣,០៧%** |

*សម្គាល់៖ *ចំនួនអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមានតាមសូចនាករ; **ស្ថិតិគំរូ ឆ្លុះបញ្ចាំងអំពីភាគរយនៃអ្នកឆ្លើយតបដែលបានកំណត់អត្តសញ្ញាណជាវិជ្ជមាននៃសូចនាករ ដោយផ្អែកលើទំហំសំណាកសរុប (N=១.២០៤)។*



**លទ្ធផលបែងចែកដោយប្រជាសាស្ត្រសំខាន់ៗ** លទ្ធផលមានភាពខុសគ្នាបន្តិចតាមយេនឌ័រ ដូចដែលបានបង្ហាញនៅក្នុងរូបភាព ៣។ ជាមធ្យម ពលករចំណាកស្រុកបុរស បានទទួលរងភាពងាយរងគ្រោះនៃពលកម្មដោយបង្ខំក្នុងអត្រាខ្ពស់ជាងគេនៅគ្រប់សូចនាករទាំងអស់ ដែលខ្ពស់ជាងពលករចំណាកស្រុកស្ត្រី។ គួរឱ្យកត់សម្គាល់ ភាពលម្អៀងគឺមានលក្ខណៈខុសគ្នាខ្លាំងតាមស្ថិតិចំពោះការវាស់ស្ទង់ធ្ងន់ធ្ងរបំផុត (ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ) និងការវាស់ស្ទង់ការវាស់វែងពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ (ការគំរាមដាក់ទណ្ឌកម្ម & សូចនាករទាំងមូល)។ យើងបានប៉ាន់ប្រមាណប្រមាណថា ពលករចំណាកស្រុកបុរស ៩៥,៦០% មកពីប្រទេសកម្ពុជា គឺបានទទួលរងគ្រោះតាមរយៈទម្រង់មួយចំនួននៃការរំលោភបំពានពលកម្មដោយបង្ខំ បើធៀបទៅនឹងអត្រាប៉ាន់ប្រមាណប្រមាណ ៣៦,៣៩% ក្នុងចំណោមពលករចំណាកស្រុកស្ត្រី។

> ជាមធ្យម ពលករចំណាកស្រុកបុរស បានទទួលរងភាពងាយរងគ្រោះនៃពលកម្មដោយបង្ខំក្នុងអត្រាខ្ពស់ជាងគេនៅគ្រប់សូចនាករទាំងអស់ ដែលខ្ពស់ជាងពលករចំណាកស្រុកស្ត្រី។

*រូបភាព ៣៖ សូចនាករស្តីពីពលកម្មដោយបង្ខំសំខាន់ៗតាមយេនឌ័រ*



ក្រុមការងារក៏បានសង្កេតឃើញអំពីការប្រែប្រួលពេលប្រៀបធៀបរបកគំហើញនៅទូទាំងឧស្សាហកម្មចម្បងៗទាំង៣ ដែលពលករចំណាកស្រុកកម្ពុជាបម្រើការងារ។ ភាគរយនៃពលករចំណាកស្រុក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោមការកំណត់របស់អង្គការពលកម្មអន្តរជាតិអំពីពលកម្មដោយបង្ខំ គឺខ្ពស់បំផុតនៅក្នុងវិស័យកសិកម្ម (៨៣,១៩%)។ ភាគរយនៅក្នុងវិស័យសំណង់ និង រោងចក្រគឺមាន ៣៩,១៨% និង ៣៧,៥៣% ។ លើសពីនេះ ការវាស់ស្ទង់ការវាស់វែងពលកម្មដោយបង្ខំធ្ងន់ធ្ងរបំផុតមួយទៀត រួមទាំង ការរំលោភបំពានលើសុចរិតភាពផ្លូវកាយ និង ការរឹតត្បិតសេរីភាព អត្រារងគ្រោះគឺមានកម្រិតខ្ពស់បំផុតក្នុងចំណោមពលករចំណាកស្រុកកម្ពុជានៅក្នុងវិស័យកសិកម្ម។ ម្យ៉ាងវិញទៀត ពលករចំណាកស្រុកដ៏ច្រើននៅក្នុងវិស័យរោងចក្របានជួបប្រទះនឹងការអនុវត្តការងារមានលក្ខណៈរំលោភបំពាន (៦១,១២%) ឬបានជួបប្រទះ បរិយាកាសការងារដែលឆបោកអយុត្តិធម៌ឬអសុវត្ថិភាព (៣០,៩២%) បើធៀបទៅនឹងពលករនៅក្នុងវិស័យសំណង់ (៥២,៣២%. ២៨,២៥%) និងកសិកម្ម (៥១,៥៨%. ២៥,៨៩%)។

ភាគរយនៃពលករចំណាកស្រុក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោមការកំណត់របស់អង្គការពលកម្មអន្តរជាតិអំពី ពលកម្មដោយបង្ខំ គឺខ្ពស់បំផុតក្នុងវិស័យកសិកម្ម (៨៣,១៩%)។

*រូបភាព ៩៖ សូចនាករស្តីពីពលកម្មដោយបង្ខំសំខាន់ៗតាមវិស័យ*




លទ្ធផលនេះ ក៏បានបង្ហាញអំពីភាពប្រែប្រួលនៅទូទាំងខេត្តដែលបានស្ទង់មតិផងដែរ។ ភាគរយនៃពលករចំណាកស្រុកមកពីខេត្តកំពង់ចាម និងព្រៃវែង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមនិយមន័យរបស់អង្គការពលកម្មអន្តរជាតិអំពីពលកម្មដោយបង្ខំ គឺមានចំនួនខ្ពស់ជាងគេបំផុត ពោលគឺមាន ៥១,៣៤% និង ៥១,៧៨% រៀងគ្នា។ ពលករចំណាកស្រុកមកពីខេត្តបន្ទាយមានជ័យ និងកំពង់ចាម បានរាយការណ៍ថាមានអត្រាខ្ពស់ជាងគេនៃការទទួលរងការបំពេញការងារដែលមានការរំលោភបំពានឬដោយបង្ខំ (៧១,៨៨% និង ៦៩,៦០%)។ ម្យ៉ាងវិញទៀត ពលករចំណាកស្រុកមកពី

ខេត្តសៀមរាប បានរាយការណ៍ថា មានអត្រារងគ្រោះខ្ពស់បំផុតនៅក្នុងបរិយាកាសការងារដែលឆបោក អយុត្តិធម៌ឬអសុវត្ថិភាព (៣៦,០០%) និងងាយនឹងទទួលរងសោហ៊ុយច្រើនហួសហេតុក្នុងការចាកចេញពីបរិយាកាសការងារដែលមានការរំលោភបំពាន (៧០,០០%)។

*រូបភាព ៥៖ សូចនាករស្តីពីពលកម្មដោយបង្ខំសំខាន់ៗតាមវិស័យ*



## ទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌

ក្រុមការងារបានស្វែងយល់ផងដែរអំពីឥរិយាបថ និងទំនុកចិត្តរបស់ពលករចំណាកស្រុកមកលើប្រព័ន្ធយុត្តិធម៌ នៅពេលជួបប្រទះ ឬសង្កេតឃើញការរំលោភបំពាននៅក្នុងការងាររបស់ពួកគេ យើងបានវាស់ស្ទង់ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ តាមរយៈការសួរសំណួរមួយចំនួនទៅកាន់អ្នកឆ្លើយតបថាតើពួកគេបានរាយការណ៍អំពីការរំលោភបំពានពលកម្មណាមួយទៅកាន់អាជ្ញាធរកាលពីមុនដែរឬទេ ថាតើពួកគេនឹងធ្វើការរាយការណ៍ដែរឬទេក្នុងករណីទទួលរងគ្រោះនាពេលអនាគត និងមូលហេតុនៃការរាយការណ៍។

> អ្នកឆ្លើយតប បានបង្ហាញអំពីកម្រិតទុកចិត្តខ្ពស់មកលើអាជ្ញាធរ ពេលសួរនាំអំពីលំដាប់សំណួរក្នុងសេណារីយ៉ូសន្មតថាពួកគេត្រូវបានគេធ្វើបាបរាងកាយ បង្ខាំង ឬទទួលរងការរំលោភបំពានពេលធ្វើការងារនៅក្រៅប្រទេស។

### ◢ ការចូលរួមប៉ាន់ប្រមាណប្រមាណជាមួយប្រព័ន្ធយុត្តិធម៌

សរុបរួម អ្នកឆ្លើយតប បានបង្ហាញអំពីកម្រិតទុកចិត្តខ្ពស់មកលើអាជ្ញាធរ នៅពេលដែលសួរនាំអំពីលំដាប់សំណួរនៅក្នុងសេណារីយ៉ូសន្មតថា ពួកគេត្រូវបានគេធ្វើបាបផ្លូវកាយ បង្ខាំង ឬទទួលរងការរំលោភបំពាននៅពេលធ្វើការងារនៅក្រៅប្រទេស។ ក្នុងកាលៈទេសៈបែបនេះ អ្នកឆ្លើយតបលើសពីពាក់កណ្តាលបន្តិច (៥២,៣០%) នឹងទុកចិត្តលើមន្ត្រីនគរបាលមេធាវី ឬមន្ត្រីរដ្ឋាភិបាលនៅក្នុងប្រទេសដែលពួកគេធ្វើការជាប្រភពនៃការស្វែងរកជំនួយ។ ជម្រើសបន្ត គឺសមាជិកគ្រួសារ (៣៦,៧៧%) មន្ត្រីនគរបាលកម្ពុជា (២១,៧៩%) និង អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមកិច្ចផ្សេងៗ (១៥,២០%)។

*រូបភាព ៦៖ តើបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលខាងក្រោមដែលអ្នកឆ្លើយតបនឹងទុកចិត្តក្នុងការស្វែងរកជំនួយ?*




អ្នកឆ្លើយតបកៅសិបបីភាគរយបាននិយាយថា ពួកគេនឹងរាយការណ៍អំពីហេតុការណ៍បែបនេះ ប្រសិនបើពួកគេក្លាយជាជនរងគ្រោះស្របពេលដែលធ្វើការងារនៅក្រៅប្រទេស។ មូលហេតុចម្បងដែលនឹងជំរុញឱ្យអ្នកឆ្លើយតបរាយការណ៍អំពីហេតុការណ៍ រួមមាន៖ ពួកគេទាមទាររកយុត្តិធម៌សម្រាប់ការរងគ្រោះរបស់ពួកគេ (៩២,៤៩%) ពួកគេចង់ត្រលប់ទៅផ្ទះវិញ (២៣,៨៦%) និងពួកគេចង់បានប្រាក់ដែលពួកគេមានសិទ្ធិត្រូវទទួលបាន (២១,៥៤%)។

*រូបភាព ៧៖ តើកត្តាអ្វីដែលនឹងជំរុញឱ្យអ្នករាយការណ៍អំពីការរំលោភបំពាន?*




ទោះជាយ៉ាងនេះក្តី អាចនឹងមានការប៉ាន់ប្រមាណលើសកម្រិតអំពីអ្នកឆ្លើយតបមួយផ្នែកបង្ហាញអំពីឆន្ទៈក្នុងការរាយការណ៍អំពីការរំលោភបំពាន។ ដូចដែលបានកត់សម្គាល់ក្នុងផ្នែកដែនកំណត់ ការស្ទង់មតិនេះ ត្រូវបានធ្វើឡើងជាមួយពលករដែលបានត្រលប់មកវិញ ដែលធ្លាប់បញ្ចប់កិច្ចសន្យាពីមុនរបស់ពួកគេ មិនថាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្តី។ ភាពលម្អៀងតាមបរិបទសង្គមអាចនឹងកើតមាន ពេលអ្នកឆ្លើយតបទាំងនេះបានលើកឡើងអំពីលទ្ធភាពដែលពួកគេនឹងរាយការណ៍អំពីហេតុការណ៍។ ការនិយាយថា ពួកគេនឹងរាយការណ៍អំពីហេតុការណ៍ នឹងត្រូវបានអ្នកដទៃគិតថាជាចម្លើយល្អ និងជាការឆ្លើយតបដែលសង្គមចង់បាន។ លើសពីនេះ ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះ អាចនឹងមិនសូវបារម្ភអំពីប្រតិកម្មតបឬការសងសឹកដែលអាចកើតមាន ដែលអាចកើតឡើងពីការរាយការណ៍អំពីការរំលោភបំពានពលកម្មដោយបង្ខំ បើធៀបទៅនឹងពលករចំណាកស្រុក ដែលបច្ចុប្បន្នកំពុងបម្រើការងារក្នុងប្រទេសគោលដៅពេលធ្វើការស្ទង់មតិនេះ។ ដូច្នេះ ពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះ អាចនឹងទំនងជានិយាយថា ពួកគេនឹងរាយការណ៍អំពីការរំលោភបំពានពលកម្មដោយបង្ខំ ប្រសិនបញ្ហានេះកើតឡើងលើពួកគេ ដោយសារបច្ចុប្បន្ននេះពួកគេបានរួចផុតពីផលវិបាកអវិជ្ជមានណាមួយនៃការរាយការណ៍ហើយ។

បន្ទាប់មក អ្នកឆ្លើយតបទាំងនេះត្រូវបានតាមដាន ដើម្បីកំណត់អត្តសញ្ញាណទីភ្នាក់ដែលពួកគេនឹងរាយការណ៍អំពីគ្រោះថ្នាក់ ដែលអ្នកឆ្លើយតបចន្លោះពី ១២% ទៅ ២៣% បានលើកឡើងអំពីអាជ្ញាធរជាច្រើននៅទាំងក្នុងកម្ពុជា និងនៅប្រទេសគោលដៅ។ ការបែងចែកទូលំទូលាយនៃចម្លើយដែលបានជ្រើសរើស អាចនឹងឆ្លុះបញ្ចាំងអំពីកង្វះផែនទីបង្ហាញផ្លូវច្បាស់លាស់អំពីការរាយការណ៍អំពីការរំលោភបំពានដែលអាចកើតមានក្នុងចំណោមពលករចំណាកស្រុក។

*រូបភាព ៨៖ តើទីភ្នាក់ងារណាមួយដែលអ្នកនឹងរាយការណ៍អំពីបទល្មើស?*



លើសពីនេះ មានទីភ្នាក់ងារដែលបានកំណត់អត្តសញ្ញាណមួយចំណែកតូចប៉ុណ្ណោះ ដែលជាទីភ្នាក់ងារអនុវត្តច្បាប់ពិតប្រាកដ – នគរបាលមូលដ្ឋាន ឬនគរបាលជាតិ ក្នុងប្រទេសប្រភព និងប្រទេសគោលដៅ (កំណត់សម្គាល់ពណ៌ខៀវនៅក្នុងតួលេខខាងលើ)។ ទីភ្នាក់ងារផ្សេងទៀត ដូចជាស្ថានទូត មេភូមិ និងមន្ត្រីនៅនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅកម្ពុជា គឺមិនទាន់បានបង្កើតឡើងដោយច្បាប់ ដើម្បីទទួលបណ្ដឹងការងារពាក់ព័ន្ធនឹងការរំលោភបំពានដែលកើតឡើងនៅក្នុងប្រទេសគោលដៅនៅឡើយទេ។ ស្ថាប័នទាំងនេះអាចនៅតែទទួលបណ្ដឹង ប៉ុន្តែនឹងចាំបាច់ត្រូវបញ្ជូនបណ្ដឹងទាំងនោះទៅកាន់អង្គភាពអនុវត្តច្បាប់ ដើម្បីដោះស្រាយករណីទាំងនេះ។ នៅក្នុងបរិបទនេះ នៅពេលដែលយើងវាយតម្លៃបន្ថែមទៅលើ "ភាពសមស្រប" នៃអាជ្ញាធរទាំងនេះ ដែលអ្នកឆ្លើយតបតិចជាងពាក់កណ្ដាល ដែលនឹងរាយការណ៍អំពីគ្រោះថ្នាក់ (៤៤,១៣%) បានកំណត់អត្តសញ្ញាណទីភ្នាក់ងារបានត្រឹមត្រូវ ដែលនឹងមានប្រសិទ្ធភាពបំផុតក្នុងការទទួល និងស៊ើបអង្កេតអំពីការរំលោភបំពានដែលអាចកើតមាន ឧទាហរណ៍ នគរបាល ឬតម្រួតនៅក្នុងប្រទេសគោលដៅ។ ចន្លោះខ្វះខាតនៃចំណេះដឹងនេះ អាចបង្កជាឧបសគ្គរាំងដល់ពលករចំណាកស្រុក ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយប្រព័ន្ធយុត្តិធម៌ ដើម្បីទទួលបានសិទ្ធិរបស់ពួកគេក្នុងការទទួលបានការពារនៅពេលអនាគត។

កង្វះខាតចំណេះដឹងនេះអាចបង្កជាឧបសគ្គរាំងដល់ពលករចំណាកស្រុកក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយប្រព័ន្ធយុត្តិធម៌ ដើម្បីទទួលបានសិទ្ធិរបស់ពួកគេក្នុងការទទួលបានការពារនាពេលអនាគត។



## ◢ បទពិសោធន៍ពីមុនជាមួយប្រព័ន្ធយុត្តិធម៌

អ្នកចូលរួមក្នុងការសិក្សាដប់ភាគរយ បានរាយការណ៍ថាធ្លាប់ទទួលរង ឬបានអង្កេតឃើញការប្រព្រឹត្តចំពោះដោយពុំស្មើភាព ឬខុសច្បាប់ពីសំណាក់និយោជក ឬអ្នកជ្រើសរើសពលករ។ អ្នកឆ្លើយតបទាំងនេះស្ទើរតែទាំងអស់ (៩៨,៣៥%) បានរាយការណ៍អំពីការប្រព្រឹត្តចំពោះដោយគ្រោះថ្នាក់ដល់អាជ្ញាធរ។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនេះ អ្នកឆ្លើយតប ៩៦,៤០% បានរាយការណ៍អំពីការទទួលរងរបស់ពួកគេ ដោយសារពួកគេចង់បានយុត្តិធម៌សម្រាប់ការទទួលរងគ្រោះរបស់ពួកគេ អ្នកឆ្លើយតប ៤៥,២៨% ចង់ទទួលបានប្រាក់ដែលគេជំពាក់ពួកគាត់ និងអ្នកឆ្លើយតប ២៧,២៩% ចង់ចាកចេញពីកន្លែងធ្វើការដែលមានលក្ខណៈរំលោភបំពាន និងត្រលប់ទៅផ្ទះវិញ។ របកគំហើញ គឺមានសង្គតិភាពជាមួយអ្វីដែលយើងបានរកឃើញក្នុងសេណារីយ៉ូប៉ាន់ប្រមាណ។

*រូបភាព ៩៖ មូលហេតុដែលអ្នកឆ្លើយតបបានសម្រេចចិត្តរាយការណ៍អំពីបទពិសោធន៍ទាំងនេះ*



គួរឱ្យកត់សម្គាល់ ការរងគ្រោះដែលបានរាយការណ៍ដោយខ្លួនឯង គឺមានកម្រិតទាបជាងការប៉ាន់ប្រមាណអំពីពលកម្មដោយបង្ខំដែលបានផ្តល់ជូនខាងលើ។ ភាពលម្អៀងដ៏ធំនេះ អាចដោយសារតែអ្នកឆ្លើយតបមួយផ្នែកធំ គឺមិនបានដឹងអំពីការរំលោភលើសិទ្ធិដែលពួកគេមាន ទោះបីជាពួកគេបានជួបប្រទះនឹងការប្រព្រឹត្តចំពោះដោយរំលោភបំពានក្តី។

ទោះជាយ៉ាងនេះក្តី គួរឱ្យកត់សម្គាល់ថា ចំណែកនៃការរងគ្រោះដែលរាយការណ៍ដោយខ្លួនឯង ដែលមាន ១០,០២% គឺមានកម្រិតទាបជាងការប៉ាន់ប្រមាណខ្លាំងណាស់ដូចដែលបានផ្តល់ជូននៅខាងលើ (៣៩,៥៩% ស្របតាមនិយមន័យរបស់អង្គការពលកម្មអន្តរជាតិអំពីពលកម្មដោយបង្ខំ)។ ភាពលម្អៀងដ៏ធំនេះ អាចដោយសារតែអ្នកឆ្លើយតបមួយផ្នែកធំ គឺមិនបានដឹងអំពីការរំលោភលើសិទ្ធិដែលពួកគេមាន ទោះបីជាពួកគេបានជួបប្រទះនឹងការប្រព្រឹត្តចំពោះដោយរំលោភបំពានក្តី។ អ្នកឆ្លើយតបដែលបានជ្រើសរើសរាយការណ៍ គឺទំនងជាទទួលរងគ្រោះពីការរំលោភបំពានធ្ងន់ធ្ងរបំផុត ដូច្នេះ ពួកគេគឺមានការជំរុញទឹកចិត្តឱ្យរាយការណ៍អំពីឧប្បត្តិហេតុ។ ដូច្នេះ សំណួរស្ទង់មតិនេះ អាចនឹងមានការប៉ាន់ប្រមាណលើសអំពីអត្រារាយការណ៍។

ការពន្យល់បកស្រាយ គឺត្រូវបានអះអាងបន្ថែមដោយការយល់ដឹង ឬការយល់ឃើញមិនគ្រប់គ្រាន់ពាក់ព័ន្ធនឹងសិទ្ធិរបស់ពួកគាត់ ក្នុងចំណោមពលករចំណាកស្រុកកម្ពុជា។ អ្នកឆ្លើយតបលើសពី ៥០% បន្តិច មិនដែលធ្លាប់បានឮអំពីសិទ្ធិ ឬច្បាប់របស់ពួកគាត់នៅក្នុងប្រទេសគោលដៅ មុនពេលចេញទៅបម្រើការងារ។ អ្នកឆ្លើយតប ១៨,៩៦% ក៏បានរាយការណ៍អំពីការត្រូវបានគេបោកប្រាស់អស់ប្រាក់កាសជាច្រើនពីសំណាក់និយោជក ឬអ្នកជ្រើសរើសពលករ ក្នុងអំឡុងពេលចំណាកស្រុកពីមុនរបស់ពួកគេ។



# ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

ដូចបានបង្ហាញក្នុងផ្នែករបកគំហើញខាងលើ សូចនាកររបស់អង្គការពលកម្មអន្តរជាតិ (ILO) កម្រិតវិសាលភាពនៃគ្រោះថ្នាក់របស់ ណេក និងចំណុចចាប់ផ្តើមពីរជំហានរបស់ មជ្ឈមណ្ឌលស្រាវជ្រាវ ណេក (NORC) បានបង្ហាញអំពីលំនាំប្រេវ៉ាឡង់នៃការរំលោភបំពានពលកម្មដោយបង្ខំក្នុងចំណោមក្រុមប្រជាជនដែលបានកំណត់សម្រាប់ការស្រាវជ្រាវនេះ។ វិសាលភាពនៃការរំលោភបំពានពលកម្មដោយបង្ខំក្នុងចំណោមអ្នកឆ្លើយតប គឺមានការប្រែប្រួលមួយចំនួន។ តាមរយៈការប្រើប្រាស់សូចនាករស្តីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ (ការរួមបញ្ចូលគ្នានៃការគំរាមដាក់ទណ្ឌកម្ម និងការរំលោភបំពានដោយបង្ខំ) ការប៉ាន់ប្រមាណបានបង្ហាញថា ពលករចំណាកស្រុក៩នាក់ ក្នុងចំណោម ១០ នាក់ដែលមកពីកម្ពុជា ទំនងជាទទួលរងនូវការរំលោភបំពានយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលធ្វើការងារនៅក្នុងប្រទេសគោលដៅ។ តាមរយៈការប្រើប្រាស់ការវាស់ស្ទង់របស់ មជ្ឈមណ្ឌលស្រាវជ្រាវ ណេក អត្រារងគ្រោះប៉ាន់ប្រមាណក្នុងការរំលោភបំពានណាមួយ ក្នុងចំណោមការរំលោភបំពានដែលបានរៀបរាប់នៅក្នុងកម្រិតវិសាលភាពនៃគ្រោះថ្នាក់ មានចន្លោះពី ១៣,៦១% ក្នុងប្រភេទធ្ងន់ធ្ងរបំផុត (ការរំលោភបំពានលើសុច្ចរិតភាពផ្លូវកាយ) រហូតដល់ ៥៧,៣១% នៅក្នុងប្រភេទមធ្យមនៃការរំលោភបំពាន (ការបំពេញការងារដែលមានការរំលោភបំពាន/ដោយបង្ខំ)។ ចំពោះការចំណាយលើការចាកចេញច្រើនហួសហេតុវិញ យើងបានប៉ាន់ប្រមាណថា ពលករចំណាកស្រុកកម្ពុជា ៥៣,២១% បានជួបប្រទះនឹងការរំលោភបំពានមួយក្នុងចំណោមការរំលោភបំពានដែលបានវាស់ស្ទង់ និង ពុំមានលទ្ធភាពឈប់ពីការងារនោះទេ ដោយសារភ័យខ្លាចទទួលរងនូវផលវិបាកធ្ងន់ធ្ងរ។ ក្នុងនោះ ផលវិបាកធ្ងន់ធ្ងរ រួមមាន៖ ការរឹបអូសប្រាក់ចំណូលដែលរកបាន ទ្រព្យសម្បត្តិមានតម្លៃ ឯកសារអត្តសញ្ញាណ ការបង្ខូចកេរ្តិ៍ឈ្មោះដល់សាម៉ីពលករដោយចេតនា ឬការគំរាមកំហែងពាក់ព័ន្ធនឹងនឹងអាជ្ញាធរជាដើម។ លទ្ធផលនេះក៏បានបង្ហាញឱ្យឃើញផងដែរអំពីការប្រែប្រួលមួយចំនួនពាក់ព័ន្ធនឹងយេនឌ័ររបស់ពលករចំណាកស្រុក ឧស្សាហកម្មដែលពួកគេបានធ្វើការ និងខេត្តដែលពួកគេរស់នៅ។

បណ្តាញសង្គម និងគ្រួសារ គឺជាបណ្តាញជ្រើសរើសពលករញឹកញាប់បំផុតក្នុងចំណោមពលករចំណាកស្រុកនៅកម្ពុជាដែលក្នុងនោះ ពីរភាគបីនៃអ្នកឆ្លើយតបសរុប បានទទួលការងារនៅក្នុងប្រទេសគោលដៅតាមរយៈគ្រួសារ ឬមិត្តភក្តិ។ អ្នកឆ្លើយតបប្រមាណ ១១,២១% ទៀត បានទទួលការងារតាមរយៈទីភ្នាក់ងារជ្រើសរើសពលករដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាលកម្ពុជា។ អ្នកឆ្លើយតប កម្រនឹង ទទួលបានការងារតាមរយៈទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលពុំបានចុះបញ្ជីជាមួយរដ្ឋាភិបាលណាស់ (២,៨២%)។

ពលករចំណាកស្រុកកម្ពុជា ក៏ទទួលបានការរ៉ាប់រងបន្ទុកហិរញ្ញវត្ថុលើការបង់ថ្លៃសេវាចំណាកស្រុក និងការងារនៅក្រៅប្រទេសផងដែរ។ ច្រើនជាង ៥០% នៃអ្នកឆ្លើយតបសរុប ប្រាប់ថាពួកគេចាំបាច់ត្រូវយកកម្ចី ដើម្បីបង់កម្រៃជ្រើសរើសការងារ និងចំណាយពាក់ព័ន្ធផ្សេងៗដើម្បីរក្សាការងារនៅក្រៅប្រទេស។ ចំនួនទឹកប្រាក់កម្ចីជាមធ្យម គឺមានចំនួន ៣.៦៦៦.៨២៧ រៀល (ប្រហែល ៨៩០ ដុល្លារអាមេរិក)។ ចំនួនទឹកប្រាក់កម្ចីនេះ គឺមានចន្លោះទាបបំផុតចំនួន ៣០០.០០០ រៀល (ប្រហែល ៧០ ដុល្លារអាមេរិក) ទៅដល់ខ្ពស់បំផុតចំនួន ១២០.០០០.០០០ រៀល (ប្រហែល ២៩.២៦៨ ដុល្លារអាមេរិក) ដែលកត្តានេះបានបង្ហាញអំពីភាពខុសគ្នាជាខ្លាំងលើស្ថានភាពផ្ទាល់ខ្លួនរបស់ពលករ។ ចំពោះប្រភពប្រាក់កម្ចីវិញ មិត្តភក្តិ និងសមាជិកគ្រួសារ គឺជាប្រភពផ្តល់កម្ចីធំបំផុត (៤០,៩៥%) បន្ទាប់មកគឺធនាគារ (៣០,៧៦%) និងនិយោជក (១៨,០៩%)។ សម្ពាធហិរញ្ញវត្ថុបង្កដោយកម្ចី ក៏ដូចជាលទ្ធភាពនៃកម្ចីជាន់គ្នារវាងអ្នកជ្រើសរើសពលករ និយោជក និងអ្នកឱ្យកម្ចី អាចធ្វើឱ្យពលករចំណាកស្រុកកម្ពុជាកាន់តែងាយរងគ្រោះថែមទៀត។

អ្នកដែលបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ បានបង្ហាញអំពីទំនុកចិត្តកម្រិតខ្ពស់លើប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសគោលដៅ និងប្រទេសកំណើតរបស់ពួកគេ។ អ្នកឆ្លើយតបស្ទើរតែជិត ៩៤% បាននិយាយថា ពួកគេនឹងរាយការណ៍អំពីការរំលោភបំពានពលកម្មដោយបង្ខំដែលអាចកើតឡើងទៅកាន់អាជ្ញាធរពាក់ព័ន្ធ។ បើទោះបីជាតួលេខនេះ បានបង្ហាញអំពីឆន្ទៈកម្រិតខ្ពស់ក្នុងការរាយការណ៍ក៏ដោយ ក៏ពុំមែនមានន័យថា ពលករចំណាកស្រុកស្ទើរតែទាំងអស់នឹងធ្វើការរាយការណ៍ (ឬ ព្យាយាមរាយការណ៍) ប្រកបដោយប្រសិទ្ធភាព អំពីការរំលោភបំពានដែលពួកគេជួបប្រទះនោះដែរ។ ទី១ នៅក្នុងការសាកសួរសំណួរបន្តបន្ទាប់ អ្នកឆ្លើយតបតិចជាង ៥០% ដែលមានឆន្ទៈរាយការណ៍ (៤៤,១៣%) បានកំណត់អត្តសញ្ញាណអាជ្ញាធរដែលពាក់ព័ន្ធបានយ៉ាងត្រឹមត្រូវ។ លើសពីនេះទៅទៀត ពេលអ្នកឆ្លើយតបឆ្លើយនឹងសំណួរពាក់ព័ន្ធនឹងឥរិយាបថ គឺអាចនឹងមានការលម្អៀងគ្នាខ្លះ។ យោងតាមសំណាកពលករចំណាកស្រុកដែលទើបត្រលប់មកស្រុកកំណើតវិញថ្មីៗ អាចនឹងមានការប៉ាន់ប្រមាណលើសកម្រិតអំពីឆន្ទៈរបស់ពលករក្នុងការរាយការណ៍អំពីការរំលោភបំពាន ដោយសារពួកគេបានបញ្ចប់ពីកិច្ចសន្យាពីមុនរបស់ពួកគេ ពុំថាទាំងផ្នែកផ្លូវកាយ និងស្មារតី ដែលក្រុមការងារអាចនិយាយបានម្យ៉ាងទៀតថា ពួកគេទំនងជា "ងាយស្រួលក្នុងការនិយាយ" ថាពួកគេនឹងរាយការណ៍អំពីការរំលោភបំពាននានា។ ទីពីរ អ្នកឆ្លើយតបអាចអះអាងថា ពួកគេនឹងរាយការណ៍អំពីការរំលោភបំពាន ប្រសិនបើពួកគេជឿថា មន្ត្រីអង្កេតសម្ភាសន៍ នឹងឯកភាពលើចម្លើយដែលបានផ្តល់ឲ្យនោះ (ភាពលម្អៀងតាមបរិបទសង្គម)។ បើសង្កេតទៅលើសេណារីយ៉ូប៉ាន់ប្រមាណវិញ អ្នកឆ្លើយតប ១០,០២% បានរាយការណ៍ថា ពួកគេពិតជាធ្លាប់បានទទួលរង ឬបានសង្កេតឃើញថាមានការប្រព្រឹត្តចំពោះពលករដោយពុំស្មើភាព ឬខុសច្បាប់ពីសំណាក់និយោជក ដែលក្នុងនោះ ៩៨,៣៥% បាននិយាយថា ពួកគេបានរាយការណ៍អំពីការរំលោភបំពានទាំងនេះទៅកាន់អាជ្ញាធរ។ ភាពមិនស៊ីសង្វាក់គ្នារវាងអត្រារងគ្រោះដែលបានរាយការណ៍ដោយខ្លួនឯង (១០,០២%) និង អត្រារងគ្រោះដែលក្រុមការងារស្រាវជ្រាវបានប៉ាន់ប្រមាណដោយប្រើប្រាស់សូចនាកររបស់អង្គការពលកម្មអន្តរជាតិ (៣៩,៥៩%) បង្ហាញថា ការរំលោភបំពានពលកម្មដោយបង្ខំកម្រិតមធ្យមមួយចំនួនអាចនឹងពុំមានការទទួលស្គាល់ និងមិនបានរាយការណ៍។ ការណ៍នេះអាចនិយាយបានម្យ៉ាងទៀតថា អ្នកដែលបានទទួលស្គាល់ថា ពួកគេបានជួបប្រទះ ឬបានឃើញនូវការប្រព្រឹត្តចំពោះពលករដោយរំលោភបំពាន គឺទំនងជាស្ថិតនៅក្នុងប្រភេទនៃការរំលោភបំពានកាន់តែធ្ងន់ធ្ងរ និងអាចនឹងមានការជំរុញទឹកចិត្តបន្ថែមឱ្យធ្វើការរាយការណ៍អំពីបទល្មើសនេះ។



## អនុសាសន៍

### អន្តរាគមន៍ដែលផ្តោតលើភាពងាយរងគ្រោះដែលត្រូវបានលាក់បាំងក្នុងខ្សែសង្វាក់ជ្រើសរើសពលករតាមអ្នកស្គាល់គ្នា

ចំពោះពលករចំណាកស្រុកកម្ពុជា បណ្តាញជ្រើសរើសពលករសាយភាយធំបំផុត គឺតាមរយៈគ្រួសារ ឬទំនាក់ទំនងមិត្តភក្តិក្នុងប្រទេសគោលដៅ។ បណ្តាញក្រៅផ្លូវការនេះ ទំនងជាអាវុធមុខពីរ។ ទី១ បណ្តាញនេះផ្តល់ភាពងាយស្រួល និងប្រភពដែលអាចជឿទុកចិត្តបានសម្រាប់អ្នកស្វែងរកការងារជាច្រើន ដែលកំពុងស្វែងរកការងារធ្វើនៅក្រៅប្រទេស។ ចំណុចមួយទៀតគឺថា បណ្តាញបែបនេះ អាចនាំឱ្យពលករចំណាកស្រុកពប្រុងប្រយ័ត្ន និងពិនិត្យពិច័យក្នុងកម្រិតទាបជាងមុន នៅពេលស្វែងរកជម្រើសការងារ និងធ្វើការសម្រេចចិត្តទទួកយកការងារ។ ស្របពេលមានកម្មវិធីជាច្រើនប្រឆាំងទៅនឹងអំពើជួញដូរកម្លាំងពលកម្ម ដោយផ្តោតលើអាជ្ញាប័ណ្ណ និងសមត្ថភាពរបស់ទីភ្នាក់ងារ និងមេខ្យល់ជ្រើសរើសពលករនោះ ទិន្នន័យការសិក្សាស្រាវជ្រាវនេះ បានរកឃើញអំពីភាពងាយរងគ្រោះលាក់កំបាំងដែលអាចពាក់ព័ន្ធនឹងបណ្តាញអ្នកស្គាល់គ្នា (គ្រួសារ និងមិត្តភក្តិ) ។ លើសពីនេះ គ្រួសារ និងមិត្តភក្តិនេះ ក៏ដើរតួនាទីជាអ្នកផ្តល់កម្ចីចម្បងដល់ពលករចំណាកស្រុកផងដែរពាក់ព័ន្ធនឹងការរ៉ាប់រងលើថ្លៃចំណាយចំណាកស្រុករបស់ពួកគេ។ អ្នកជ្រើសរើសពលករ និងអ្នកផ្តល់កម្ចីនេះអាចជាមនុស្សតែមួយ ពោលគឺបង្កស្ថានភាពពលករចំណាកស្រុកកាន់តែងាយរងគ្រោះ និងស្មុគស្មាញថែមទៀត។

> ស្របពេលដែលមានកម្មវិធីជាច្រើនប្រឆាំងទៅនឹងអំពើជួញដូរកម្លាំងពលកម្ម ដោយផ្តោតលើអាជ្ញាប័ណ្ណ និងសមត្ថភាពរបស់ទីភ្នាក់ងារ និងមេខ្យល់ជ្រើសរើសពលករនោះ ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ បានរកឃើញអំពីភាពងាយរងគ្រោះលាក់កំបាំងដែលអាចពាក់ព័ន្ធនឹងបណ្តាញអ្នកស្គាល់គ្នា (គ្រួសារ និងមិត្តភក្តិ។

### ការលើកកម្ពស់ការយល់ដឹងក្នុងចំណោមសហគមន៍ពលករចំណាកស្រុកពាក់ព័ន្ធនឹងសិទ្ធិ ឬច្បាប់

ទិន្នន័យរបស់ការសិក្សាស្រាវជ្រាវនេះ បង្ហាញអំពីកង្វះការយល់ដឹងនៅក្នុងចំណោមសហគមន៍ពលករចំណាកស្រុកពាក់ព័ន្ធនឹងសិទ្ធិរស់នៅ និងសិទ្ធិការងារ ព្រមទាំង សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ ។ ភាពខ្វះខាតនៃព័ត៌មាន ធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការធ្វើចំណាកស្រុកដែលពុំមានសុវត្ថិភាព និង បរិយាកាសការងារដែលមានការរំលោភបំពាន។ ដូច្នេះ ការបង្កើនការយល់ដឹងរបស់ពលករចំណាកស្រុក មុនពេលចេញដំណើរទៅបម្រើការងារ គឺពិតជាមានសារៈសំខាន់ណាស់។ ឧទាហរណ៍ ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមកិច្ចពាក់ព័ន្ធ អាចដាក់ចេញនូវយុទ្ធនាការអប់រំ និងចុះផ្តល់ព័ត៌មានតាមមូលដ្ឋានដល់ពលករចំណាកស្រុកទាំងនេះ អំពីការងារ កិច្ចសន្យា ហានិភ័យដែលអាចកើតមាន ប្រភេទនៃការកេងប្រវ័ញ្ច ការរំលោភបំពានទូទៅ និងចំណេះដឹង ឬការអនុវត្តជាក់ស្តែងអំពីការការពារសិទ្ធិរបស់ពួកគេ ព្រមទាំងការស្វែងរកជំនួយផ្សេងៗនៅកម្ពុជា ក៏ដូចជានៅប្រទេសគោលដៅផងដែរ។ ខ្លឹមសារនៃយុទ្ធនាការ ឬការបណ្តុះបណ្តាល អាចកែតម្រូវបន្ថែមទៀតដើម្បីឱ្យសមស្របទៅតាមប្រទេសគោលដៅ យេនឌ័រ ឬវិស័យជាក់លាក់។ ពេលពលករចំណាកស្រុកកាន់តែច្រើនឡើងយល់ដឹងអំពីសិទ្ធិ និងអត្ថប្រយោជន៍ការងារដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ នោះការយល់ដឹងនិងការចាត់វិធានការរួមក៏នឹងមានការកើនឡើងផងដែរ ដើម្បីលើកកម្ពស់ស្ថានភាពចំណាកស្រុកជាទូទៅ។

## ការណែនាំច្បាស់លាស់អំពីធនធាន សេវាផ្លូវច្បាប់ និងយន្តការរាយការណ៍

> ការណែនាំអំពីគោលនយោបាយ និង យន្តការរាយការណ៍ច្បាស់លាស់ ចាំបាច់ត្រូវតែផ្តល់ជូនដល់ពលករចំណាកស្រុក ដើម្បីឱ្យពួកគេ ដឹងអំពីស្ថាប័នជាក់លាក់ (មួយ ឬច្រើន) ណាដែលមានដែនយុត្តាធិការនៅក្នុងស្ថានភាព ជាក់លាក់។

អ្នកឆ្លើយតប បានបង្ហាញអំពីការជឿទុកចិត្តកម្រិតខ្ពស់លើប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធនឹងការរាយការណ៍អំពីការអនុវត្ត ឬបរិយាកាសការងារដែលមានគ្រោះថ្នាក់។ ទោះបីជាមានឆន្ទៈរឹងមាំក្នុងការស្វែងរកជំនួយពីអាជ្ញាធរទាំងនេះក៏ដោយ ក៏ពលករចំណាកស្រុកទាំងនេះពុំទាន់យល់ដឹងច្បាស់លាស់នៅឡើយ ថាតើមធ្យោបាយ ទីភ្នាក់ងារពាក់ព័ន្ធ ឬនីតិវិធីណាមួយដែលសមស្របបំផុតក្នុងការរាយការណ៍អំពីការរំលោភបំពានដែលអាចកើតមានឡើង និងស្វែងរកការគាំទ្រផ្នែកច្បាប់។ ការណែនាំអំពីគោលនយោបាយ និង យន្តការរាយការណ៍ច្បាស់លាស់ គឺចាំបាច់ត្រូវតែផ្តល់ជូនដល់ពលករចំណាកស្រុកដើម្បីឱ្យពួកគេពលករចំណាកស្រុកដឹងអំពីស្ថាប័នជាក់លាក់ (ណាមួយ ឬច្រើន) ដែលមានដែនយុត្តាធិការនៅក្នុងស្ថានភាពជាក់លាក់។ លើសពីនេះ ទីភ្នាក់ងារ និងស្ថាប័នពាក់ព័ន្ធអាចរៀបចំធនធានគាំទ្រ ជំនួយគាំទ្រសេវាផ្លូវច្បាប់ដែលមាន ក៏ដូចជាព័ត៌មានអំពីទីតាំងជួយសង្គ្រោះក្នុងករណីមានគ្រោះអាសន្ន ព្រមទាំងផ្តល់ព័ត៌មានទាំងនេះជូនដល់ពលករចំណាកស្រុកដែលកិច្ចការនេះ គឺជាផ្នែកមួយនៃកញ្ចប់ឯកសារតម្រង់ទិសមុនពេលចាកចេញទៅបម្រើការងារ។

### ការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើភ្នាក់ងារជ្រើសរើសពលករ និងការពង្រីកលទ្ធភាពទទួលបានកម្ចីដែលសមរម្យ

អ្នកឆ្លើយតបច្រើនជាងពាក់កណ្តាលបាននិយាយថា ចាំបាច់ត្រូវយកកម្ចី ដើម្បីដោះស្រាយលើការធ្វើដំណើររបស់ពួកគេ។ ថ្លៃចំណាយខ្ពស់នៃចំណាកស្រុក មិនថាទាំងក្នុងទម្រង់នៃថ្លៃសេវាជ្រើសរើសការងារ ឬចំណាយផ្សេងៗនោះទេ គឺជាផ្នែកមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា និងការអន្តរាគមន៍កាន់តែច្រើនពីសំណាក់រដ្ឋាភិបាល។ មួយវិញទៀត រដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវធ្វើអធិការកិច្ចឱ្យបានដិតដល់លើសេវារបស់ភ្នាក់ងារជ្រើសរើសពលករជាច្រើន និងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិឱ្យបានតឹងរ៉ឹង ដើម្បីរាំងដល់ឥរិយាបថស្វែងរកការជួលការងារខុសប្រក្រតី និងរចនាសម្ព័ន្ធថ្លៃសេវាពាក់ព័ន្ធច្រើនហួសហេតុ។ម្យ៉ាងវិញទៀត ស្ថាប័នរដ្ឋាភិបាល និងសហគមន៍អាចធ្វើការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីផ្តល់កម្ចីដែលសមរម្យ និងកាលវិភាគសងប្រាក់សមរម្យដល់ពលករចំណាកស្រុក ដែលមានប្រវត្តិអាចជឿទុកចិត្តបាន។ អត្ថិភាពនៃកម្ចីការប្រាក់ទាប និងផែនការទូទាត់សងមានចីរភាព នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារពលករចំណាកស្រុកពីថ្លៃសេវាច្រើនហួសហេតុពីសំណាក់អ្នកផ្តល់កម្ចីឯកជន ឬអន្ទាក់បំណុល ដែលបង្កើនភាពងាយរងគ្រោះរបស់ពួកគេទៅក្នុងការរំលោភបំពានពលកម្មដោយបង្ខំ។

> ថ្លៃចំណាយខ្ពស់នៃការធ្វើចំណាកស្រុក មិនថាទាំងនៅក្នុងទម្រង់នៃថ្លៃសេវាជ្រើសរើសការងារ ឬចំណាយផ្សេងៗ ជាផ្នែកមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ដិតដល់ និងការអន្តរាគមន៍កាន់តែច្រើនពីសំណាក់រដ្ឋាភិបាល។



# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ I.
## នីតិវិធីជ្រើសសំណាកគំរូ និងការប៉ាន់ប្រមាណប្រជាជន

### សំណាកគំរូគោលដៅ ធៀបនឹងសំណាកគំរូជាក់ស្តែង

សរុបមក អ្នកប្រមូលទិន្នន័យបានកំណត់អត្តសញ្ញាណអ្នកឆ្លើយតបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សរុបចំនួន ១.៥៦៨ នាក់នៅទូទាំង ៤១៤ ភូមិ ក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនេះ មានអ្នកឆ្លើយតបចំនួន ១.២០៤ ត្រូវបានសម្ភាសន៍។ តារាង ១១ បង្ហាញព័ត៌មានលម្អិតអំពីចំនួនប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានជ្រើសរើសជាសំណាកគំរូតាមស្រុក ក៏ដូចជាចំនួនឃុំ និងភូមិដែលបានចុះប្រមូលទិន្នន័យ។

(ចំពោះឃុំ និងភូមិដែលអ្នកស្រាវជ្រាវបានចុះ ប៉ុន្តែរកឃើញថាពុំមានប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការសិក្សានេះ ត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានរួមបញ្ចូលនៅក្នុងការរាប់។)

*តារាង ១១៖ ប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានជ្រើសជាសំណាកគំរូតាមស្រុក*

| ស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនប្រជាជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | ចំនួនសំណាកគំរូ |
|---|---|---|---|---|
| បន្ទាយមានជ័យ | | | | |
| ម៉ាឡៃ | ៣ | ៧ | ៤០ | ៣៦ |
| មង្គលបុរី | ៣ | ៦ | ៣៦ | ៥២ |
| អូរជ្រៅ | ៣ | ៨ | ៣៩ | ៥៣ |
| ប៉ោយប៉ែត | ៣ | ៧ | ៣៦ | ៣៩ |
| ភ្នំស្រុក | ៣ | ៦ | ៣៩ | ៤៧ |
| ព្រះនេត្រព្រះ | ៣ | ៧ | ៣៦ | ៤៨ |
| សិរីសោភ័ណ | ៣ | ៨ | ៤២ | ៤៩ |
| ស្វាយចេក | ៣ | ៩ | ៣៦ | ៤៩ |
| កំពង់ចាម | | | | |
| បន្ទាយ | ៥ | ១៣ | ៤០ | ៤០ |
| កំពង់ចាម | ៣ | ៩ | ២៣ | ២៣ |
| កំពង់សៀម | ៦ | ១៧ | ៤១ | ៣៧ |
| កងមាស | ៦ | ២០ | ៣៧ | ៣៧ |

| | | | | |
|---|---|---|---|---|
| កោះសូទិន | ៦ | ១៥ | ៣៩ | ៣៦ |
| ព្រៃឈរ | ៤ | ១៧ | ៤៤ | ៤០ |
| ស្រីសន្ធរ | ៧ | ២០ | ៣៩ | ៣៧ |
| ស្ទឹងត្រង់ | ៥ | ១៧ | ៣៨ | ៣៨ |
| ចម្ការលើ (ជំនួស) | ១ | ៣ | ១៣ | ១៣ |
| ព្រៃវែង | | | | |
| កំចាយមារ | ៣ | ១៣ | ៦៣ | ៣៩ |
| កំពង់ត្របែក | ៤ | ១៦ | ៣៨ | ៣៦ |
| កញ្ជៀច | ៣ | ១២ | ៤៩ | ៤២ |
| មេសាង | ៣ | ១៥ | ៤៤ | ៣៧ |
| ពាមរ | ៥ | ១០ | ៣២ | ២៦ |
| ព្រៃវែង | ៤ | ១០ | ៣៨ | ២៤ |
| ពោធិ៍រៀង | ៤ | ១២ | ៥៩ | ៣៦ |
| ស៊ីធរកណ្ដាល | ៥ | ១៥ | ៤១ | ៣៥ |
| ពាមជរ (ជំនួស) | ៣ | ៥ | ២៧ | ២៥ |

| សៀមរាប | | | | |
|---|---|---|---|---|
| អង្គរធំ | ៤ | ៩ | ៥៤ | ៣៦ |
| ជីក្រែង | ៣ | ១៣ | ៤៩ | ៣៦ |
| ក្រឡាញ់ | ៣ | ៨ | ៤៦ | ៣៩ |
| ប្រាសាទបាគង | ៧ | ២០ | ៤១ | ៣៣ |
| សៀមរាប | ៦ | ២១ | ៤០ | ៣៨ |
| សូត្រនិគម | ៣ | ១០ | ៤៦ | ៣៨ |
| ស្វាយលើ | ៤ | ១៤ | ៤០ | ២៥ |
| បន្ទាយស្រី (ជំនួស) | ៣ | ៨ | ១៦ | ១៤ |
| ស្រីស្នំ (ជំនួស) | ១ | ១ | ៥ | ៥ |





## វិធីថ្លឹងថ្លែងសំណាកគំរូ

ការថ្លឹងថ្លែងសំណាកគំរូ ជាវិធីកំណត់ស្ថិតិមួយ ដែលប្រើប្រាស់ដើម្បីរក្សាទម្ងន់សំណាកគំរូនៃចំនួនសរុបប្រជាជនដែលបានស្គាល់ឱ្យស្មើគ្នា។ ដែនកំណត់ទូទៅជាច្រើនដែលបានកំណត់នៅក្នុងវិធីសាស្ត្រជ្រើសសំណាកគំរូ ដូចជាអនុក្រុមប្រជាជនដែលបានតំណាងខ្វះ ឬលើសក្នុងសំណាកគំរូ គឺអាចដោះស្រាយឬកែសម្រួលបានតាមរយៈការថ្លឹងថ្លែងសំណាកគំរូនេះ។ ឯកសារនេះ ផ្តល់ជូននូវសេចក្តីសង្ខេបអំពីវិធីថ្លឹងថ្លែងសំណាកគំរូ ដែលបានយកមកអនុវត្តចំពោះការសិក្សារបស់អង្គការ IJM។

វិធីសាស្ត្រជ្រើសសំណាកគំរូ គឺផ្អែកលើវិធីសាស្ត្រពហុដំណាក់កាល និងត្រូវបានអនុវត្តជាលក្ខណៈឯករាជ្យសម្រាប់ខេត្តនីមួយៗក្នុងចំណោមខេត្តទាំងបួននៅកម្ពុជា រួមមាន៖ ខេត្តបន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងសៀមរាប។ វិធីសាស្ត្រនេះ ចាប់ផ្តើមចេញពីការជ្រើសរើសអនុតំបន់នៅក្នុងខេត្តនីមួយៗ ដែលក្នុងខេត្តនីមួយៗ មានការជ្រើសរើសជាលក្ខណៈប្រព័ន្ធច្បាស់លាស់ និងដោយចៃដន្យ។ ក្នុងតំបន់នីមួយៗ បណ្តុំភូមិមួយ គឺត្រូវបានជ្រើសរើសដោយចៃដន្យសុទ្ធសាធ។ ក្រុមការងារចុះតាមមូលដ្ឋាន ចុះតាមភូមិនីមួយៗដែលបានជ្រើសរើស និងឱ្យមេភូមិចូលរួម ដោយសាកសួរថាតើពួកគេបានដឹងអំពីពលករចំណាកស្រុកដែលទើបតែត្រឡប់មកវិញនៅពេលថ្មីៗនេះដែរឬទេ។ ក្រុមការងារ នឹងកត់ត្រាបញ្ជីបុគ្គលទាំងនោះដោយកត់ត្រាព័ត៌មានទំនាក់ទំនង និងបន្ទាប់មកជ្រើសរើសអនុក្រុមដោយចៃដន្យពីក្នុងបញ្ជីនេះ ដើម្បីធ្វើការសម្ភាសន៍។ លើសពីនេះ ក្រុមការងារចុះមូលដ្ឋាន នឹងស្វែងរកបុគ្គលនៅក្នុងបញ្ជីនេះ តាមរយៈការណែនាំ ឬការចុះទៅទីតាំងផ្ទាល់ និងជ្រើសរើសអនុក្រុមបុគ្គលទាំងនេះដោយចៃដន្យ ដើម្បីធ្វើការសម្ភាសន៍។ ចំពោះករណីដែលមិនគ្រប់កូតា

សំណាកគំរូនៅតាមភូមិ ឬតំបន់ ក្រុមការងារចុះមូលដ្ឋាននឹងចុះទៅតាមភូមិ និង/ឬតំបន់នៅក្បែរខាង និងអនុវត្តតាមនីតិវិធីជ្រើសសំណាកគំរូនេះឡើងវិញ។

ការជ្រើសរើសសំណាកគំរូ ដែលបានមកពីសំណាកគំរូស្ថាពរ គឺមានចំនួន ១.២០៤ នាក់។ បុគ្គលសរុបចំនួន ៣៤៧ នាក់ ត្រូវបានជ្រើសរើស តាមរយៈការអនុវត្តវិធីសាស្ត្រជ្រើសសំណាកគំរូប្រូបាប៊ីលីតេ ឧទាហរណ៍ តាមរយៈការចុះតាមភូមិដែលបានជ្រើសរើសនៅក្នុងតំបន់ដែលបានជ្រើសរើស និងការជ្រើសរើសដោយផ្ទាល់ពីបញ្ជីដែលទទួលបានពីមេភូមិ។ រូបភាព ១០ បង្ហាញអំពីអ៊ីស្តូក្រាមនៃប្រូបាប៊ីលីតេនៃការជ្រើសរើសសម្រាប់អ្នកឆ្លើយតបទាំងនេះ ដែលហៅកាត់ថា សំណាកគំរូប្រូបាប៊ីលីតេ។

*រូបភាព ១០៖ ប្រូបាប៊ីលីតេនៃការជ្រើសរើសស្ថាពរ/សន្ទុតសម្រាប់អ្នកឆ្លើយតបសំណាកគំរូទាំងអស់*

**ប្រូបាប៊ីលីតេនៃការជ្រើសរើសសំណាកសម្រាប់សំណាកគំរូប្រូបាប៊ីលីតេ**





ការផ្ទូវផ្ទងសំណាកគំរូ ជាទូទៅសម្តៅទៅលើនីតិវិធីស្ថិតិដែលកំណត់ទម្ងន់សំណាកគំរូទៅតាមសំណាកគំរូពុំមែនប្រូបាប៊ីលីតេ ដោយផ្អែកលើការអង្កេតដែលបានធ្វើឡើងពីសំណាកគំរូយោង ឬ សំណាកគំរូប្រូបាប៊ីលីតេមួយ (Elliot និង Valliant. ២០១៧)។ ការផ្ទូវផ្ទងសំណាកគំរូ គឺត្រូវបានប្រើប្រាស់ជាទូទៅ ដើម្បីរួមបញ្ចូលជាផ្លូវការនូវសំណាកគំរូមិនមែនប្រូបាប៊ីលីតេទៅក្នុងនីតិវិធីសន្និដ្ឋាន តាមនីតិវិធីមួយដែលកាត់បន្ថយភាពលម្អៀងនៃការជ្រើសរើស ដែលជាទូទៅកើតឡើងចំពោះសំណាកគំរូពុំមែនប្រូបាប៊ីលីតេ។ នីតិវិធីប៉ាន់ប្រមាណនេះ ប្រើប្រាស់នីតិវិធីផ្ទូវផ្ទងឯមធ្យមព្យាករណ៍ (PMM) ដើម្បីដាក់ "ទម្ងន់សន្មត" សម្រាប់ សំណាកគំរូមិនមែនប្រូបាប៊ីលីតេ។ វិធីសាស្ត្រនៃការផ្ទូវផ្ទងមធ្យមព្យាករណ៍ គឺផ្អែកលើការបង្កើតនូវបណ្តុំម្ចាស់ជំនួយដែលមានសក្តានុពលដែលមានទីតាំងស្ថិតនៅក្បែរគ្នា ដោយផ្អែកលើការវាស់ស្ទង់ដែលបានជ្រើសរើសជាមុន ធៀបជាមួយនឹងបណ្តុំអ្នកឆ្លើយតបដែលបានកំណត់។ កញ្ចប់ 'mice' (van Buuren. និង Groothuis-Oudshoorn. ២០១១) នៅក្នុងភាសាកម្មវិធី R programming ផ្តល់នូវសំណុំមុខងារផ្អែកលើវិធីសាស្ត្រ PMM ដែលងាយស្រួលប្រើប្រាស់ដើម្បីជាជំនួយដល់ការកំណត់ទម្ងន់សំណាកគំរូសន្មតទាំងនេះ។

សំណុំអថេរឯករាជ្យ ត្រូវបានកំណត់ដើម្បីប្រើប្រាស់នៅក្នុងនីតិវិធី PPM មានដូចជា ខេត្តកំណើត យេនឌ័រ កម្រិតវប្បធម៌ អាយុ ប្រូបាប៊ីលីតេនៃការជ្រើសរើសដោយផ្អែកលើបញ្ជីរបស់មេភូមិ/បញ្ជីដែលបានបង្កើត និង សូចនាករនៃពលកម្មដោយបង្ខំ។ អថេរឯករាជ្យទាំងនេះ គឺប្រើប្រាស់ជាប៉ារ៉ាម៉ែត្រឥទ្ធិពលចម្បងនៅក្នុងគំរូ beta regression model ដែលប្រូបាប៊ីលីតេជ្រើសរើស បម្រើជាអថេរមិនឯករាជ្យ។ គេរកឃើញថា ខេត្ត យេនឌ័រ ប្រូបាប៊ីលីតេនៃការជ្រើសរើសផ្អែកលើបញ្ជីរបស់

មេភូមិឬបញ្ជីដែលបានបង្កើត គឺសុទ្ធតែសំខាន់ទាំងអស់។ ដូច្នេះ អថេរទាំងនេះគួបផ្សំជាមួយនឹងអថេរសូចនាករស្តីពីពលកម្មដោយបង្ខំ គឺត្រូវបានប្រើប្រាស់សម្រាប់វិធីសាស្រ្តកំណត់ទម្ងន់ PPM។

គំរូ PPM គឺបានអនុវត្តដាច់ដោយឡែកចំពោះអ្នកឆ្លើយតបដែលជាសំណាកគំរូពុំមែនប្រូបាប៊ីលីតេចំនួន ៨៥៧ នាក់។ រូបភាព ១១ បង្ហាញអំពីអ៊ីស្តូក្រាមនៃប្រូបាប៊ីលីតេជ្រើសរើសស្ថាពរឬសន្ទតសម្រាប់ទាំងអ្នកឆ្លើយតបដែលជាសំណាកគំរូប្រូបាប៊ីលីតេ និងពុំមែនប្រូបាប៊ីលីតេ។

*រូបភាព ១១៖ មូលហេតុដែលអ្នកឆ្លើយតបបានសម្រេចចិត្តរាយការណ៍អំពីបទពិសោធន៍ទាំងនេះ*

## ប្រូបាប៊ីលីតេជ្រើសរើសស្ពាពរឬសន្ទុត





ការថ្លឹងថ្លែងសំណាកគំរូ ចាប់ផ្តើមចេញពីការកំណត់ទម្ងន់មូលដ្ឋាន ដែលបញ្ច្រាសទៅនឹងប្រូបាប៊ីលីតេជ្រើសរើស និងការអនុវត្តកត្តាលៃតម្រូវ ០,៧៥ ចំពោះអ្នកឆ្លើយតបពុំមែនប្រូបាប៊ីលីតេ។ កត្តាលៃតម្រូវ ត្រូវបានប្រើប្រាស់ដើម្បីបង្កើនការចូលរួមចំណែកនៃសំណាកគំរូប្រូបាប៊ីលីតេទៅក្នុងនីតិវិធីប៉ាន់ប្រមាណ ដោយសារសំណាកគំរូប្រូបាប៊ីលីតេ គឺមានតម្លៃតូចជាង សំណាកគំរូពុំមែនប្រូបាប៊ីលីតេ ហេតុដូច្នេះដើម្បីការពារពីភាពលម្អៀងណាមួយដែលអាចកើតចេញពីការរួមបញ្ចូលព័ត៌មានពីសំណាកគំរូពុំមែនប្រូបាប៊ីលីតេទៅក្នុងនីតិវិធីប៉ាន់ប្រមាណ។ រូបភាព ១២ បង្ហាញអំពីអ៊ីស្តូក្រាមនៃទម្ងន់មូលដ្ឋាន។ គេបានរកឃើញថា ពុំមានទម្ងន់ណាមួយដែលមានតម្លៃខ្ពស់ពេក លើសពី ៥ដង នៃទម្ងន់មធ្យមនោះទេ។ ដូច្នេះ ការតម្រឹមទម្ងន់សំណាកគំរូ គឺពុំចាំបាច់អនុវត្តនោះទេ ហើយទម្ងន់មូលដ្ឋាន គឺត្រូវបានយកមកអនុវត្តជាទម្ងន់សំណាកគំរូស្ថាពរ។

*រូបភាព ១២៖* *ទម្ងន់មូលដ្ឋាន/ស្ថាពរសម្រាប់អ្នកឆ្លើយតបសំណាកគំរូ។*

**ទម្ងន់សំណាកគំរូមូលដ្ឋានសម្រាប់សំណាកគំរូនៅកម្ពុជា**



## ឧបសម្ព័ន្ធ II. ឯកសារយោង

Chapman. D. (១៩៥១). លក្ខណៈសមាសធាតុមួយចំនួននៃបំណែងចែកអ៊ីពែរធរណីមាត្រ (hypergeometric distribution) ជាមួយនឹងការអនុវត្តចំពោះជំរឿនសំណាកគំរូសត្វសាស្ត្រ. សាកលវិទ្យាល័យកាលីហ្វ័រញ៉ា ឯកសារបោះពុម្ពផ្សាយអំពីស្ថិតិ ១. ១៣១-១៦០.

Elliott. M. R.. & Valliant. R. (២០១៧). ការសន្និដ្ឋានសម្រាប់សំណាកគំរូមិនមែនប្រូបាប៊ីលីតេ. វិទ្យាសាស្ត្រស្ថិតិ. ៣២(២). ២៤៩-២៦៤.Frank. O. and Snijders. T. (១៩៩៤). ការប៉ាន់ប្រមាណអំពីទំហំប្រជាជនលាក់កំបាំងដោយប្រើប្រាស់ការជ្រើសសំណាកគំរូ Snowball. ទិន្នានុប្បវត្តិអំពីស្ថិតិផ្លូវការ ១០. ៥៣-៦៧.

អង្គការពលកម្មអន្តរជាតិ (ILO). (២០១២). ពិបាកមើល ពិបាករាប់៖ គោលការណ៍ណែនាំអំពីការស្ទង់មតិ ដើម្បីប៉ាន់ប្រមាណអំពីពលកម្មដោយបង្ខំលើមនុស្សពេញវ័យ និងកុមារ. ទីក្រុងហ្សឺណែវ៖ អង្គការពលកម្មអន្តរជាតិ.

Klovdahl. A.; Potterat. J.; Woodhouse. D.; Muth. J.; Muth. S. & Darrow. W. (១៩៩៤). បណ្តាញសង្គម និងជំងឺឆ្លង៖ ការសិក្សារបស់ Colorado Springs. វិទ្យាសាស្ត្រសង្គម និងវេជ្ជសាស្ត្រ ៣៨. ៧៩-៨៨.

van Buuren. S.. & Groothuis-Oudshoorn. K. (២០១១). mice: Multivariate Imputation by Chained Equations in R. កម្មវិធីសូហ្វវែរ Journal of Statistical Software. ៤៥(៣). ១–៦៧.

Verite. (២០១២). ការស្រាវជ្រាវអំពីសូចនាការស្តីពីពលកម្មដោយបង្ខំ៖ ភាពជោគជ័យ បញ្ហាប្រឈម និងការឆ្លុះបញ្ចាំងអំពីការចូលរួមនាពេលអនាគត. អាចរកបាននៅ៖ https://www.verite.org/wp-content/ uploads/២០១៦/១១/Lessons-Learned-During-Research-on-Indicators-of-Forced-Labor- in-the-Production-of-Goods-v២.pdf

Zhang. Sheldon X.. Michael W. Spiller. Brian Carl Finch. និង Yang Qin. ២០១៤. "ការប៉ាន់ប្រមាណអំពីការជួញដូរពលកម្មក្នុងចំណោមពលករចំណាកស្រុកមិនមានការអនុញ្ញាតនៅ សានឌីហ្គោ." ANNALS នៃបណ្ឌិតសភាអាមេរិកវិទ្យាសាស្ត្រនយោបាយ និងសង្គម ៦៥៣(១)៖ ៦៥-៨៦.

Zhang. Sheldon X. ២០១២. "ការវាស់វែងការជួញដូរពលកម្ម៖ កំណត់សម្គាល់នៃការស្រាវជ្រាវ." ឧក្រិដ្ឋកម្ម ច្បាប់ និងការប្រែប្រួលសង្គម ៥៨ (៤):៤៦៩–៤៨២.

Zhang. Sheldon X.. Meredith Dank. Kyle Vincent. Pradeep Narayanan. Sowmyaa Bharadwaj. & Sudharsanam Manni Balasubramaniam. (២០១៩). ជនរងគ្រោះគ្មានសំឡេង៖ ការវាស់ស្ទង់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារនៅរដ្ឋប៊ីហា ប្រទេសឥណ្ឌា. ជនរងគ្រោះ & ជនល្មើស ១៤(៧)៖ ៨៣២-៨៥៨.

# កំណត់សម្គាល់ចុងឯកសារ

១. សម្រាប់ការពិភាក្សាគ្រប់ជ្រុងជ្រោយអំពីគោលបំណង និងវត្ថុបំណងនៃការផ្ដួចផ្ដើមសិក្សាវាយតម្លៃក្នុងបរិបទនៃការស្រាវជ្រាវប្រេវ៉ាឡង់ផ្អែកលើបណ្ដាញ សូមមើលឯកសារយោង៖ អង្គការសុខភាពពិភពលោក (២០១៣) សេចក្ដីផ្ដើមអំពីមេរោគអេដស៍ឬជំងឺអេដស៍ និងការអង្កេតតាមដានជំងឺកាមរោគ ម៉ូឌុល៥៤ សេចក្ដីផ្ដើមអំពីការជ្រើសសំណាកគំរូជំរុញដោយអ្នកឆ្លើយតប (លេខ WHO-EM/STD/១៣៤/E)។ ឯកសារនេះអាចទាញយកបានតាមរយៈអាស័យដ្ឋាន https://apps. who.int/iris/handle/១០៦៦៥/១១៦៨៦៤។



IJM

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ**
ប្រអប់សំបុត្រលេខ ៥៨១៤៧
រដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី ២០០៣៧ សហរដ្ឋអាមេរិក
ទូរសព្ទ ៧០៣.៤៦៥.៥៤៩៥
ទូរសារ ៧០៣.៤៦៥.៥៤៩៩
IJM.org

**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ** គឺជាអង្គការសកល ដែលការពារប្រជាជនក្រីក្រពីអំពើហិង្សានៅទូទាំងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ សហការជាដៃគូជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជួយសង្គ្រោះជនរងគ្រោះពីអំពើហិង្សា នាំឧក្រិដ្ឋកម្មមកជំនុំជម្រះរកយុត្តិធម៌ ស្តារសម្បទាជនរងគ្រោះ និងពង្រឹងប្រព័ន្ធយុត្តិធម៌។

អង្គការត្រូវបានទទួលស្គាល់ថាជាអង្គការមួយ ក្នុងចំណោមអង្គការមិនស្វែងរកប្រាក់ចំណេញទាំង ១០ ដែល "ធ្វើឱ្យមានការផ្លាស់ប្តូរ" ដោយសារព័ត៌មានសហរដ្ឋអាមេរិក និងរបាយការណ៍ពិភពលោក គំរូដ៏មានប្រសិទ្ធភាពរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ត្រូវបានទទួលស្គាល់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិក វេទិកាសេដ្ឋកិច្ចពិភពលោក និងអ្នកដឹកនាំនៅជុំវិញពិភពលោក ក៏ដូចជាត្រូវបានចុះផ្សាយដោយក្រសួងការបរទេស ទស្សនាវដ្ដី Forbes, The Guardian សារព័ត៌មាន The New York Times, The Times of India សារព័ត៌មាន ភ្នំពេញ ប៉ុស្ដិ៍ វិទ្យាស្ថានជាតិសាធារណៈ និងសារព័ត៌មាន CNN ក្នុងចំណោមបណ្តាញផ្សព្វផ្សាយជាច្រើនផ្សេងទៀត។

អត្ថបទ និងរូបភាពទាំងអស់ © ២០២៣ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។